# ក្រមរដ្ឋប្បវេណី

## ភាគ ៥

បោះពុម្ពនៅក្នុងខែ មីនា ឆ្នាំ ២០១២

# អារម្ភកថា

សៀវភៅនេះ ត្រូវបានចងក្រងឡើង តាមផ្នែកនៃ "**ក្រមរដ្ឋប្បវេណី**" ហើយ នេះ គឺជាសៀវភៅភាគទី ៥ ដែលគ្របដណ្តប់លើ ***មូលដ្ឋាននៃប្រាតិភោគ*** ។

សៀវភៅនេះ ត្រូវបានបង្កើតឡើងដោយសមាជិកក្រុមការងារដែលរួមមានអនាគតគ្រូបណ្តុះបណ្តាលនៃសាលាភូមិន្ទចៅក្រម ដោយមានការឧបត្ថម្ភគាំទ្រពីទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA) និង នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនៃវិទ្យាស្ថានស្រាវជ្រាវ និង បណ្តុះបណ្តាលនៃក្រសួងយុត្តិធម៌នៃប្រទេសជប៉ុន (ICD) ។

សមាជិកនៃក្រុមការងារមានដូចខាងក្រោម:

| | | |
|---|---|---|
| លោក **អិន ចាន់ទិបុល** | លោកស្រី **ចាំង ស៊ុណាត** | លោកស្រី **សែម សត្តិភូឡា** |
| លោក **សេង នាង** | លោក **ម្លង់ សំណាង** | លោក **តាំង ស៊ុនឡាយ** |
| លោក **យូ ប៊ុនណា** | លោក **ងួន រតនា** | លោក **គង់ តារាធាត** |
| លោក **ម៉ុង មុនីសោភា** | លោក **មួត ម៉ាង** | លោក **ជា សុខហៀង** |
| លោក **ហេង សុខណា** | លោកស្រី **យ៉េត ម៉ូលីន** | លោក **ងួន ចន្ទី** |
| កញ្ញា **ថ្លាង ផារ៉ែណត** | លោកស្រី **ស្រ៊ុន ឈន់ចលភូណ៌** | កញ្ញា **សី លីនណា** |
| លោក **កេត សុជាតិ** | លោក **ចំន្ទ រង្សី** | លោកស្រី **ខៀវ សុខា** |
| លោក **រស់ ពិសិដ្ឋ** | លោក **ស៊ិន សុវណ្ណរ័ត្ន** | លោក **ហេង ចន្ទស៊ីបូរិន** |
| លោក **ផៃ ចិរៈ** | លោក **អ៊ី ម៉ាចះ** | លោក **កេង សុម៉ារិទ្ធ** |
| លោក **ឈុន ចំន្ទសីហា** | លោក **យ៉ាច់ មេត្តា** | លោក **ផៃ ចិចឡុនៈ** |
| លោកស្រី **ទ៉ា សុផ្លា** | លោក **សំម ឫទ្ធីធាសនា** | |

សមាជិកក្រុមការងារទាំងអស់ សង្ឃឹមថា កំរងភាគនីមួយ ៗ នៃ "ក្រមរដ្ឋប្បវេណី" នេះ អាចនឹងជួយដល់អ្នកអានអោយយល់ដឹង និង សិក្សាអំពីមូលដ្ឋាននៃក្រមរដ្ឋប្បវេណីនាពេលបច្ចុប្បន្ន ។

**កំណត់សំគាល់ :** ខ្លឹមសារនៃសៀវភៅនេះ ត្រូវបានចងក្រងឡើង ដោយសមាជិកក្រុមការងារ និង មិនបានឆ្លុះបញ្ចាំងពីទស្សនៈផ្លូវការរបស់អាជ្ញាធរពាក់ព័ន្ធណាមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជាទេ ។

សៀវភៅនេះ បោះពុម្ពលើកទី ១ នៅក្នុងខែ មីនា ឆ្នាំ ២០១២ ។

# មាតិកា

ទំព័រ


**ជំពូកទី ៦ ប្រាតិភោគ** ........ ១

**ផ្នែកទី ១ ហ៊ីប៉ូតែក** ........ ១

១- និយមន័យហ៊ីប៉ូតែក ........ ២

២- ការបង្កើតហ៊ីប៉ូតែក ........ ២

២-១ លក្ខខណ្ឌនៃការបង្កើតហ៊ីប៉ូតែករវាងគូភាគី ........ ២

២-២ លក្ខខណ្ឌតាំងនៃកិច្ចសន្យាហ៊ីប៉ូតែក ........ ៤

៣- អានុភាពនៃហ៊ីប៉ូតែក ........ ៦

៣-១ ទំហំអានុភាពនៃហ៊ីប៉ូតែក ........ ៦

៣-២ ឧបាទេសកម្ម ........ ៧

៣-៣ សិទ្ធិទាមទារសំណងរបស់អ្នកធានាដោយវត្ថុ ........ ៧

៣-៤ លំដាប់នៃហ៊ីប៉ូតែក ........ ៨

៣-៥ ទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានា ........ ១២

៤- ការអនុវត្តហ៊ីប៉ូតែក ........ ១៣

៤-១ អ្នកទិញ ........ ១៤

៤-២ វិធានដើម្បីសម្របសម្រួលការអនុវត្តដោយបង្ខំ នៅពេលដែលមានម្ចាស់សិទ្ធិច្រើនលើអចលនវត្ថុដែលជាកម្មវត្ថុនៃហ៊ីប៉ូតែក ........ ១៤

៥- ការចាត់ចែងហ៊ីប៉ូតែក ........ ២១

៥-១ ហ៊ីប៉ូតែកបន្ត ........ ២១

៥-២ អនុប្បទាន ឬ ការបោះបង់ហ៊ីប៉ូតែក ........ ២២

៥-៣ អនុប្បទាន ឬ ការបោះបង់ និង ការផ្លាស់ប្តូរនូវលំដាប់នៃហ៊ីប៉ូតែក ........ ២៣

៦- ការរលត់ហ៊ីប៉ូតែក ........ ២៥

៦-១ សេចក្តីផ្តើម ........ ២៥

៦-២ ការសងដោយថ្លៃលក់ ........ ២៥

៦-៣ អាជ្ញាយុកាលនៃការលត់ ........ ២៦

**ផ្នែកទី ២ សិទ្ធិឃាត់ទុក** ........ ២៨

១- និយមន័យ ........ ២៨

២- លក្ខខណ្ឌនៃសិទ្ធិឃាត់ទុក ........ ២៨
៣- អានុភាព ........ ៣០
៣-១ សិទ្ធិឃាត់ទុក ........ ៣០
៣-២ សិទ្ធិទទួលសំណងពីផលដោយមានអាទិភាព ........ ៣០
៣-៣ ករណីយកិច្ចរបស់ម្ចាស់សិទ្ធិឃាត់ទុក ........ ៣១
៣-៤ សិទ្ធិទាមទារឱ្យសងសោហ៊ុយមកវិញ ........ ៣១
៤- អាជ្ញាយុកាលនៃការរលត់សិទ្ធិ ........ ៣១
៥- ការរលត់សិទ្ធិឃាត់ទុក ........ ៣១
**ផ្នែកទី ៣ សិទ្ធិលើការបញ្ចាំ ........ ៣៣**
១- សេចក្ដីផ្ដើម ........ ៣៣
២- ប្រភេទនៃកម្មវត្ថុនៃសិទ្ធិលើការបញ្ចាំ ........ ៣៣
៣- លក្ខខណៈទូទៅ ........ ៣៣
៣-១ លក្ខខណ្ឌ ........ ៣៣
៣-២ ទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានា ........ ៣៣
៣-៣ អានុភាព ........ ៣៤
៣-៤ អាជ្ញាយុកាលនៃការរលត់សិទ្ធិលើបំណុល ........ ៣៥
៣-៥ ការបញ្ចាំបន្ត ........ ៣៥
៣-៦ ការហាមកិច្ចសន្យាបញ្ចាំផ្ដាច់ ........ ៣៦
៤- ការបញ្ចាំចលនវត្ថុ ........ ៣៦
៤-១ លក្ខខណ្ឌតាំងនៃសិទ្ធិលើការបញ្ចាំ ........ ៣៦
៤-២ ការប្រើប្រាស់ ឬ ការអាស្រ័យផលពីវត្ថុបញ្ចាំដោយម្ចាស់សិទ្ធិលើការបញ្ចាំ ........ ៣៦
៤-៣ ការអនុវត្តសិទ្ធិលើការបញ្ចាំដោយសង្ខេប ........ ៣៧
៤-៤ លំដាប់នៃសិទ្ធិលើការបញ្ចាំ ........ ៣៧
៥- ការបញ្ចាំអចលនវត្ថុ ........ ៣៨
៥-១ សិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យផលរបស់ម្ចាស់សិទ្ធិលើការបញ្ចាំ ........ ៣៨
៥-២ ការគោរពតាមវិធីប្រើប្រាស់ធម្មតា ........ ៣៨
៥-៣ បទបញ្ញត្តិពិសេសស្ដីពីដីសំរាប់ធ្វើកសិកម្ម ........ ៣៨
៥-៤ បន្ទុកសោហ៊ុយគ្រប់គ្រងវត្ថុបញ្ចាំ ........ ៣៩
៥-៥ ការប្រាក់នៃសិទ្ធិលើបំណុល ........ ៤០

៥-៦ ការសន្យាពិសេសនៅក្នុងកិច្ចសន្យាបញ្ចាំ....................................................................៤០

៥-៧ អំឡុងពេលនៃសិទ្ធិលើការបញ្ចាំដែលមានអត្ថិភាព ..........................................................៤០

៥-៨ ការអនុវត្តដូចគ្នាតាមបញ្ញត្តិស្តីពីហ៊ីប៉ូតែក ............................................................... ៤១

៦- ការបញ្ចាំសិទ្ធិ.................................................................................................... ៤២

៦-១ លក្ខខណ្ឌសុពលភាពនៃការបញ្ចាំសិទ្ធិលើបំណុលចំពោះគូរភាគី.......................................៤៣

៦-២ លក្ខខណ្ឌតតាំងនៃការបញ្ចាំសិទ្ធិលើបំណុលចំពោះតតិយជន ........................................៤៣

៦-៣ ការអនុវត្តសិទ្ធិលើការបញ្ចាំដោយប្រមូលសិទ្ធិលើបំណុល...............................................៤៤

**ផ្នែកទី ៤ ប្រាតិភោគដោយអនុប្បទាន..........................................................................៤៥**

១- សេចក្តីផ្តើម........................................................................................................ ៤៦

២- លក្ខខណ្ឌ.......................................................................................................... ៤៧

៣- អានុភាព.............................................................................................................. ៤៧

៣-១ ទំហំនៃអានុភាព......................................................................................................... ៤៧

៣-២ អានុភាពចំពោះផល ................................................................................................ ៤៧

៣-៣ ឧបាទេសកម្ម........................................................................................................... ៤៨

៣-៤ ទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានា...................................................................៤៩

៣-៥ ការចាត់ចែងវត្ថុដែលជាកម្មវត្ថុដោយអ្នកធានាដោយវត្ថុ និង ម្ចាស់សិទ្ធិប្រាតិភោគប្រត្យក្ស.....៤៩

៣-៦ បញ្ញត្តិពិសេស នៅក្នុងករណីដែល ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន កាន់កាប់វត្ថុដែលជាកម្មវត្ថុ ............................................................................................................... ៥១

៤- ការអនុវត្តសិទ្ធិប្រាតិភោគដោយអនុប្បទាន ................................................................. ៥១

៤-១ ការប្តូរជាប្រាក់........................................................................................................ ៥១

៤-២ អនុប្បទានជាស្ថាពរ ................................................................................................. ៥២

៤-៣ករណីយកិច្ចត្រូវបង់ទឹកប្រាក់ដែលលើស ................................................................... ៥២

៤-៤ សិទ្ធិទទួលយកមកវិញរបស់អ្នកបង្កើត........................................................................ ៥២

**ផ្នែកទី ៥ ការធានា ............................................................................................... ៥៣**

១-សេចក្តីផ្តើម..........................................................................................................៥៣

២- ការបង្កើតកិច្ចសន្យាធានា.......................................................................................៥៣

២-១ លក្ខខណ្ឌជាមូលដ្ឋាន.............................................................................................៥៣

២-២ ការការពារអ្នកធានា.................................................................................................៥៣

៣- អានុភាពនៃកិច្ចសន្យាធានា.......................................................................................៥៤

៣-១ ទំហំកាតព្វកិច្ចធានា..................................................................................................៥៤

៣-២ លក្ខណៈនៃកាតព្វកិច្ចធានា...........................................................................................៥៥

៣-៣ សិទ្ធិរបស់អ្នកធានា ...................................................................................................... ៥៦

៣-៤ លក្ខណសម្បត្តិរបស់អ្នកធានា.......................................................................................... ៥៧

៣-៥ គោលការណ៍នៃការធានាដោយសាមគ្គី ........................................................................... ៥៨

៣-៦ អានុភាពនៃហេតុដែលកើតឡើងទាក់ទងនឹងអ្នកធានា...................................................... ៥៨

៣-៧ អ្នកធានារួម .................................................................................................................. ៥៨

៤- ប្រភេទនៃការធានា..............................................................................................................៥៩

៥- សិទ្ធិទាមទារសំណង.............................................................................................................. ៦១

៥-១ លក្ខខណ្ឌនៃការទាមទារសំណង......................................................................................... ៦១

៥-២ ទំហំនៃការទាមទារសំណង ................................................................................................ ៦២

៥-៣ ការទាមទារសំណងជាមុន.................................................................................................. ៦២

៥-៤ សិទ្ធិទាមទាររបស់អ្នកធានារួម..........................................................................................៦៣

៦- ឧបាទេសកម្ម .......................................................................................................................៦៣

**ផ្នែកទី ៦ អនុប្បទានសិទ្ធិលើបំណុល**...................................................................................**៦៤**

១- ភាពដែលអាចធ្វើអនុប្បទានសិទ្ធិលើបំណុល ........................................................................ ៦៤

១-១ បញ្ញត្តិទូទៅ ................................................................................................................... ៦៤

១-២ ការសន្យាពិសេសហាមមិនឱ្យធ្វើអនុប្បទាន........................................................................ ៦៤

២- លក្ខខណ្ឌដើម្បីធ្វើអនុប្បទានសិទ្ធិលើបំណុល ..................................................................... ៦៤

៣- លក្ខខណ្ឌតតាំង..................................................................................................................... ៦៥

៣-១ លក្ខខណ្ឌតតាំងចំពោះកូនបំណុល ..................................................................................... ៦៥

៣-២ លក្ខខណ្ឌតតាំងចំពោះអនុប្បទានិកដទៃទៀត ..................................................................... ៦៦

៤- អានុភាពនៃការជូនដំណឹង និង ការយល់ព្រម.......................................................................... ៦៧

**ជំពូកទី ៧ អានុភាពនៃសិទ្ធិលើបំណុលចំពោះតតិយជន**.............................................................**៦៨**

**ផ្នែកទី ១ សិទ្ធិលុបចោលនូវអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍**.............................................**៦៨**

១- សេចក្តីផ្តើម...........................................................................................................................៦៨

២- មុខងារ និង និយមន័យ........................................................................................................ ៦៨

៣- លក្ខខណ្ឌ ..............................................................................................................................៦៩

៣-១ អត្ថិភាពនៃសិទ្ធិដែលត្រូវបានរក្សាការពារ .......................................................................៦៩

៣-២ អំពើដែលនាំឱ្យខូចខាតផលប្រយោជន៍ និង ការដឹងអំពីការខូចខាតផលប្រយោជន៍ .......... ៧១

៣-៣ ការបានដឹងរបស់អ្នកដែលបានទទួលផលប្រយោជន៍ពីអំពើរបស់កូនបំណុល ឬ ការបានដឹងរបស់អ្នកដែលបានទទួលបន្តនូវវត្ថុពីអ្នកនោះ ឬ អំពើដែលនាំឱ្យខូចខាតផលប្រយោជន៍នោះ មិនត្រូវបានបង់ថ្លៃ ..... ៧៣

៤- ការអនុវត្តសិទ្ធិលុបចោលនូវអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍ .......... ៧៤

៤-១ នីតិវិធីតុលាការដែលចាំបាច់ .......... ៧៤

៤-២ ការតម្កល់ .......... ៧៤

៤-៣ អានុភាពនៃសិទ្ធិលុបចោលនូវអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍ .......... ៧៦

៤-៤ អំឡុងពេលដែលអាចអនុវត្តសិទ្ធិលុបចោលនូវអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍ .......... ៧៧

**ផ្នែកទី ២ ឧបាទេសកម្មដោយអ្នកមានសិទ្ធិលើបំណុល .......... ៧៨**

១- សេចក្តីផ្តើម .......... ៧៨

២- លក្ខខណ្ឌ .......... ៧៨

២-១ ឧបាទេសកម្មដោយផ្អែកតាមមាត្រា ៤២២ កថាខណ្ឌទី ១ .......... ៧៩

២-២ ឧបាទេសកម្មដោយផ្អែកតាមមាត្រា ៤២២ កថាខណ្ឌទី ២ .......... ៨២

៣- វិធីអនុវត្ត .......... ៨៣

៤- អានុភាពនៃសិទ្ធិឧបាទេសកម្មរបស់ម្ចាស់បំណុល .......... ៨៣

៤-១ ការតតាំងរបស់កូនបំណុលទី ៣ .......... ៨៣

៤-២ ទំនាក់ទំនងរវាងម្ចាស់បំណុលដែលធ្វើឧបាទេសកម្ម និង កូនបំណុល .......... ៨៤

៤-៣ អានុភាពនៃឧបាទេសកម្មចំពោះកូនបំណុល .......... ៨៤

៤-៤ ការទទួលការសង .......... ៨៥

# ជំពូកទី ៦

# ប្រាតិភោគ

## ផ្នែកទី ១

## ហ៊ីប៉ូតែក

**សេចក្តីផ្តើម**

ហ៊ីប៉ូតែក គឺជាប្រភេទមួយនៃសិទ្ធិប្រាតិភោគប្រត្យក្សដែលកូនបំណុល ឬ តតិយជនដែលបានយកទ្រព្យសម្បត្តិមកដាក់ហ៊ីប៉ូតែក និង ម្ចាស់បំណុលបានព្រមព្រៀងបង្កើតជាបន្ទុកមួយនៅលើទ្រព្យរបស់ខ្លួនដើម្បីធានាកាតព្វកិច្ចដែលមានចំពោះម្ចាស់បំណុលដោយមិនមានការផ្ទេរនូវការកាន់កាប់ទ្រព្យនោះទៅឱ្យម្ចាស់បំណុលឡើយ ។

ហ៊ីប៉ូតែក ជារបបគតិយុត្តិមួយនៃការធានាបំណុលដោយវត្ថុដែលត្រូវបានដាក់ជាប្រាតិភោគ ។ សារៈប្រយោជន៍ដ៏ធំបំផុតមួយរបស់ហ៊ីប៉ូតែកគឺថា កូនបំណុលមិនចាំបាច់ផ្ទេរនូវការកាន់កាប់ទ្រព្យដែលជាកម្មវត្ថុនៃហ៊ីប៉ូតែកទៅឱ្យម្ចាស់បំណុលឡើយ ពីព្រោះករណីនេះ ធ្វើឱ្យកូនបំណុលអាចបន្តការរស់នៅ ឬ ការធ្វើអាជីវកម្មនៅលើទ្រព្យរបស់ខ្លួននោះជាធម្មតា ទោះបីជាទ្រព្យនោះកំពុងតែជាប់ហ៊ីប៉ូតែកក៏ដោយដែលចំណុចនេះហើយនាំឱ្យវាមានការខុសប្លែកពីការបញ្ចាំ និង ប្រាតិភោគដោយអនុប្បទានដែលមានចែងក្នុងក្រមរដ្ឋប្បវេណីដែលកូនបំណុលត្រូវតែផ្ទេរនូវការកាន់កាប់វត្ថុទៅឱ្យម្ចាស់បំណុល និង ខុសប្លែកពីការធានាដោយវត្ថុ (យោងតាមច្បាប់ភូមិបាលឆ្នាំ២០០១) ដែលកូនបំណុលត្រូវតែផ្ទេរនូវបណ្ណ័កាន់កាប់វត្ថុនោះទៅឱ្យម្ចាស់បំណុល ។

សារៈប្រយោជន៍ មួយទៀតនៃហ៊ីប៉ូតែក គឺថា កូនបំណុលអាចបង្កើតហ៊ីប៉ូតែកច្រើននៅលើទ្រព្យនោះបានចំពោះម្ចាស់បំណុលច្រើនគ្នាទៀតផង ហើយដែលលំដាប់នៃការទទួលបានសំណង គឺអាស្រ័យទៅលើពេលវេលានៃការចុះបញ្ជីសុរិយោដីនៃបន្ទុកហ៊ីប៉ូតែក នោះ ។

ហេតុដូច្នេះការយល់អំពីការបង្កើតកិច្ចសន្យាហ៊ីប៉ូតែក និង អានុភាពនៃកិច្ចសន្យាហ៊ីប៉ូតែកនោះ ជាការមួយដែលមានសារៈសំខាន់ណាស់ ពីព្រោះថាបើ កិច្ចសន្យាហ៊ីប៉ូតែកមួយ ត្រូវបានបង្កើតឡើង ប៉ុន្តែ មិនស្របទៅនឹងលក្ខខណ្ឌដែលច្បាប់បានកំណត់ទេនោះ នាំឱ្យកិច្ចសន្យាហ៊ីប៉ូតែកនោះមិនមានអានុភាពតាមផ្លូវច្បាប់ទាល់តែសោះ ហើយម្ចាស់បំណុលក៏មិនមានសិទ្ធិប្រាតិភោគប្រត្យក្សនៅលើវត្ថុដែលដាក់ហ៊ីប៉ូតែក ដោយកូនបំណុលនោះដែរ ។ ពោលគឺម្ចាស់បំណុលមិនអាចអនុវត្តនូវសិទ្ធិហ៊ីប៉ូតែករបស់ខ្លួន ឬ ទទួលបាននូវអាទិភាពនៃការសងបំណុល របស់ខ្លួនមុនម្ចាស់បំណុលដទៃទៀតបានទេ ។

អ្វីដែលគួរឱ្យកត់សំគាល់នោះគឺថា ហ៊ីប៉ូតែកដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណីនេះ គឺអាចអនុវត្តបានតែលើអចលនវត្ថុ សិទ្ធិជួលអចិន្ត្រៃយ៍ ឬផលុបភោគ តែប៉ុណ្ណោះ។ ចំពោះហ៊ីប៉ូតែកលើចលនវត្ថុ គឺថិតនៅក្នុងក្របខណ្ឌនៃច្បាប់ពិសេសដោយឡែក។

## ១- និយមន័យហ៊ីប៉ូតែក

យោងតាមមាត្រា៨៤៣ នៃក្រមរដ្ឋប្បវេណី បានឱ្យនិយមន័យ " *ហ៊ីប៉ូតែក* " ថាជាសិទ្ធិមួយដែលម្ចាស់បំណុលទទួលការសងចំពោះសិទ្ធិលើបំណុលរបស់ខ្លួន ដោយមានអាទិភាពជាងម្ចាស់បំណុលផ្សេងទៀតចំពោះអចលនវត្ថុដែលបានដាក់ជាប្រាតិភោគនៃកាតព្វកិច្ចដោយកូនបំណុល ឬតតិយជនដោយមិនផ្ទេរការកាន់កាប់។

ក្នុងន័យនេះយើងឃើញថាហ៊ីប៉ូតែក គឺជារបបគតិយុត្តិមួយដែលបង្កើតឡើងដើម្បីការពារនូវផលប្រយោជន៍របស់ម្ចាស់បំណុល។ ហើយម្ចាស់បំណុលដែលមានសិទ្ធិហ៊ីប៉ូតែកដើម្បីធានានូវបំណុលរបស់ខ្លួន មានអាទិភាពជាងម្ចាស់បំណុលផ្សេងទៀតដែលគ្មានសិទ្ធិហ៊ីប៉ូតែកទេ។

**ឧទាហរណ៍**

លោក **ខ** គឺជាម្ចាស់បំណុលរបស់លោក **ក** ចំនួន ១០ ០០០ ដុល្លារ។ លោក **ក** បានយកអចលនវត្ថុ Lទៅដាក់ហ៊ីប៉ូតែកឱ្យលោក **ខ** ដើម្បីធានាបំណុល។ លោក **ក** ក៏មានម្ចាស់បំណុលផ្សេងទៀតដែរគឺ លោក **គ** និង លោក **ឃ** ។ បើដល់ពេលកំណត់សងហើយ លោក **ក** មិនមានប្រាក់សងទេនោះ លោក **ខ** អាចអនុវត្តសិទ្ធិហ៊ីប៉ូតែករបស់ខ្លួនចំពោះដី L របស់លោក **ក** ។ សន្មត់ថា អចលនវត្ថុ L នោះលក់បានតម្លៃតែ ១០ ០០០ ដុល្លារ។ ប្រាក់ ដែលបានមកពីការលក់នេះ ត្រូវយកទៅសងតែលោក **ខ** តែប៉ុណ្ណោះ។ ម្ចាស់បំណុលផ្សេងទៀត នឹងមិនទទួលបាននូវសំណងដែលកើតចេញមកពីការលក់អចលនវត្ថុ L នោះទេ។ ប៉ុន្តែលោក **គ** និង លោក **ឃ** នៅតែអាចទាមទារសំណងពីលោក **ក** ។

## ២- ការបង្កើតហ៊ីប៉ូតែក

### ២-១ លក្ខខណ្ឌសុពលភាពនៃការបង្កើតកិច្ចសន្យាហ៊ីប៉ូតែករវាងគូភាគី

ដូចដែលបានលើកឡើងខាងលើហើយថា ការយល់អំពីលក្ខខណ្ឌសុពលភាពចំពោះគូភាគីក្នុងការបង្កើតកិច្ចសន្យាហ៊ីប៉ូតែក មួយជាការដែលសំខាន់ណាស់ដើម្បីឱ្យម្ចាស់បំណុលអាចអនុវត្តនូវសិទ្ធិហ៊ីប៉ូតែករបស់ខ្លួនបាន។

មាត្រា ៨៤៤ នៃក្រមរដ្ឋប្បវេណីបានចែងថា ហ៊ីប៉ូតែកនឹងត្រូវបានបង្កើតឡើងដោយការព្រមព្រៀងគ្នារវាងម្ចាស់បំណុល និង កូនបំណុល ឬ តតិយជនដែលយកអចលនវត្ថុរបស់ខ្លួនមកដាក់ជាប្រាតិភោគ ។

យោងតាមមាត្រានេះ យើងឃើញថា លក្ខខណ្ឌសុពលភាពចំពោះគូភាគីក្នុងការបង្កើតកិច្ចសន្យាហ៊ីប៉ូតែកមួយ គឺការព្រមព្រៀងរវាងម្ចាស់បំណុល និង កូនបំណុល ឬ តតិយជនដែលយកអចលនវត្ថុរបស់ខ្លួនមកដាក់ជាប្រាតិភោគតែប៉ុណ្ណោះ ប៉ុន្តែ វាមិនតំរូវឱ្យមានការចុះបញ្ជីឡើយ ។

សួរថា តើសំរាប់កិច្ចសន្យាហ៊ីប៉ូតែកមួយ តំរូវឱ្យគូរភាគីធ្វើដោយផ្ទាល់មាត់ ឬ ជាលាយលក្ខ័អក្សរ ទើបមានសុពលភាព? ដោយសារតែមាត្រា ៨៤៤ ខាងលើ មិនបានកំរិតអំពីលក្ខខណ្ឌទម្រង់ក្នុងការបង្កើតកិច្ចសន្យាហ៊ីប៉ូតែក របស់គូរភាគីទេ ការព្រមព្រៀងអាចត្រូវបានធ្វើឡើងតាមទំរង់ណាមួយក៏បាន គឺដោយផ្ទាល់មាត់ក៏បាន ឬ ជាលាយល័ក្ខអក្សរក៏បាន។ ប៉ុន្តែក្រមនេះ បានកំរិតនូវលក្ខខណ្ឌទម្រង់របស់កិច្ចសន្យាហ៊ីប៉ូតែក ដើម្បីឱ្យគូភាគីអាចយកហ៊ីប៉ូតែករបស់ខ្លួនទៅតតាំងនឹងតតិយជនបាន គឺកិច្ចសន្យាហ៊ីប៉ូតែកនោះ ត្រូវធ្វើក្រោមទំរង់ជាលិខិតយថាភូត និង ត្រូវយកទៅចុះបញ្ជីសុរិយោដី ( មាត្រា៨៤៥ នៃក្រមរដ្ឋប្បវេណី) ។ ដូចនេះលិខិត យថាភូត ឬ ការចុះបញ្ជីមិនមែនជាលក្ខខណ្ឌ សុពលភាពនៃកិច្ចសន្យាហ៊ីប៉ូតែកចំពោះគូរភាគីទេ មានន័យថាកិច្ចសន្យាដោយផ្ទាល់មាត់ ឬ ជាលាយលក្ខ័អក្សរ ក៏ដោយក៏មានសុពលភាពចំពោះគូរភាគីដែរ ។ ទោះបីជា គូភាគីមិនបានបង្កើតកិច្ចសន្យាហ៊ីប៉ូតែកនោះជាលាយល័ក្ខអក្សរក៏ដោយ ក៏កិច្ចសន្យាហ៊ីប៉ូតែក នៅតែមានអានុភាពដដែល។ ប៉ុន្តែ វាអាចបង្កឱ្យមានការលំបាកសំរាប់ភាគីក្នុងការបង្ហាញភស្តុតាងនៅចំពោះមុខតុលាការ ហើយអ្វីដែលគួរឱ្យកត់សម្គាល់នោះគឺថា វាអាចមានបញ្ហាលំបាកសំរាប់ម្ចាស់បំណុលហ៊ីប៉ូតែកក្នុងការអនុវត្តហ៊ីប៉ូតែករបស់ខ្លួន ពីព្រោះយោងតាមមាត្រា ៤៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី គឺតំរូវឱ្យមានលិខិតអនុវត្តដែលលិខិតអនុវត្តមួយនៅក្នុងចំណោមលិខិតអនុវត្តទាំងនោះគឺជា លិខិតយថាភូតដែលធ្វើឡើងដោយសារការី ។

ហេតុនេះទោះបីជា ក្រមរដ្ឋប្បវេណី មិនតំរូវឱ្យមានលក្ខខណ្ឌទម្រង់នៃកិច្ចសន្យាហ៊ីប៉ូតែកក៏ដោយ ក៏ភាគីត្រូវបង្កើតកិច្ចសន្យាហ៊ីប៉ូតែករបស់ខ្លួនក្រោមទម្រង់ជាលិខិតយថាភូតដើម្បីឱ្យធានាបាននូវភាពឆាប់រហ័ស និង ងាយស្រួលក្នុងការអនុវត្តនូវសិទ្ធិហ៊ីប៉ូតែករបស់ខ្លួន ។

**ឧទាហរណ៍**

លោក **ក** ចង់ខ្ចីប្រាក់លោក **ខ** ចំនួន ១០ ០០០ ដុល្លារ ។ លោក **ក** មានដី L មួយកន្លែង ។ ដើម្បីធានានូវការសងបំណុលរបស់ខ្លួន លោក **ខ** ទាមទារឱ្យលោក **ក** ដាក់ដី L ជាប្រាតិភោគមកឱ្យខ្លួន ។ លោក **ក** និង លោក **ខ** បានចុះកិច្ចសន្យាជាលាយល័ក្ខអក្សរជាមួយគ្នា ប៉ុន្តែកិច្ចសន្យានោះធ្វើត្រឹមតែជាលិខិតឯកជនមិនបានធ្វើជាលិខិតយថាភូត ហើយក៏មិនបានយកកិច្ចសន្យាហ៊ីប៉ូតែកនោះទៅចុះបញ្ជីសុរិយោដី ។ នៅក្នុងករណីនេះ មិនត្រឹមតែកិច្ចសន្យាខ្ចីបរិភោគតែប៉ុណ្ណោះទេដែលមានអានុភាពនោះ គឺថែមទាំងការព្រមព្រៀងគ្នាក្នុងការបង្កើតហ៊ីប៉ូតែកក៏មានសុពលភាពដែររវាងលោក **ក** និង លោក **ខ** ។ បើលោក **ក** មិនមានប្រាក់ដើម្បីសងបំណុលទៅលោក **ខ** នៅពេលដែលដល់ពេលកំណត់ត្រូវសងទេ លោក **ខ** អាចដាក់ពាក្យសុំឱ្យអនុវត្តហ៊ីប៉ូតែករបស់ខ្លួនទៅតុលាការបាន ។ ម្យ៉ាងទៀត ទោះបីជា លិខិតយថាភូត និង ការចុះបញ្ជី មិនតំរូវឱ្យមានក្នុងការបង្កើតហ៊ីប៉ូតែកក៏ដោយ

ក៏លិខិតយថាភូត សាលក្រម ឬ សាលដីកា ឬ ឯកសារដែលមានអានុភាពដូចគ្នា គឺតំរូវឱ្យមានដែរនៅពេលអនុវត្ត ដើម្បីបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិ។ ហេតុដូច្នេះ ជាថ្មីម្តងទៀត វាជាការល្អ និង ងាយស្រួលសំរាប់ម្ចាស់បំណុល ក្នុងការមានលិខិតយថាភូត។

បញ្ហានឹងកើតមានឡើងនៅពេលដែលលោក **ក** មានម្ចាស់បំណុលផ្សេងទៀតដូចជាលោក **គ** និងលោក **ឃ** ហើយលោក **ក** មិនមានអចលនវត្ថុណាផ្សេងទៀតក្រៅពីអចលនវត្ថុ L នោះ។ តើលោក **ខ** អាចយកហ៊ីប៉ូតែក របស់ខ្លួនទៅតតាំងជាមួយលោក **គ** និង លោក **ឃ** បានដែរឬទេ? នៅក្នុងករណីនេះ តើលោក **ខ** អាចទទួលបាននូវ សិទ្ធិបុរិមា ឬ អាទិភាពនៃសំណងដែលកើតចេញពីការលក់ដោយបង្ខំនូវអចលនវត្ថុ L នោះមុនម្ចាស់បំណុល **គ** និង **ឃ** ដែរឬទេ?

ហើយតើវានឹងក្លាយទៅជាយ៉ាងដូចម្តេចទៅវិញ នៅពេលដែលលោក **ខ** និង លោក **គ** មិនបានចុះបញ្ជី ហ៊ីប៉ូតែករបស់ខ្លួនទេ តែបែរជាលោក **ឃ** ដែលជាម្ចាស់បំណុលបានចុះបញ្ជីហ៊ីប៉ូតែកនោះ? ដើម្បីឆ្លើយតបទៅនឹង សំណួរនេះបាន សូមពិនិត្យមើលលក្ខខណ្ឌតតាំងនៃហ៊ីប៉ូតែកចំពោះតតិយជនដូចខាងក្រោមនេះ។

### ២-២ លក្ខខណ្ឌតតាំងនៃកិច្ចសន្យាហ៊ីប៉ូតែក

តើលក្ខខណ្ឌ៍នៃការតតាំងមានអត្ថន័យយ៉ាងដូចម្តេច?

ទំនាក់ទំនងគតិយុត្ត ជួនកាលមានលក្ខខណ្ឌ ២ ផ្សេងគ្នា គឺ លក្ខខណ្ឌសុពលភាពសំរាប់គូភាគី និង លក្ខខណ្ឌតតាំងនៃហ៊ីប៉ូតែកសំរាប់តតិយជនដែលមិនមែនជាគូភាគី។ ហ៊ីប៉ូតែកដែលជាសិទ្ធិមួយដែលកើតឡើងតាម កិច្ចសន្យារបស់គូភាគីនោះក៏មានលក្ខខណ្ឌដោយឡែកសំរាប់តតាំងជាមួយតតិយជនដែរ។ ដោយសារតែហ៊ីប៉ូតែក ជាសិទ្ធិដែលមិនមែនមានឥទ្ធិពលចំពោះតែម្ចាស់បំណុល និង កូនបំណុលនោះទេ ប៉ុន្តែថែមទាំងមានឥទ្ធិពល ចំពោះតតិយជនផ្សេងទៀត ដូចជាជនដែលទិញដីដែលជាប់ហ៊ីប៉ូតែកនោះ និងម្ចាស់បំណុលផ្សេងទៀតដែល មិនមែនជាម្ចាស់បំណុលហ៊ីប៉ូតែក។ ហេតុនេះការយល់ដឹងអំពីលក្ខខណ្ឌតំរូវតាមច្បាប់សំរាប់ឱ្យម្ចាស់សិទ្ធិហ៊ីប៉ូតែក អាចតតាំងនូវសិទ្ធិហ៊ីប៉ូតែករបស់ខ្លួនជាមួយនឹងតតិយជនបានជាប្រការមួយដែលចាំបាច់។

យោងតាមមាត្រា ៨៤៥ នៃក្រមរដ្ឋប្បវេណីបានចែងថា *ម្ចាស់បំណុលហ៊ីប៉ូតែកមិនអាចយកហ៊ីប៉ូតែក នោះមកតតាំងចំពោះតតិយជន ក្រៅពីអ្នកដែលបង្កើតហ៊ីប៉ូតែកបានឡើយ ប្រសិនបើមិនបានធ្វើកិច្ចសន្យាបង្កើត ហ៊ីប៉ូតែកនោះ ដោយលិខិតយថាភូត និងមិនបានចុះបញ្ជីនៅក្នុងសៀវភៅបញ្ជីដីធ្លីទេ* ។

ហេតុផលដែលតំរូវឱ្យមានការចុះបញ្ជីសុរិយោដីយ៉ាងដូច្នេះ គឺដើម្បីជូនដំណឹងដល់សាធារណជនឱ្យបាន ដឹង ពីព្រោះតែនៅពេលដែលអចនលវត្ថុមួយចំនួន ត្រូវបានដាក់ជាហ៊ីប៉ូតែក ម្ចាស់បំណុលហ៊ីប៉ូតែក នឹងទទួលបាន នូវការសងសិទ្ធិលើបំណុលរបស់ខ្លួន ពីអចលនវត្ថុហ៊ីប៉ូតែកនោះដោយមានអាទិភាពជាងម្ចាស់បំណុលផ្សេងដទៃ ទៀត។ ហេតុនេះ វាទាមទារឱ្យមានការប្រកាសជាសាធារណៈនូវសិទ្ធិនោះតាមរយៈការចុះបញ្ជីសុរិយោដីដើម្បីឱ្យ តតិយជន ក្រៅពីគូភាគីនៃកិច្ចសន្យាអាចមើលឃើញ និង បានដឹងអំពីសិទ្ធិនោះ។ នៅពេលដែលមានការចុះបញ្ជី

ហ៊ីប៉ូតែកនោះហើយ សូម្បីតែអ្នកដែលទិញអចលនវត្ថុដែលជាប់ហ៊ីប៉ូតែកដោយការចុះបញ្ជីនោះ មិនអាចបដិសេធនូវអានុភាពនៃហ៊ីប៉ូតែកនោះបានទេ។ និយាយម្យ៉ាងទៀត អ្នកទិញអាចធ្វើលទ្ធកម្មនូវដីដែលមានជាប់បន្ទុកហ៊ីប៉ូតែកតែប៉ុណ្ណោះ ក្នុងករណីដែលម្ចាស់បំណុលហ៊ីប៉ូតែក អាចតតាំងនូវហ៊ីប៉ូតែករបស់ខ្លួន។

ជាសរុបមក ដើម្បីតតាំងហ៊ីប៉ូតែកចំពោះតតិយជន ត្រូវតែគោរពនូវលក្ខខណ្ឌដូចតទៅ:

-ត្រូវមានកិច្ចសន្យាហ៊ីប៉ូតែកជាលាយលក្ខណ៍អក្សរ

-កិច្ចសន្យាហ៊ីប៉ូតែកនោះត្រូវធ្វើជាទម្រង់យថាភូត

-ត្រូវយកកិច្ចសន្យាហ៊ីប៉ូតែកនោះ ទៅចុះបញ្ជីសុរិយោដី។

**ឧទាហរណ៍:**

១- X គឺជាម្ចាស់កម្មសិទ្ធិនៃដី (L) ដែលមានតម្លៃ ៣000 ដូល្លារ ហើយបានជួលដីនោះទៅឱ្យតតិយជន។ X ចង់ខ្ចីប្រាក់ចំនួន ១ 000 ដូល្លារពី Y ។Y ស្នើសុំឱ្យដាក់ហ៊ីប៉ូតែកលើដី (L) នោះ។

តើ X ត្រូវប្រគល់ប័ណ្ណកម្មសិទ្ធិទៅឱ្យ Y ដែរឬទេ ដើម្បីធានាបំណុលរបស់ខ្លួន?

**ចំលើយ:** X មិនចាំបាច់ប្រគល់ប័ណ្ណកម្មសិទ្ធិនៃដីរបស់ខ្លួនទៅឱ្យ Y ទេ ក្នុងករណីដែល X និង Y បានព្រមព្រៀងគ្នាថា ដី (L) ត្រូវដាក់ហ៊ីប៉ូតែក។

តើ X អាចរំពឹងថា ខ្ចីបានចំនួនប៉ុន្មានដែលសមរម្យតាមរយៈការដាក់ដី (L) ជាប្រាតិភោគ?

**ចំលើយ:** គឺក្រោមតំលៃ ៣ 000 ដូល្លារដែលជាតម្លៃនៃដី។

២- X និង Y បានព្រមព្រៀងគ្នាថា X ត្រូវដាក់ដី (L) ជាហ៊ីប៉ូតែក ហើយ Y ឱ្យ X ខ្ចីចំនួន១ 000ដូល្លារ។ បន្ទាប់មក X បានឱ្យដី (L) នោះ ទៅ Z ។ តើ Y អាចអនុវត្តសិទ្ធិហ៊ីប៉ូតែករបស់ខ្លួនបានដែរឬទេ? ប្រសិនបើមិនអាចតើ Y ត្រូវធ្វើយ៉ាងដូចម្តេច?

**ចំលើយ:** Y មិនអាចអនុវត្តសិទ្ធិហ៊ីប៉ូតែករបស់ខ្លួនចំពោះ Z បានទេ ពោលគឺ Y មិនអាចទាមទារដីនោះពី Z វិញ ដើម្បីយកមកលក់ឡាយឡុងសងបំណុលរបស់ខ្លួនបានទេ បើ Y មិនបានធ្វើជាលិខិតយថាភូត និង ចុះបញ្ជីនូវសិទ្ធិហ៊ីប៉ូតែករបស់ខ្លួនទេនោះ ពីព្រោះ Z គឺជាតតិយជន។ ហេតុនេះដើម្បីឱ្យអាចអនុវត្តសិទ្ធិហ៊ីប៉ូតែករបស់ខ្លួនបាន Y ត្រូវតែយកសិទ្ធិហ៊ីប៉ូតែករបស់ខ្លួនទៅចុះបញ្ជី បើមិនដូច្នេះទេ Y បានត្រឹមតែអាចដាក់ពាក្យបណ្តឹងធម្មតាដើម្បីឱ្យ X សងបំណុលរបស់ខ្លួនតែប៉ុណ្ណោះ។

៣- X បានយកដីទៅដាក់ហ៊ីប៉ូតែកដើម្បីធានាបំណុល ១ 000 ដូល្លារ។ ការដាក់ហ៊ីប៉ូតែកនេះត្រូវបានធ្វើឡើងដោយលិខិតយថាភូត និង បានចុះបញ្ជី។X ចង់លក់ដីនោះទៅឱ្យ Z ។ តើអាចលក់បានដែរឬទេ?

**ចំលើយ:** X អាចលក់ដីនោះបាន។ ប៉ុន្តែទោះបីជា X បានលក់ដីនោះទៅឱ្យ Z ហើយក៏ដោយ Z អាចធ្វើលទ្ធកម្មនូវដីនោះដោយមានជាប់បន្ទុកហ៊ីប៉ូតែក។ ហេតុដូច្នេះ តម្លៃលក់ដីនោះ ត្រូវទាបជាង ៣ 000 ដូល្លារ ដោយសារហានិភ័យដែល Y អាចអនុវត្តហ៊ីប៉ូតែករបស់គាត់។

## ៣- អានុភាពនៃហ៊ីប៉ូតែក

### ៣-១ ទំហំនៃអានុភាពហ៊ីប៉ូតែក

នៅពេលដែលហ៊ីប៉ូតែកមួយត្រូវបានបង្កើតឡើងនៅលើដីមួយកន្លែង ហ៊ីប៉ូតែកនោះមានអានុភាពលើវត្ថុដែលភ្ជាប់នឹង ដីនោះរួមទាំងអាគារ ដែលមាននៅលើដីដែលជាប់ហ៊ីប៉ូតែកនោះផងដែរ។ ទោះបីជាអាគារនោះត្រូវបានសង់នៅមុនពេល ឬ ក្រោយពេលបង្កើតហ៊ីប៉ូតែកក៏ដោយ ហើយដែលភាគីមិនអាចកំណត់នូវលក្ខខណ្ឌផ្សេងពីនេះ នៅក្នុងកិច្ចសន្យាហ៊ីប៉ូតែករបស់ខ្លួនបានឡើយ ( មាត្រា ៨៤៦ នៃក្រមរដ្ឋប្បវេណី) ។

ការកំណត់បែបនេះដោយហេតុថា យោងតាមមាត្រា ១២២ នៃក្រមរដ្ឋប្បវេណី វត្ថុដែលនៅជាប់នឹងដី ឬវត្ថុដែលក្លាយជាភាគមួយនៃដី ជាពិសេស អាគារ ឬ សំណង់ដែលសង់នៅលើដីហើយមិនអាចប្តូរកន្លែងបាន គឺជាសមាសភាគនៃដី។ ហេតុនេះនាំឱ្យសិទ្ធិហ៊ីប៉ូតែកដែលមាននៅលើដីមួយកន្លែង នឹងមានអានុភាពទៅលើអ្វីដែលជាសមាសភាគនៃដីនោះដែរ។

**ឧទាហរណ៍:**

លោក **ក** គឺជាម្ចាស់ដីមួយកន្លែង។ លោក **ក** បានសាងសង់អាគារមួយនៅលើដីនោះមុនការបង្កើតសិទ្ធិលើហ៊ីប៉ូតែក។ ក្រោយមក លោក **ក** បានបង្កើតសិទ្ធិហ៊ីប៉ូតែកនៅលើដីនោះ ទៅអោយលោក **ខ**។ ពេលនោះអានុភាពនៃហ៊ីប៉ូតែករបស់លោក **ខ** គឺមាននៅលើ ដី ផង និង អាគារផង។

សិទ្ធិហ៊ីប៉ូតែកនៅលើអចលនវត្ថុមួយកន្លែង មិនមានអានុភាពទៅលើផលដែលកើតចេញពីអចលនវត្ថុនោះទេ មិនថាជាផលស៊ីវិល ឬផលធម្មជាតិឡើយ។ ដោយសារតែហ៊ីប៉ូតែកត្រូវបានបង្កើតជាធ្នូរទៅនឹងតម្លៃនៅលើអចលនវត្ថុមួយដើម្បីធានាកាតព្វកិច្ច ប៉ុន្តែអ្នកបង្កើតហ៊ីប៉ូតែកនៅលើអចលនវត្ថុមួយ គឺនៅតែមានសិទ្ធិប្រើប្រាស់និងអាស្រ័យផល លើអចលនវត្ថុនោះដដែល ដូចនេះ ផលជាកម្មសិទ្ធិរបស់អ្នកធានាដោយវត្ថុ។ មានន័យថាទោះបីជាដី ឬ អាគារ ត្រូវបានដាក់ហ៊ីប៉ូតែកហើយក៏ដោយ ក៏ថ្លៃឈ្នួលដែលកើតចេញពីដី ឬអាគារនោះនៅតែជារបស់អ្នកធានាដោយវត្ថុដដែល។ ប៉ុន្តែ ក្នុងករណីដែលអចលនវត្ថុដែលជាប់ហ៊ីប៉ូតែកនោះត្រូវបានលក់ដោយការអនុវត្តហ៊ីប៉ូតែក អ្នកទិញនឹងធ្វើនូវលទ្ធកម្មកម្មសិទ្ធិពេញលេញ ហើយអ្នកបង្កើតហ៊ីប៉ូតែកនឹងត្រូវបាត់បង់កម្មសិទ្ធិលើអចលនវត្ថុដែលជាកម្មវត្ថុនៃហ៊ីប៉ូតែកនេះដែរ។ សិទ្ធិប្រើប្រាស់ និង អាស្រ័យផលលើអចលនវត្ថុរបស់អ្នកបង្កើតហ៊ីប៉ូតែកនោះក៏ត្រូវរលត់ដែរ។ ហេតុដូច្នេះហើយបានជាមាត្រា ៨៤៨ និង មាត្រា ៨៤៩ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណី ចែងថាហ៊ីប៉ូតែកនឹងមានអានុភាពចំពោះផល តែនៅពេលដែលអចលនវត្ថុជាប់ហ៊ីប៉ូតែកនោះត្រូវបានរឹបអូស ហើយ ម្ចាស់បំណុលហ៊ីប៉ូតែក អាចរឹបអូសផលនោះ។ ចំណែកនីតិវិធីអនុវត្តចំពោះផលក្រោយការរឹបអូសអចលនវត្ថុ មានចែងក្នុងក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៥១៦។

### ៣-២ ឧបាទេសកម្ម

ដូចដែលបានពន្យល់រួចមកហើយថា ហ៊ីប៉ូតែក គឺជាសិទ្ធិដើម្បីប្តូរនឹងតម្លៃនៃកម្មវត្ថុជាក់លាក់ណាមួយ។ ដូច្នេះ ម្ចាស់សិទ្ធិហ៊ីប៉ូតែក អាចអនុវត្តនូវសិទ្ធិហ៊ីប៉ូតែករបស់ខ្លួនចំពោះប្រាក់ ឬ វត្ថុផ្សេងដទៃទៀតដែលចេញមកអំពីមូលហេតុនៃការលក់ ឬ ការបាត់បង់ ឬ ការខូចខាត កម្មវត្ថុនៃហ៊ីប៉ូតែកនោះ ពីព្រោះថាហេតុទាំងនោះត្រូវបានចាត់ទុកជាការទទួលស្គាល់ ឬ បំផ្លែងនូវតម្លៃនៃអចលនវត្ថុដែលជាប់ហ៊ីប៉ូតែកនោះ។ ប៉ុន្តែម្ចាស់សិទ្ធិហ៊ីប៉ូតែកពុំអាចអនុវត្តហ៊ីប៉ូតែករបស់ខ្លួនបានឡើយ នៅក្រោយពេលដែលប្រាក់ត្រូវបានបង់ ឬ វត្ថុផ្សេងទៀតត្រូវបានប្រគល់ទៅឱ្យអ្នកបង្កើត។ ហេតុផលដែលមានការចែងយ៉ាងដូច្នេះ ដោយសារតែហ៊ីប៉ូតែកត្រូវបានបង្កើតឡើង និង អាចអនុវត្តបានតែចំពោះកម្មវត្ថុណាមួយជាក់លាក់តែប៉ុណ្ណោះ ប៉ុន្តែនៅក្រោយពេលដែលតំលៃដែលបានបំផ្លែង ឬ កើតចេញពីការលក់ ឬ បាត់បង់វត្ថុជាក់លាក់នោះត្រូវបានប្រគល់ទៅឱ្យអ្នកបង្កើតហ៊ីប៉ូតែកនោះហើយ ចាប់តាំងពីពេលនោះមកវា មិនអាចបែងចែកពីទ្រព្យសម្បត្តិផ្សេងទៀតបានទេ។ ហេតុនេះហ៊ីប៉ូតែក មិនអាចអនុវត្តចំពោះទ្រព្យនោះបានទៀតទេ។ ដូច្នេះ បើសិនជាម្ចាស់បំណុលចង់អនុវត្តសិទ្ធិហ៊ីប៉ូតែកតាមរយៈឧបាទេសកម្មលើវត្ថុ ម្ចាស់បំណុលហ៊ីប៉ូតែកត្រូវអនុវត្តឧបាទេសកម្មលើហ៊ីប៉ូតែករបស់ខ្លួនឱ្យបានមុនការប្រគល់ប្រាក់ ឬ វត្ថុដែលកើតចេញពីមូលហេតុនៃការលក់ ឬ ការបាត់បង់ ឬ ការខូចខាតចំពោះកម្មវត្ថុនោះទៅឱ្យកូនបំណុលហ៊ីប៉ូតែក។

**ឧទាហរណ៍:**

លោក **ក** បានបង្កើតសិទ្ធិហ៊ីប៉ូតែកនៅលើអាគារមួយកន្លែងរបស់ខ្លួនទៅឱ្យលោក **ខ** ដើម្បីធានាបំណុលរបស់ខ្លួនចំនួន ១០ ០០០ ដុល្លារ។ ប៉ុន្តែ លោក **គ** បានធ្វើឱ្យអាគារនោះឆេះ។ ដូចនេះ លោក **ខ** ដែលជាម្ចាស់បំណុលហ៊ីប៉ូតែកអាចប្តឹងទាមទារប្រាក់ដែលជាថ្លៃសំណងខូចខាតអាគារពីលោក **គ** បានតាមរយៈឧបាទេសកម្មលើវត្ថុនៃម្ចាស់សិទ្ធិហ៊ីប៉ូតែកលើវត្ថុនោះ។ តែបើលោក **គ** បានផ្តល់ប្រាក់សំណងខូចខាតនៃអាគារនោះទៅឱ្យលោក **ក** រួចហើយ លោក **ខ** មិនអាចប្តឹងទាមទារប្រាក់ពីលោក **ក** តាមរយៈឧបាទេសកម្មលើវត្ថុបានទៀតទេ ពីព្រោះថាប្រាក់ដែលជាសំណងថ្លៃខូចខាតអាគារដែលលោក **ក** ទទួលបាននោះក្លាយទៅជាទ្រព្យទូទៅរបស់លោក **ក** ហើយ។ តែ លោក **ខ** នៅតែអាចទាមទារប្រាក់ជំពាក់ពីលោក **ក** ជាម្ចាស់បំណុលធម្មតាបាន។

### ៣-៣ សិទ្ធិទាមទារសំណងរបស់អ្នកធានាដោយវត្ថុ

ប្រសិនបើអ្នកដែលបានបង្កើតហ៊ីប៉ូតែកដើម្បីធានាកាតព្វកិច្ចរបស់អ្នកដទៃ បានសងចំពោះកាតព្វកិច្ចនោះ ឬបានបាត់បង់នូវកម្មសិទ្ធិលើដីហ៊ីប៉ូតែកដោយសារការអនុវត្តហ៊ីប៉ូតែកនោះ អ្នកនោះត្រូវមានសិទ្ធិទាមទារសំណងពីកូនបំណុលដោយយោងទៅតាមបញ្ញត្តិស្តីពីការធានា ( មាត្រា ៨៥០ នៃក្រមរដ្ឋប្បវេណី)។ បញ្ញត្តិនេះ ឆ្លើយតប

ទៅនឹងមាត្រា ៩១១ និងបញ្ញត្តិមាត្រាដែលទាក់ទងមួយចំនួនទៀតផ្សេងទៀតនៃក្រមរដ្ឋប្បវេណី ។

<u>**ឧទាហរណ៍**</u>

X គឺជាកូនបំណុលដែលបានជំពាក់ប្រាក់គេចំនួន ១ 000 ដុល្លារ ។ Y គឺជាម្ចាស់បំណុលហ៊ីប៉ូតែក ហើយ Z គឺជាអ្នកធានាដោយវត្ថុដែលបានធានាបំណុលចំនួន ១ 000 ដុល្លារនេះ ។

Y អនុវត្តហ៊ីប៉ូតែករបស់ខ្លួន ហើយបានទទួលនូវការសងគ្រប់ចំនួនហើយ Z បានបាត់បង់នូវកម្មសិទ្ធិរបស់ខ្លួន (អ្នកផ្សេងទទួលកម្មសិទ្ធិនោះ) ។

នៅក្នុងករណីនេះ Z ទទួលនូវសិទ្ធិទាមទារសំណងចំនួន ១ 000 ដុល្លារពី X ។

**ចំណុចខុសប្លែកគ្នារវាង អ្នកធានាដោយវត្ថុ និង អ្នកធានាធម្មតា**

ភាពខុសប្លែកគ្នាដ៏សំខាន់រវាងសិទ្ធិ និង កាតព្វកិច្ចរបស់អ្នកធានាដោយវត្ថុ និង អ្នកធានា មានពីរ ។ ទី ១ គឺ អ្នកធានាមានករណីយកិច្ច រីឯអ្នកធានាដោយវត្ថុវិញមិនមានករណីយកិច្ចទេ ហើយមួយទៀតគឺ អ្នកធានាទទួលខុសត្រូវចំពោះរាល់ចំនួនប្រាក់ធានា ចំណែកឯការទទួលខុសត្រូវរបស់អ្នកធានាដោយវត្ថុវិញ ត្រូវបានកំរិតត្រឹមតែការបាត់បង់នូវវត្ថុដែលត្រូវបានដាក់ធានាតែប៉ុណ្ណោះ សូមពិនិត្យមើលឧទាហរណ៍ដូចខាងក្រោមនេះ:

លោក **ក** ជាម្ចាស់បំណុល ហើយលោក **ខ** ជាកូនបំណុល ។ លោក **គ** មានអចលនវត្ថុមួយកន្លែងហើយបានយកអចលនវត្ថុនោះទៅដាក់ហ៊ីប៉ូតែកដើម្បីធានាបំណុលឱ្យលោក **ខ** ។ ពេលនោះ គេហៅលោក **គ** ថាជាអ្នកធានាដោយវត្ថុនៅក្នុងករណីនេះ ។ លោក **គ** មានឋានៈស្រដៀងគ្នានឹងអ្នកធានាដែរ តែខុសគ្នាត្រង់ថា លោក **ក** ដែលជាម្ចាស់បំណុលហ៊ីប៉ូតែក មានសិទ្ធិត្រឹមតែទាមទារឱ្យលោក **ខ** ដែលជាកូនបំណុល សងបំណុលមកខ្លួន មិនមែនទាមទារឱ្យលោក **គ** សងទេ ។ បើ លោក **ខ** សងបំណុលទៅលោក **ក** ហើយ លោក **ក** មិនអាចអនុវត្តសិទ្ធិហ៊ីប៉ូតែករបស់ខ្លួនបានទៀតទេ ។ តែបើលោក **ខ** មិនអាចសងបំណុលទៅលោក **ក** បានទេ អចលនវត្ថុរបស់លោក **គ** នឹងត្រូវបានរឹបអូសដោយលោក **ក** ។

ចំណុចដែលខុសគ្នាពី កិច្ចធានា គឺនៅត្រង់ថា បើសិនជាលោក **គ** គឺជាអ្នកធានា លោក **ក** ដែលជាម្ចាស់បំណុល មានសិទ្ធិលើបំណុលចំពោះលោក **ខ** ផង និង លោក **គ** ផង ។ មានន័យថា លោក **ក** មានសិទ្ធិទាមទារឱ្យលោក **ខ** សងក៏បាន លោក **គ** សងក៏បាន ។

## ៣-៩ លំដាប់នៃហ៊ីប៉ូតែក

ដូចដែលបានលើកឡើងពីខាងដើមហើយថា កូនបំណុលអាចបង្កើតសិទ្ធិហ៊ីប៉ូតែកលើទ្រព្យតែមួយទៅឱ្យម្ចាស់បំណុលច្រើនគ្នា ដែលនេះជាចំណុចមួយដែលមានប្រយោជន៍ បំផុតនៅក្នុងចំណោមចំណុចជាច្រើន បើប្រៀបធៀបទៅនឹងការធានា ។

យោងតាមមាត្រា ៨៥១ នៃក្រមរដ្ឋប្បវេណី បានចែងថាក្នុងករណីដែលបានបង្កើតហ៊ីប៉ូតែកនៅលើ

អចលនវត្ថុតែមួយដើម្បីធានាសិទ្ធិលើបំណុលច្រើន លំដាប់នៃហ៊ីប៉ូតែកនោះ ត្រូវអនុលោមតាមពេលវេលាដែលបានចុះបញ្ជី ។

ក្នុងការអនុវត្តហ៊ីប៉ូតែកចំពោះអចលនវត្ថុនេះដែរ មានបញ្ញត្តិមួយចំនួនដែលមានចែងនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ដែលមានការពាក់ពន្ធ័យ៉ាងជិតស្និតទៅនឹងប្រធានបទនេះដែលនឹងត្រូវលើកយកមកអធិប្បាយនៅពេលនេះទោះបីជាយើងកំពុងសិក្សាពីច្បាប់សារធាតុក៏ដោយ ។ នីតិវិធីនៃការអនុវត្តនេះដើម្បីដោះស្រាយនូវវិវាទរវាងហ៊ីប៉ូតែកច្រើន ឬ វិវាទនានារវាងហ៊ីប៉ូតែកជាមួយនឹងម្ចាស់សិទ្ធិប្រត្យក្ស ឬ សិទ្ធិប្រាតិភោគប្រតក្សផ្សេងទៀតនៅលើអចលនវត្ថុតែមួយដែលជាកម្មវត្ថុនៃការអនុវត្តហ៊ីប៉ូតែក នោះ។ ចំនុចទាំងនេះនឹងត្រូវលើកយកមកបង្ហាញដូចខាងក្រោមនេះ:

ជាគោលការណ៍ការអនុវត្តសិទ្ធិប្រាតិភោគប្រត្យក្ស គឺធ្វើឡើងតាមវិធីលក់ដោយបង្ខំដើម្បីទទួលសំណងជាអាទិភាពពីប្រាក់ដែលបានមកពីការលក់នេះ។ តើសិទ្ធិប្រាតិភោគប្រត្យក្សផ្សេងដទៃទៀតក្រៅពីសិទ្ធិប្រាតិភោគប្រត្យក្សដែលត្រូវបានអនុវត្តលើអចលនវត្ថុនោះ ដូចជាហ៊ីប៉ូតែក នឹងត្រូវរលត់ក្រោយការលក់ឬយ៉ាងណា? យោងតាមមាត្រា៥១០ កថាខណ្ឌទី ១ និង ទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី *សិទ្ធិប្រាតិភោគប្រត្យក្សលើអចលនវត្ថុ សិទ្ធិប្រត្យក្សប្រើប្រាស់និងអាស្រ័យផលលើអចលនវត្ថុ និង សិទ្ធិជួលអចលនវត្ថុដែលអាចតតាំងនឹងសិទ្ធិប្រាតិភោគរបស់ម្ចាស់បំណុលនៃការអនុវត្ត ត្រូវបន្តអត្ថិភាពក្រោយការលក់ដោយបង្ខំដែលជាការអនុវត្តសិទ្ធិប្រាតិភោគ។ ក្រៅពីសិទ្ធិដែលបានកំណត់ខាងលើនេះ សិទ្ធិលើអចលនវត្ថុត្រូវរលត់ ដោយការលក់ ។*

តាមរយៈមាត្រានេះយើងឃើញថា បើពាក្យសុំឱ្យចាប់ផ្តើមនីតិវិធីអនុវត្តសិទ្ធិប្រាតិភោគប្រត្យក្ស ត្រូវធ្វើឡើងដោយម្ចាស់បំណុល ដែលមានសិទ្ធិប្រាតិភោគប្រត្យក្សណាមួយមុននោះ សិទ្ធិប្រត្យក្សផ្សេងៗទៀត រួមទាំងសិទ្ធិប្រាតិភោគប្រត្យក្សផងដែរ ដែលចិតនៅក្នុងលំដាប់អាទិភាពខ្ពស់ជាងម្ចាស់សិទ្ធិប្រាតិភោគប្រត្យក្សដែលដាក់ពាក្យសុំអនុវត្តមុននោះ មិនរលត់ដោយនីតិវិធីអនុវត្តទេ (មាត្រា ៥១០ កថាខណ្ឌទី ១ ) ផ្ទុយទៅវិញបើសិទ្ធិប្រត្យក្ស ឬ សិទ្ធិប្រាតិភោគប្រត្យក្សផ្សេងៗនោះមានលំដាប់អាទិភាពទាបជាងសិទ្ធិប្រាតិភោគប្រត្យក្សដែលដាក់ពាក្យសុំអនុវត្តមុននោះ ពេលនោះសិទ្ធិប្រត្យក្ស ឬ សិទ្ធិប្រាតិភោគប្រត្យក្សលើអចលនវត្ថុនោះត្រូវរលត់ដោយការអនុវត្ត ( មាត្រា ៥១០ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ។

**ឧទាហរណ៍:**

លោក **ក** លោក **ខ** និង លោក **គ** សុទ្ធតែជាម្ចាស់បំណុលហ៊ីប៉ូតែក នៅលើដីមួយកន្លែង។ លោក **ក** ជាម្ចាស់បំណុលហ៊ីប៉ូតែក លំដាប់ទី ១។ លោក **ខ** ជាម្ចាស់បំណុលហ៊ីប៉ូតែក លំដាប់ទី ២។ លោក **គ** ជាម្ចាស់បំណុលហ៊ីប៉ូតែកលំដាប់ទី ៣។ បើសិនជា លោក **ក** ដាក់ពាក្យសុំអនុវត្តហ៊ីប៉ូតែករបស់ខ្លួន មុននោះ ពេលនោះ លោក **ខ** និង លោក **គ** អាចចូលរួមចែកចំណែកដែរ។ តែបើសិនជាលោក **ខ** ឬ លោក **គ** ដាក់ពាក្យសុំអនុវត្តមុននោះ ពេលនោះ លោក **ក** មិនអាចចូលរួមក្នុងការចែកចំណែកទេ។ ព្រោះសិទ្ធិហ៊ីប៉ូតែករបស់លោក **ក** មិនរលត់

ទេ។ លោក ក នៅតែអាចដាក់ពាក្យសុំអនុវត្តហ៊ីប៉ូតែក របស់ខ្លួនពីតតិយជនដែលបានធ្វើលទ្ធកម្មលើដីនោះ តាមរយៈការលក់ដោយបង្ខំដដែល ។

ដូច្នេះ នៅក្នុងក្រមរដ្ឋប្បវេណីកម្ពុជាបានអនុម័តយកគោលការណ៍ទទួលបន្តចំពោះ សិទ្ធិប្រាតិភោគប្រត្យក្ស មានន័យថាកំណត់ឱ្យអ្នកទិញនូវអចលនវត្ថុនៃការអនុវត្តទទួលបន្តនូវបន្ទុកទាំងឡាយដែលមានលើអចលនវត្ថុនោះ ក្រោយពេលអនុវត្តដោយបង្ខំ ។ គោលការណ៍នេះយកចិត្តទុកដាក់ លើការការពារអ្នកដែលមានសិទ្ធិប្រាតិភោគប្រត្យក្សលើអចលនវត្ថុ។ គោលការណ៍ទទួលបន្តចំពោះសិទ្ធិប្រាតិភោគប្រត្យក្សនេះដែរ អ្នកទិញអាចទិញអចលនវត្ថុក្នុងតម្លៃមួយ ថោកជាងតម្លៃពិតប្រាកដនៃអចលនវត្ថុនោះដោយគ្មានជាប់បន្ទុកសិទ្ធិប្រត្យក្ស ឬ សិទ្ធិប្រាតិភោគប្រត្យក្សផ្សេងទៀតនោះទេ ដោយសារខ្លួនត្រូវទទួលបន្តនូវបន្ទុកនៃកាតព្វកិច្ចដែលត្រូវធានាដោយសិទ្ធិប្រាតិភោគប្រត្យក្សជាលក្ខខណ្ឌមូលដ្ឋាន ។

ព្រមជាមួយគ្នានេះដែរ មាត្រា៤៤៩ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី បានចែងថាអ្នកទិញត្រូវទទួលខុសត្រូវ សងនូវសិទ្ធិលើបំណុលដែលត្រូវបានធានាដោយសិទ្ធិប្រាតិភោគ ដែលអ្នកទិញបានទទួលបន្ត ។

ហើយអ្វីដែលគួរឱ្យកត់សំគាល់នោះ គឺថា ម្ចាស់សិទ្ធិហ៊ីប៉ូតែកដែលចិតក្នុងលំដាប់ទី ១ អាចទទួលនូវការសងដោយមានអាទិភាពជាងម្ចាស់បំណុលហ៊ីប៉ូតែកដែលចិតក្នុងលំដាប់បន្ទាប់ ។ ជាទូទៅ ម្ចាស់បំណុលផ្សេងទៀតគឺមិនទទួលបានសូម្បីតែសំណង ។

**<u>ករណីសិក្សា:</u>**

X គឺជាម្ចាស់សិទ្ធិហ៊ីប៉ូតែកលំដាប់ទី ១ ធានា ដោយប្រាក់ចំនួន ៤០០ ដុល្លាររបស់ A ។

Y គឺជាម្ចាស់សិទ្ធិហ៊ីប៉ូតែកលំដាប់ទី ២ ធានា ដោយប្រាក់ចំនួន ៣០០ ដុល្លាររបស់ A ។

Z គឺជាម្ចាស់សិទ្ធិហ៊ីប៉ូតែកលំដាប់ទី ៣ ធានា ដោយប្រាក់ចំនួន ២០០ ដុល្លាររបស់ A ។

កម្មវត្ថុនៃសិទ្ធិហ៊ីប៉ូតែកគឺដី (L) ដែលជាកម្មសិទ្ធិរបស់ A ។

១-១ X បានដាក់ពាក្យសុំអនុវត្តហ៊ីប៉ូតែករបស់ខ្លួន។ ដី (L) ត្រូវបានលក់នៅក្នុងតម្លៃ ៦០០ ដុល្លារ ។

តើនរណាត្រូវទទួលប្រាក់ដែលបានមកពីការលក់នោះ តើត្រូវទទួលចំនួនប៉ុន្មាន? តើសិទ្ធិណាខ្លះដែលត្រូវបន្តអត្ថិភាពហើយសិទ្ធិណាខ្លះដែលត្រូវរលត់?

**ចំលើយ :** តាមរយៈការដាក់ពាក្យសុំឱ្យអនុវត្តរបស់ X ហ៊ីប៉ូតែករបស់ X និង ហ៊ីប៉ូតែកដែលស្ថិតនៅលំដាប់ទាបជាង នឹងត្រូវរលត់។ បន្ទាប់មកប្រាក់ដែលបានមកពីការលក់ដោយបង្ខំចំនួន ៤០០ ដុល្លារនឹងត្រូវចែងទៅឱ្យ X ហើយប្រាក់ដែលនៅសល់ចំនួន ២០០ ដុល្លារ នឹងត្រូវចែកទៅឱ្យ Y ប៉ុន្តែមិនមែនចែកទៅឱ្យ Z នោះទេ។ ការចែកចំណែក ត្រូវចែកឱ្យគ្រប់ចំនួននៃសិទ្ធិលើបំណុលទាំងអស់របស់ X ហើយផ្នែកនៃសិទ្ធិលើបំណុលរបស់ Y ។

ចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលដែលនៅសល់របស់ Y គឺមានចំនួន ១០០ ដូល្លារ ហើយ Z នៅសល់ចំនួន ២០០ ដូល្លារ ។

១-២ តើយ៉ាងម៉េចទៅវិញប្រសិនបើថ្លៃលក់មានចំនួន ២ ០០០ ដូល្លារ?

ហ៊ីប៉ូតែកទាំងអស់នឹងត្រូវរលត់ ។ ប្រាក់ដែលបានមកពីការលក់ត្រូវចែកទៅឱ្យម្ចាស់បំណុលទាំងអស់ ពីព្រោះទឹកប្រាក់ មានចំនួនគ្រប់គ្រាន់ដើម្បីសងសិទ្ធិលើបំណុលទាំងអស់ ។ ហើយបន្ទាប់មកទៀត ប្រាក់ដែលនៅសល់ចំនួន ១១០០ ត្រូវចែកទៅឱ្យ A ។ គ្មានសិទ្ធិលើបំណុលណាមួយត្រូវបន្តអត្ថិភាពនោះទេ ដោយសារតែការចែកចំណែកគ្រប់ចំនួន ។

២- Y បានដាក់ពាក្យសុំអនុវត្តហ៊ីប៉ូតែករបស់ខ្លួន ។ ដី (L) ត្រូវបានលក់ក្នុងតម្លៃ ៦០០ ដូល្លារ ។ តើនរណាត្រូវទទួលប្រាក់ដែលបានមកពីការលក់នេះ ហើយត្រូវទទួលបានចំនួនប៉ុន្មាន? តើសិទ្ធិណាខ្លះដែលត្រូវបន្តអត្ថិភាព និងសិទ្ធិណាខ្លះត្រូវរលត់?

**ចំលើយ :** ការដាក់ពាក្យសុំឱ្យអនុវត្តរបស់ Y នឹងធ្វើឱ្យហ៊ីប៉ូតែករបស់គាត់ និង ហ៊ីប៉ូតែករបស់ Z រលត់ ពីព្រោះហ៊ីប៉ូតែករបស់ Z ស្ថិតនៅលំដាប់ទាបជាងហ៊ីប៉ូតែករបស់ Y ប៉ុន្តែការដាក់ពាក្យសុំអនុវត្តរបស់ Y នេះនឹងមិនធ្វើឱ្យហ៊ីប៉ូតែករបស់ X រលត់នោះទេ ។ Y នឹងទទួលបានប្រាក់ចំនួន ៣០០ ដូល្លារមុនគេ ហើយបន្ទាប់មក Z នឹងទទួលបាន ២០០ ដូល្លារ ហើយប្រាក់នៅសល់ចំនួន ១០០ ដូល្លារនឹងត្រូវបានទៅ A ។ សិទ្ធិលើបំណុល និង ហ៊ីប៉ូតែករបស់ X នឹងបន្តអត្ថិភាព ។

៣- Z បានដាក់ពាក្យសុំអនុវត្តហ៊ីប៉ូតែករបស់ខ្លួន ។ ដី (L) ត្រូវបានលក់ក្នុងតម្លៃ ៦០០ ដូល្លារ ។ តើនរណាត្រូវទទួលប្រាក់ដែលបានមកពីការលក់នោះ តើត្រូវទទួលចំនួនប៉ុន្មាន? តើសិទ្ធិណាខ្លះដែលត្រូវបន្តអត្ថិភាព ហើយសិទ្ធិណាខ្លះដែលត្រូវរលត់?

ការដាក់ពាក្យសុំឱ្យអនុវត្តរបស់ Z នឹងធ្វើឱ្យតែហ៊ីប៉ូតែករបស់គាត់រលត់តែប៉ុណ្ណោះ ពីព្រោះហ៊ីប៉ូតែកពីរផ្សេងទៀតស្ថិតនៅក្នុងលំដាប់ខ្ពស់ជាងហ៊ីប៉ូតែករបស់ Z ។ បន្ទាប់មក ប្រាក់ចំនួន ២០០ ដូល្លារនឹងចែកឱ្យទៅ Z ហើយប្រាក់ដែលនៅសល់ចំនួន ៤០០ ដូល្លារទៀតនឹងបានទៅ A ។ សិទ្ធិលើបំណុល និង ហ៊ីប៉ូតែករបស់ X និង Y នឹងបន្តអត្ថិភាព ។

រឿងក្តីខាងក្រោមនេះ គឺឯករាជ្យពីរឿងក្តីខាងលើ ។

X គឺជាម្ចាស់សិទ្ធិហ៊ីប៉ូតែកលំដាប់ទី ១ ដែលបានធានាចំនួន ៤០០ ដូល្លារ ។

Y គឺជាម្ចាស់សិទ្ធិហ៊ីប៉ូតែកលំដាប់ទី ២ ដែលបានធានាចំនួន ៣០០ ដូល្លារ ។

កម្មវត្ថុនៃសិទ្ធិហ៊ីប៉ូតែកទាំងនេះ គឺ ដី (L) ដែលជាកម្មសិទ្ធិរបស់ A ។ ផ្អែកលើការពិនិត្យរបស់ Z តម្លៃនៃដី (L) គឺមានតម្លៃ ១ ០០០ ដូល្លារ តើ A រំពឹងថានឹងអាចខ្ចីប្រាក់ពី Z បានចំនួនប៉ុន្មាន តាមរយៈការយកដី (L) នោះមកដាក់ជាប្រាតិភោគ?

**ចំលើយ :** ប្រសិនបើ តម្លៃនៃដីដែលត្រូវបានប៉ាន់ប្រមាណទៅគឺមានចំនួន ១ ០០០ ដូល្លារ Z អាចរំពឹងទទួលបានប្រាក់ចំនួន ៣០០ ដូល្លារពីដី L ពីព្រោះថា តម្លៃចំនួន ៧០០ ដូល្លារ ត្រូវបានដាក់ជាប្រាតិភោគ

រួចហើយ ។ ហេតុដូច្នេះ ក្នុងករណីប្រសិនបើ មិនគិតពីការប្រាក់ទេ Z អាចឱ្យ A ខ្ចីច្រើនបំផុតត្រឹមចំនួន ៣០០ ដុល្លារ ។

### ៣-៥ ទំហំនៃសិទ្ធិលើបំណុលដែលត្រូវធានា

យោងតាមមាត្រា ៨៥២ កថាខណ្ឌទី ១ និង ទី ២ ក្នុងករណីដែលម្ចាស់បំណុលហ៊ីប៉ូតែកមានសិទ្ធិទាមទារការប្រាក់ ឬ ធនលាភផ្សេងទៀត ម្ចាស់បំណុលហ៊ីប៉ូតែកអាចអនុវត្តហ៊ីប៉ូតែកនោះបានតែចំពោះចំនួននៃការសងដែលដល់កំណត់ពេលសម្រាប់អំឡុងពេល ២ (ពីរ) ឆ្នាំចុងក្រោយតែប៉ុណ្ណោះ ។ ប៉ុន្តែចំពោះធនលាភដែលមានពីមុនមកប្រសិនបើបានចុះបញ្ជីពិសេស ក្រោយពីបានដល់ពេលកំណត់ត្រូវសងហ៊ីប៉ូតែកនេះអាចអនុវត្តបានចាប់ពីពេលដែលបានចុះបញ្ជីនោះ ។ មាត្រា ៨៥២ កថាខណ្ឌទី ១ ក៏ត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះប្រាក់ដែលត្រូវបង់សម្រាប់អំឡុង ពេល ២ (ពីរ) ឆ្នាំចុងក្រោយ ក្នុងករណីដែលម្ចាស់បំណុលហ៊ីប៉ូតែកមានសិទ្ធិទាមទារឱ្យសងសំណងនៃការខូចខាត ដែលបានកើតឡើងដោយការមិនអនុវត្តកាតព្វកិច្ច ។ ប៉ុន្តែក្នុងករណីនេះ ចំនួនសរុបនៃសំណងការខូចខាតព្រមទាំងការប្រាក់ និងធនលាភផ្សេងទៀត មិនអាចលើសចំនួនសរុបសម្រាប់អំឡុងពេល ២ (ពីរ) ឆ្នាំបានឡើយ ។

បានជាច្បាប់មានការកំណត់ដូច្នេះ ពីព្រោះវាមានភាពចាំបាច់សំរាប់ការពារម្ចាស់បំណុលហ៊ីប៉ូតែកដទៃផ្សេងទៀតដែលស្ថិតនៅក្នុងលំដាប់ទាបជាង ដើម្បីឱ្យដឹងថាតើតម្លៃនៃអចលនវត្ថុដែលត្រូវបានយកមកដាក់ជាប្រាតិភោគ នោះមានចំនួនប៉ុន្មាន ។

**ឧទាហរណ៍**

លោក ក បានយកដីរបស់ខ្លួនមួយកន្លែងដែលមានតម្លៃចំនួន ២ ០០០ ដុល្លារទៅដាក់ហ៊ីប៉ូតែកឱ្យលោក ខ ដើម្បីធានាបំណុលចំនួន ១០០០ ដុល្លា នៅថ្ងៃទី ០៦ ខែ ០៧ ឆ្នាំ ២០០៦ ដោយយកការប្រាក់ ១០ ភាគរយក្នុងមួយឆ្នាំ។ ការប្រាក់នៃការយឺតយ៉ាវ គឺ ២០ ភាគរយ។ កាលបរិច្ឆេទដែលត្រូវសងនៅថ្ងៃទី ០៦ ខែ ០៧ ឆ្នាំ ២០១១។ លោក ក ចង់ខ្ចីប្រាក់ពីលោក គ បន្ថែមទៀត។ ឧទាហរណ៍ថ្ងៃនេះ គឺជាថ្ងៃទី ថ្ងៃទី ០៦ ខែ ០៧ ឆ្នាំ ២០១៥។ ដូច្នេះរយៈពេល ២ ឆ្នាំ ចុងក្រោយដែលត្រូវយកមកគណនាគឺនៅឆ្នាំ ២០១៣។ ហេតុដូច្នេះ ខ អាចទទួលបានប្រាក់ចំនួនច្រើនបំផុត ១ ៤០០ ដុល្លារពីហ៊ីប៉ូតែក ដូច្នេះ គ ត្រូវឱ្យខ្ចីច្រើនបំផុតនោះចំនួន ៦០០ ដុល្លារ (ករណីប្រសិនបើ គ គិតការប្រាក់ គ ត្រូវឱ្យខ្ចីតិចជាងចំនួន ៦០០ ដុល្លារ) ។

**ឧទាហរណ៍**

លោក ក គឺជាកូនបំណុលដែលមានដីមួយកន្លែងតំលៃ ៥០០ ដុល្លា។ លោក ក បានយកដីនោះទៅដាក់ហ៊ីប៉ូតែកឱ្យលោក ខ ដើម្បីធានាបំណុលរយៈពេលពីឆ្នាំ ២០០១ ដល់ឆ្នាំ ២០១១ ចំនួន ១០០ ដុល្លាដោយយកការប្រាក់ ១០ ភាគរយក្នុងមួយឆ្នាំ ។ លោក ក ក៏បានខ្ចីប្រាក់ពីលោក គ ដែរ ដោយយកដីដដែលនោះទៅដាក់ហ៊ីប៉ូតែកឱ្យលោក គ ដើម្បីធានាបំណុលរយៈពេល ពីឆ្នាំ ២០០៥ ដល់ឆ្នាំ ២០១១ ចំនួន ២០០ ដុល្លា ដោយមានការប្រាក់ ១០ ភាគរយក្នុងមួយឆ្នាំដូចគ្នា។ លោក ក មិនបានបង់ការប្រាក់ឱ្យលោក ខ ចំនួន ៥ ឆ្នាំ ស្មើនឹងទឹក

ប្រាក់ចំនួន ៥០ ដុល្លា។ លោក **ក** ក៏មិនបានបង់ការប្រាក់ឱ្យលោក **ឥ** ចំនួន ៥ ឆ្នាំដែរ ស្មើនឹងទឹកប្រាក់ចំនួន ១០០ ដុល្លា។ សន្មត់ថាដីនោះលក់បានតំលៃ ៥០០ ដុល្លា។

នៅក្នុងករណីនេះ តាមរយៈការដាក់ពាក្យសុំឱ្យអនុវត្តហ៊ីប៉ូតែករបស់ **ខ** , **ខ** ទទួល = ១០០ + ( ១០០ x ការប្រាក់ ១០ % x ២ ឆ្នាំ ) = ១២០ ដុល្លារ។

លោក **ឥ** ទទួល = ២០០ + (២០០ x ការប្រាក់ ១០ % x ២ ឆ្នាំ) = ២៤០ ដុល្លារ។

សូមកត់សំគាល់ថា លោក **ក** នៅតែជំពាក់ការប្រាក់លោក **ខ** ចំនួន ៣០ ដុល្លារ និង លោក **ឥ** ចំនួន ៦០ ដុល្លារ។ លោក **ខ** និង លោក **ឥ** នៅតែអាចទាមទារការប្រាក់នេះពីលោក **ក** ក្នុងនាមជាម្ចាស់សិទ្ធិលើបំណុល ប៉ុន្តែមិនអាចទាមទារក្នុងនាមជាម្ចាស់បំណុលហ៊ីប៉ូតែកបានទេពាក់ព័ន្ធនឹងចំនួនទឹកប្រាក់ដែលនៅសល់។

## ៤- ការអនុវត្តហ៊ីប៉ូតែក

យោងតាមបញ្ញត្តិដែលកំណត់ក្នុងក្រមរដ្ឋប្បវេណី បើកូនបំណុលហ៊ីប៉ូតែកមិនបានអនុវត្តកាតព្វកិច្ចរបស់ខ្លួនទេ ម្ចាស់បំណុលហ៊ីប៉ូតែកអាចអនុវត្តហ៊ីប៉ូតែករបស់ខ្លួនតាមរយៈការដាក់ពាក្យសុំឱ្យលក់ដោយបង្ខំនូវអចលនវត្ថុហ៊ីប៉ូតែកទៅតុលាការ។ និយាយម្យ៉ាងទៀត ម្ចាស់បំណុលហ៊ីប៉ូតែកមិនអាចអនុវត្តសិទ្ធិហ៊ីប៉ូតែករបស់ខ្លួនបានឡើយ ក្នុងករណីប្រសិនបើ កាតព្វកិច្ចត្រូវបានអនុវត្ត (មាត្រា ៨៩៣ នៃក្រមរដ្ឋប្បវេណី)។

ចំពោះនីតិវិធី នៃការអនុវត្តហ៊ីប៉ូតែក គឺមានចែងនៅក្នុង ក្រមនីតិវិធីរដ្ឋប្បវេណី។

**ឧទាហរណ៍:**

លោក **ខ** គឺជាម្ចាស់បំណុលហ៊ីប៉ូតែកចំនួន ១ ០០០ ដុល្លា នៅលើដី L មួយកន្លែងរបស់លោក **ក**។ បើដល់ពេលកំណត់សងហើយ លោក **ក** មិនមានប្រាក់សងទេនោះ លោក **ខ** អាចដាក់ពាក្យសុំឱ្យលក់ដោយបង្ខំ។ សន្មត់ថាអចលនវត្ថុ L នោះលក់បានតំលៃ ១២០០ ដុល្លា។ ដូចនេះ ថ្លៃដែលលក់ចំនួន ១០០០ ដុល្លា ត្រូវយកទៅសងម្ចាស់បំណុលដែលជាលោក **ខ**។ តែបើដីនោះលក់បានតែ ៨០០ ដុល្លា នោះ លោក **ក** នៅជំពាក់លោក **ខ** ចំនួន ២០០ ដុល្លាទៀត។ បំណុលដែលនៅសល់ចំនួន ២០០ ដុល្លានេះ លោក **ខ** នៅតែមានសិទ្ធិទាមទារពីលោក **ក** ដដែល តែមិនមែនទាមទារក្នុងនាមជាម្ចាស់បំណុលហ៊ីប៉ូតែកទៀតទេ ព្រោះសិទ្ធិហ៊ីប៉ូតែករបស់លោក **ខ** ត្រូវបានរលត់ដោយការលក់អចលនវត្ថុហ៊ីប៉ូតែកនោះទៅតាមនីតិវិធីអនុវត្តដោយបង្ខំរបស់តុលាការហើយ។ ដូចនេះ សិទ្ធិទាមទារបំណុលដែលនៅសល់របស់លោក **ខ** នេះគឺជាសិទ្ធិទាមទារបំណុលធម្មតា។

### ៤-១ អ្នកទិញ

ពាក់ពន្ធ័នឹងការអនុវត្តហ៊ីប៉ូតែកនេះដែរ មានចំនុចមួយចំនួនដែលអ្នកដាក់ពាក្យសុំអនុវត្តគួរយល់ដឹងៈ

ក-កូនបំណុលមិនអាចក្លាយជាអ្នកទិញអចលនវត្ថុដែលខ្លួនបានដាក់ហ៊ីប៉ូតែកទេ ពីព្រោះថាបើកូនបំណុលមានលុយដល់ទៅទិញអចលនវត្ថុដែលជាប់ហ៊ីប៉ូតែកនោះ គាត់គួរតែសងបំណុលទៅម្ចាស់បំណុលវិញ ហើយវាប្រសើរជាងការខាតបង់ពេលវេលា និងសោហ៊ុយចំណាយទៅលើការអនុវត្តហ៊ីប៉ូតែកនោះ ( មាត្រា ៤៣៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ។

ខ-ផ្ទុយទៅវិញម្ចាស់បំណុលហ៊ីប៉ូតែក ឬ អ្នកធានាដោយវត្ថុ អាចទិញអចលនវត្ថុដែលដាក់ហ៊ីប៉ូតែកនោះបាន ពីព្រោះពុំមានបទប្បញ្ញត្តិណាមួយ ដែលហាមឃាត់ម្ចាស់បំណុលហ៊ីប៉ូតែក ឬអ្នកធានាដោយវត្ថុមិនឱ្យទិញនោះទេ ជាទូទៅ ។

គ-បើសិនជាតំលៃដែលបានមកពីការលក់អចលនវត្ថុនោះ មិនគ្រប់គ្រាន់សំរាប់សោហ៊ុយនីតិវិធីនៃការអនុវត្តទេ នីតិវិធីបែបនេះ ត្រូវបានចាត់ទុកថា មិនត្រឹមត្រូវ និង គ្មានប្រយោជន៍។ ហេតុដូច្នេះ មាត្រា ៤៣៥ តំរូវឱ្យម្ចាស់បំណុលនៃការអនុវត្តធ្វើសំណើថា ខ្លួននឹងទិញអចលនវត្ថុក្នុងតម្លៃស្មើសុំក្នុងអំឡុងពេល មួយសប្តាហ៍ក្រោយពេលជូនដំណឹងទៅម្ចាស់បំណុលនៃការអនុវត្ត ក្នុងករណីដែលគ្មានលទ្ធភាពសល់ទេនោះ ក្រោយពីបានសងសោហ៊ុយសំរាប់នីតិវិធីហើយ។ ក្នុងករណីដែលម្ចាស់បំណុលនៃការអនុវត្ត មិនបានធ្វើសកម្មភាពដូច្នោះទេ តុលាការត្រូវលុបចោលពាក្យសុំការអនុវត្តនោះ។ ដូចនេះមុននឹងអនុវត្តហ៊ីប៉ូតែក តុលាការអនុវត្តត្រូវ ជ្រើសតាំងអ្នកវាយតម្លៃ និង បង្គាប់ឱ្យវាយតម្លៃអចលនវត្ថុ ដោយផ្អែកលើការស្រាវជ្រាវអំពីសណ្ឋាននៃអចលនវត្ថុ ទំនាក់ទំនងនៃការកាន់កាប់ និង ស្ថានភាពបច្ចុប្បន្នឯទៀត។

ឃ-ម្ចាស់បំណុលដែលដាក់ពាក្យសុំឱ្យអនុវត្តហ៊ីប៉ូតែក ត្រូវទទួលបន្ទុកបង់ជាមុនទៅតុលាការនូវសោហ៊ុយសម្រាប់ការអនុវត្ត និងសោហ៊ុយសម្រាប់នីតិវិធី យោងតាមមាត្រា ៣៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

### ៤-២ វិធានដើម្បីសំរបសំរួលការអនុវត្តដោយបង្ខំនៅពេលដែលមានម្ចាស់សិទ្ធិច្រើនលើអចលនវត្ថុដែលជាកម្មវត្ថុហ៊ីប៉ូតែក

ដូចដែលបានលើកឡើងពីខាងដើមហើយថា ការអនុវត្តដោយបង្ខំចំពោះហ៊ីប៉ូតែកមិនមានភាពស្មុគស្មាញខ្លាំងទេ នៅក្នុងករណីដែលមានតែកម្មវត្ថុនៃហ៊ីប៉ូតែកតែមួយ និង ម្ចាស់បំណុលហ៊ីប៉ូតែកតែម្នាក់នោះ ប៉ុន្តែការអនុវត្តនឹងកាន់តែស្មុគស្មាញ នៅពេលដែលមានម្ចាស់បំណុលហ៊ីប៉ូតែកច្រើននាក់ ឬ កម្មវត្ថុហ៊ីប៉ូតែកមានច្រើនជាងមួយនោះ ដែលការនេះចាំបាច់តំរូវឱ្យមានបញ្ញត្តិដើម្បីសំរបសំរួលក្នុងការអនុវត្ត។

### ៤-២-១ ការអនុវត្តដោយបង្ខំក្នុងករណីដែលមានម្ចាស់បំណុលហ៊ីប៉ូតែកច្រើននាក់

ពាក់ព័ន្ធនឹងការអនុវត្តដោយបង្ខំ ដែលមានម្ចាស់សិទ្ធិហ៊ីប៉ូតែកច្រើននាក់បែបនេះ នៅលើអចលនវត្ថុតែមួយ មានសំណួរជាច្រើនត្រូវបានលើកឡើងដូចជា "តើមានតែម្ចាស់សិទ្ធិហ៊ីប៉ូតែកដែលនៅលំដាប់លើគេតែប៉ុណ្ណោះឬ ដែលអាចដាក់ពាក្យសុំឱ្យអនុវត្តហ៊ីប៉ូតែកបាន?" "តើម្ចាស់សិទ្ធិហ៊ីប៉ូតែកដែលឋិតនៅក្នុងលំដាប់ទី ២ ឬ លំដាប់ចុងក្រោយ អាចដាក់ពាក្យសុំឱ្យអនុវត្តហ៊ីប៉ូតែករបស់ខ្លួនមុនម្ចាស់សិទ្ធិហ៊ីប៉ូតែកដែលឋិតនៅក្នុងលំដាប់ទីមួយដែរឬទេ?" "តើការដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំរបស់ម្ចាស់សិទ្ធិហ៊ីប៉ូតែកដែលមានលំដាប់ទីមួយ មានអានុភាពខុសគ្នាយ៉ាងដូចម្តេច?""តើសិទ្ធិហ៊ីប៉ូតែកទាំងនោះ ត្រូវរលត់ព្រមគ្នា ឬ មានសិទ្ធិហ៊ីប៉ូតែកខ្លះត្រូវនៅបន្តអត្ថិភាពក្រោយការលក់ដោយបង្ខំនោះ?" " តើម្ចាស់សិទ្ធិហ៊ីប៉ូតែកម្នាក់ៗ ត្រូវទទួលចំណែកប៉ុន្មានចេញពីថ្លៃលក់ដោយបង្ខំនោះ ?" ជាដើម ។

ដើម្បីឆ្លើយតបទៅនឹងសំណួរទាំងនេះ មាត្រា៥១០ កថាខណ្ឌទី ១ និង ទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណីបានចែងថា សិទ្ធិប្រាតិភោគប្រត្យក្សលើអចលនវត្ថុដែលអាចតតាំងនឹងសិទ្ធិប្រាតិភោគរបស់ម្ចាស់បំណុលនៃការអនុវត្ត ត្រូវនៅបន្តអត្ថិភាពក្រោយការលក់ដោយបង្ខំ ដែលជាការអនុវត្តសិទ្ធិប្រាតិភោគនោះ។ ក្រៅពីសិទ្ធិដែល បានកំណត់ខាងលើនេះ សិទ្ធិលើអចលនវត្ថុត្រូវរលត់ដោយការលក់ ។ ម្យ៉ាងវិញទៀត មាត្រា៤៤៩ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណីបានចែងថា អ្នកទិញត្រូវទទួលខុសត្រូវសងនូវសិទ្ធិលើបំណុលដែលត្រូវបានធានាដោយសិទ្ធិប្រាតិភោគ ដែលអ្នកទិញ បានទទួលបន្ត។

គ្មានបញ្ញត្តិណាមួយនៃច្បាប់សារធាតុ និង ច្បាប់នីតិវិធីនៃការអនុវត្តសិទ្ធិប្រាតិភោគប្រត្យក្ស ហាមមិនឱ្យម្ចាស់សិទ្ធិហ៊ីប៉ូតែកដែលមានលំដាប់ទាបជាង ដាក់ពាក្យសុំអនុវត្តដោយបង្ខំមុនម្ចាស់សិទ្ធិហ៊ីប៉ូតែកដែលមានលំដាប់ខ្ពស់ជាងនោះទេ ។

ហេតុដូច្នេះមានន័យថា បើសិនជាម្ចាស់សិទ្ធិហ៊ីប៉ូតែកដែលមានលំដាប់អាទិភាពមុន បានដាក់ពាក្យសុំអនុវត្តសិទ្ធិហ៊ីប៉ូតែកដែលមានលំដាប់បន្តបន្ទាប់ត្រូវរលត់។ តែផ្ទុយទៅវិញ បើសិនជាម្ចាស់សិទ្ធិហ៊ីប៉ូតែកដែលមានលំដាប់បន្ទាប់ដាក់ពាក្យសុំអនុវត្តមុននោះ សិទ្ធិហ៊ីប៉ូតែកដែលមានលំដាប់ខ្ពស់ជាងមិនរលត់ទេ ។ សួរថា តើលក្ខខណ្ឌតតាំងសំដៅទៅលើអ្វី គឺសំដៅទៅលើលំដាប់នៃការចុះបញ្ជីសិទ្ធិប្រាតិភោគប្រត្យក្ស។ សំណួរសួរថាតើប្រាក់ដែលបានមកពីការលក់ត្រូវបែងចែកយ៉ាងដូចម្តេច ក្នុងករណីដែលមានហ៊ីប៉ូតែច្រើនបានរលត់? ចំពោះការទទួលចំណែកដែលចេញពីថ្លៃលក់ដោយបង្ខំនោះ គឺត្រូវទទួលទៅតាមលំដាប់នៃសិទ្ធិជាអាទិភាពមិនមែនទៅតាមសមាមាត្រទេ។

ដើម្បីឱ្យយល់កាន់តែច្បាស់អំពីនីតិវិធីនៃការអនុវត្តនេះ សូមពិនិត្យមើលករណីសិក្សាខាងក្រោមនេះ:

**ករណីដែលមានម្ចាស់បំណុលហ៊ីប៉ូតែកច្រើននាក់:**

ឧបមាថាតម្លៃនៃដី (L) ដែលជាកម្មសិទ្ធិរបស់ A ត្រូវបានគេវាយតម្លៃថាមានតម្លៃចំនួន ១ 000 ដុល្លារ ហើយមិនចាំបាច់ គិតអំពីសោហ៊ុយនៃនីតិវិធីនោះទេដើម្បីងាយស្រួល ។

X គឺជាម្ចាស់បំណុលហ៊ីប៉ូតែកលំដាប់ទី ១ ដោយបានធានាបំណុលចំនួន ៥00 ដុល្លារចំពោះ A ។

Y គឺជាម្ចាស់បំណុលហ៊ីប៉ូតែកលំដាប់ទី ២ ដោយបានធានាបំណុលចំនួន ៤00 ដុល្លារចំពោះ A ។

Z គឺជាម្ចាស់បំណុលហ៊ីប៉ូតែកលំដាប់ទី ៣ ដោយបានធានបំណុលចំនួន ៣00 ដុល្លារចំពោះ A ។

១- តើហ៊ីប៉ូតែកអ្វីដែលនៅតែបន្តអត្ថិភាព ហើយហ៊ីប៉ូតែកអ្វីដែលត្រូវរលត់? តើដី (L) ត្រូវបានវាយតម្លៃដើម្បីលក់បានចំនួនប៉ុន្មាន? ហើយតើម្ចាស់បំណុលនីមួយៗនឹងទទួលបានចំណែកចំនួនប៉ុន្មាន ប្រសិនបើ X ដាក់ពាក្យសុំឱ្យអនុវត្តហ៊ីប៉ូតែករបស់ខ្លួន?

**ចំលើយ :** យោងតាមមាត្រា ៥១0 នៃក្រមនីតិវិធីរដ្ឋប្បវេណី បើសិនជា X ដាក់ពាក្យសុំអនុវត្តហ៊ីប៉ូតែករបស់ខ្លួនមុននោះ ហ៊ីប៉ូតែករបស់ Y និង Z ត្រូវរលត់ដោយការលក់ដោយបង្ខំ។ ហើយ Y និង Z អាចចូលរួមក្នុងការចែកចំណែកដោយស្វ័យប្រវត្តិ។ ឧបមាថា តម្លៃនៃដី (L) ត្រូវបានគេវាយតម្លៃថា មានតម្លៃចំនួន ១ 000 ដុល្លារ (តម្លៃនេះ ត្រូវបានចាត់ទុកថា សមហេតុសមផល ពីព្រោះតម្លៃដើមនៃដី (L) មានចំនួន ១ 000 ដុល្លារ ហើយ ហ៊ីប៉ូតែកទាំងអស់ត្រូវបានរលត់អស់ហើយ )។ ដូច្នេះ X ត្រូវបានចំណែក ៥00 ដុល្លារ Y ត្រូវបានចំណែក ៤00 ដុល្លារ និង Z ត្រូវបានចំណែក ១ 00 ដុល្លារ ។

២- តើហ៊ីប៉ូតែកអ្វីដែលនៅតែបន្តអត្ថិភាព ហើយហ៊ីប៉ូតែកអ្វីដែលត្រូវរលត់? តើដី (L) ត្រូវបានវាយតម្លៃដើម្បីលក់បានចំនួនប៉ុន្មាន? ហើយតើម្ចាស់បំណុលនីមួយៗនឹងទទួលបានចំណែកចំនួនប៉ុន្មាន ប្រសិនបើ Y ដាក់ពាក្យសុំឱ្យអនុវត្តហ៊ីប៉ូតែករបស់ខ្លួន?

**ចំលើយ :** ប្រសិនបើ Y ដាក់ពាក្យសុំអនុវត្តហ៊ីប៉ូតែករបស់ខ្លួនមុននោះ សិទ្ធិហ៊ីប៉ូតែករបស់ Z ត្រូវរលត់។ ប៉ុន្តែ ហ៊ីប៉ូតែករបស់ X មិនរលត់ទេ។ Z អាចចូលរួមក្នុងការចែកចំណែកជាមួយ Y ដែរ ។ ប៉ុន្តែ X មិនអាចចូលរួមក្នុងការចែកចំណែកបានទេ ផ្ទុយទៅវិញ X អាចដាក់ពាក្យសុំអនុវត្តហ៊ីប៉ូតែករបស់ខ្លួននៅពេលក្រោយបាន។ ឧបមាថា តម្លៃនៃដី (L) ត្រូវបានគេវាយតម្លៃថា មានតម្លៃចំនួន ១ 000 ដុល្លារ (មិនចាំបាច់គិតអំពីសោហ៊ុយនៃនីតិវិធីទេ) ។ អ្នកដែលទិញអចលនវត្ថុដោយការលក់ដោយបង្ខំនោះ អាចផ្តល់សំណើទិញក្នុងតម្លៃ ៥00 ដុល្លារ ពីព្រោះអ្នកទិញ នឹងធ្វើលទ្ធកម្មដីនោះដោយមានជាប់បន្ទុកហ៊ីប៉ូតែកដែលបាន ធានាបំណុលចំនួន ៥00 ដុល្លារ។ ជាលទ្ធផល Y ត្រូវបានចំណែក ៤00 ដុល្លារ ហើយ Z ត្រូវបានចំណែក ១00 ដុល្លារ ។

៣- តើហ៊ីប៉ូតែកអ្វីដែលនៅបន្តអត្ថិភាព ហើយហ៊ីប៉ូតែកអ្វីដែលត្រូវរលត់? ហើយម្ចាស់បំណុលនីមួយៗនឹងទទួលបានចំណែកចំនួនប៉ុន្មាន ប្រសិនបើ Z ដាក់ពាក្យសុំឱ្យអនុវត្តហ៊ីប៉ូតែករបស់ខ្លួន?

**ចំលើយ :** បើសិនជា Z ដាក់ពាក្យសុំអនុវត្តហ៊ីប៉ូតែករបស់ខ្លួនមុននោះ ហ៊ីប៉ូតែករបស់ Z ត្រូវរលត់ ។ ប៉ុន្តែហ៊ីប៉ូតែករបស់ X និង Y មិនរលត់ទេ ។ X និង Y មិនអាចចូលរួមក្នុងការចែកចំណែកបានទេ ។ ផ្ទុយទៅវិញ X និង Y អាចដាក់ពាក្យសុំអនុវត្តហ៊ីប៉ូតែករបស់ខ្លួនចំពោះអ្នកដែលបានធ្វើលទ្ធកម្មដោយការលក់ដោយបង្ខំចំពោះដី (L) នោះបាន ។ ឧបមថាតម្លៃនៃដី (L) ត្រូវបានគេវាយតម្លៃថា មានតម្លៃចំនួន ១ 000 ដុល្លារ ( មិនចាំបាច់គិតអំពីសោហ៊ុយនៃនីតិវិធីទេ) ។ អ្នកដែលទិញអចលនវត្ថុដោយការលក់ដោយបង្ខំនោះ នឹងមិនតំរូវឱ្យបង់នូវតម្លៃពេញទេ ពីព្រោះដីនោះនៅជាប់បន្ទុក ៩00 ដុល្លារដែលជាសិទ្ធិរបស់ X និង Y ។ ដូច្នេះ អ្នកទិញបង់ត្រឹមតែតម្លៃ ១00 ដុល្លារតែប៉ុណ្ណោះ ។ មានន័យថា Z មានសិទ្ធិទទួលបានតែ **១00** តែប៉ុណ្ណោះ ។

យោងតាមករណីសិក្សាខាងលើ យើងឃើញថា មិនថា ម្ចាស់បំណុលហ៊ីប៉ូតែកនៅក្នុងលំដាប់ទីប៉ុន្មានដែលបានដាក់ពាក្យសុំអនុវត្តហ៊ីប៉ូតែកមុននោះទេ គឺចំណែកដែលម្ចាស់បំណុលហ៊ីប៉ូតែកម្នាក់ៗត្រូវទទួលបាន នៅតែដូចគ្នាដដែលដូចលោក Z នៅក្នុងករណីនេះ គឺនៅតែបានទទួលចំណែក ១00 ដុល្លារដដែលចេញពីថ្លៃលក់ដោយបង្ខំនៅក្នុងគ្រប់ករណីទាំងបីខាងលើ ។

### ៤-២-២ ការអនុវត្តដោយបង្ខំចំពោះអាគារជាកម្មសិទ្ធិរបស់តតិយជន

យោងតាមមាត្រា ៨៩៤ នៃក្រមរដ្ឋប្បវេណីបានចែងថា បើអ្នកបង្កើតហ៊ីប៉ូតែក មានកម្មសិទ្ធិលើអាគារដែលអ្នកបង្កើតហ៊ីប៉ូតែកនោះ ឬតតិយជនបានសាងសង់នៅលើដីហ៊ីប៉ូតែក នៅក្រោយពេលហ៊ីប៉ូតែកនោះត្រូវបានបង្កើត ហើយម្ចាស់បំណុលហ៊ីប៉ូតែកអាចលក់ដោយបង្ខំនូវអាគារនោះ ព្រមជាមួយនឹងដីហ៊ីប៉ូតែកនោះបាន ។ ប៉ុន្តែបើចំនួនថ្លៃលក់ដី និង អាគារនោះទាបជាង ថ្លៃលក់ដីដែលគ្មានអាគារលើនោះ ម្ចាស់បំណុលហ៊ីប៉ូតែកអាចទាមទារឱ្យអ្នកបង្កើតហ៊ីប៉ូតែករុះរើអាគារនោះ មុនពេលលក់ដោយបង្ខំ ។ ការចែងបែបនេះ ដោយអនុលោមទៅតាមមាត្រា ១២២ នៃក្រមរដ្ឋប្បវេណី ដែលបានកំណត់ថា វត្ថុដែលនៅជាប់នឹងដី ឬ វត្ថុដែលក្លាយជាភាគមួយនៃដី ជាពិសេសអាគារ ឬ សំណង់ដែលសង់នៅលើដីហើយមិនអាចប្តូរកន្លែងបាន គឺជាសមាសភាគនៃដី ។

ក្នុងករណីដែលតតិយជនមានកម្មសិទ្ធិលើអាគារលើដីហ៊ីប៉ូតែក ដោយផ្អែកលើ សិទ្ធិជួលអចិន្ត្រៃយ៍ ផលុបភោគ ឬ សិទ្ធិជួល បើតតិយជននោះមិនអាចយកសិទ្ធិជួលអចិន្ត្រៃយ៍ ផលុបភោគ ឬ សិទ្ធិជួលរបស់ខ្លួនមកតតាំងចំពោះម្ចាស់បំណុលហ៊ីប៉ូតែក ម្ចាស់បំណុលហ៊ីប៉ូតែកអាចលក់ដោយបង្ខំនូវអាគារនោះព្រមជាមួយនឹងដីហ៊ីប៉ូតែកបាន ។

**គំនូសបង្ហាញអំពីវិធីក្នុងការពិចារណាទាក់ទងទៅនឹងការអនុវត្តដោយបង្ខំនូវអាគារជាកម្មសិទ្ធិរបស់តតិយជន**




### ៤-២-៣ សិទ្ធិរបស់តតិយជនដែលបានធ្វើលទ្ធកម្ម

យោងតាមមាត្រា ៨៩៥ និង ៨៩៦ នៃក្រមរដ្ឋប្បវេណី បានចែងថា តតិយជនដែលបានធ្វើលទ្ធកម្មនូវអចលនវត្ថុហ៊ីប៉ូតែកដែលមិនមែនតាមរយៈការលក់ដោយបង្ខំ អាចក្លាយជាអ្នកទិញនៅក្នុងការលក់ដោយបង្ខំបាន ហើយក៏អាចទាមទារសំណងនៃចំណាយចាំបាច់ពីថ្លៃលក់ដោយបង្ខំនូវអចលនវត្ថុ ដោយមានអាទិភាពជាងម្ចាស់បំណុលហ៊ីប៉ូតែកទៀតផង ។

ឧទាហរណ៍ X គឺជាម្ចាស់បំណុលហ៊ីប៉ូតែកដែលបានធានាសិទ្ធិលើបំណុលចំនួន ១ 000ដុល្លារ ។ Y ជាអ្នកបង្កើតហ៊ីប៉ូតែកលើដី (L) ដែលមានតម្លៃចំនួន ៣ 000 ដុល្លារ ។ Z បានទិញដីនោះពី Y ក្នុងតម្លៃ ២000 ដុល្លារ ។ Z បានចេញចំណាយសោហ៊ុយចំនួន ៥00 ដុល្លារដើម្បីបង្កើនតម្លៃនៃដីនោះ ហើយតម្លៃនៃដីនោះបានកើនឡើងចំនួន ៣ ៥00 ដុល្លារ ។ ក្រោយមក X ទាមទារឱ្យមានការលក់ដោយបង្ខំនូវដីនោះ ។

ឧបមាថា តម្លៃនៃដីដែលត្រូវបានវាយតម្លៃគឺមានចំនួន ៣ ៥00 ដុល្លារ ហើយ Z អាចទិញដីនោះប្រសិនបើគាត់ចង់ទិញ ។ នៅក្នុងករណីនេះ ថ្លៃលក់ដោយបង្ខំនៃដីនោះមានចំនួន ៣ ៥00 ដុល្លារ ។ បើសិនជា Z ជាអ្នកទិញដីនេះ ពេលនោះសិទ្ធិទាមទារសំណងនឹងត្រូវរលត់ ពីព្រោះអ្នកទិញអចលនវត្ថុដោយការលក់ដោយបង្ខំ-តតិយជនដែលបានធ្វើលទ្ធកម្ម និង ម្ចាស់បំណុលហ៊ីប៉ូតែក គឺជាមនុស្សតែមួយ ។

ករណីប្រសិនបើ Z មិនទិញទេ Z គ្រាន់តែអាចអនុវត្តសិទ្ធិរបស់ខ្លួនដើម្បីទាមទារសំណងចំនួន ៥០០ ដុល្លារ ពី X ពីព្រោះ Z បានធ្វើឱ្យកើនតម្លៃដីនោះ។

**ឧទាហរណ៍:**

លោក **ក** បានបង្កើតសិទ្ធិហ៊ីប៉ូតែកនៅលើដី L មួយកន្លែងឱ្យលោក **ខ** ដែលជាម្ចាស់បំណុលហ៊ីប៉ូតែកដែលមានលំដាប់ទី ១។ ក្រោយមកលោក **ក** បានបង្កើតសិទ្ធិជួលអចិន្ត្រៃយ៍នៅលើដី L នោះទៅឱ្យលោក **គ** ដោយមានការចុះបញ្ជីសុរិយោដី ។ លោក **ក** បានធ្វើអនុប្បទានដី L ដដែលនោះទៅឱ្យលោក **ឃ**។ លោក **ខ** ដែលជាម្ចាស់បំណុលហ៊ីប៉ូតែកនៅក្នុងលំដាប់ទី ១ បានអនុវត្តហ៊ីប៉ូតែកនៅលើដី L នោះ ហើយលោក **ង** គឺជាអ្នកទិញដីនោះតាមរយៈការលក់ដោយបង្ខំ។

នៅពេលដែល លោក **ខ** អនុវត្តហ៊ីប៉ូតែកនៅលើដី L នោះ សិទ្ធិជួលអចិន្ត្រៃយ៍ មិនអាចតតាំងចំពោះម្ចាស់បំណុលហ៊ីប៉ូតែកបានទេ ដោយសារតែសិទ្ធិជួលអចិន្ត្រៃយ៍នេះ ត្រូវបានបង្កើតក្រោយហ៊ីប៉ូតែក ដូចនេះ សិទ្ធិជួលអចិន្ត្រៃយ៍របស់លោក **គ** មិនអាចយកទៅតតាំងជាមួយនឹងសិទ្ធិហ៊ីប៉ូតែករបស់លោក **ខ** បានឡើយ។ ដូចនេះ លោក **ង** ដែលជាអ្នកទិញដីនោះតាមរយៈការលក់ដោយបង្ខំ មានឋានៈស្មើលោក **ខ** ដែលជាម្ចាស់បំណុលហ៊ីប៉ូតែក។ មានន័យថា លោក **ង** អាចធ្វើលទ្ធកម្មកម្មសិទ្ធិនៅលើដី L នេះ ដោយមិនមានជាប់បន្ទុកនៃសិទ្ធិជួលអចិន្ត្រៃយ៍។

ចំពោះលោក **ឃ** វិញ (កាលដែលខ្លួនបានទទួលដីនេះតាមរយៈអនុប្បទានពីលោក **ក**) មិនអាចធ្វើឱ្យលោក **ឃ** បានទទួលកម្មសិទ្ធិនៅលើដីនេះឡើយ ពីព្រោះដីនេះជាប់ទាំងបន្ទុកនៃសិទ្ធិហ៊ីប៉ូតែកផង និង សិទ្ធិជួលអចិន្ត្រៃយ៍ផង។ បើសិនជាលោក **ឃ** ចង់ធ្វើលទ្ធកម្មកម្មសិទ្ធិនៅលើដី L នោះ ដោយមិនជាប់បន្ទុកអ្វីទាំងអស់ លោក **ឃ** ត្រូវអនុវត្តតាមមាត្រា ៨៥៥ ដែលស្តីអំពីការស្នើសុំទិញដោយតតិយជនដែលបានធ្វើលទ្ធកម្ម មានន័យថា លោក **ឃ** អាចដាក់ពាក្យសុំទិញនូវដី L នេះ តាមរយៈការលក់ដោយបង្ខំដូចជាលោក **ង** ដែរ។ បើមិនដូច្នោះទេ លោក **ឃ** អាចបាត់បង់នូវកម្មសិទ្ធិលើដីនោះ ។

### ៤-២-៤ ការចែកចំណែកព្រមគ្នា និង ការចែកចំណែកមិនព្រមគ្នា ក្នុងករណីនៃហ៊ីប៉ូតែករួមគ្នា

ហ៊ីប៉ូតែករួម គឺជាហ៊ីប៉ូតែកមួយប្រភេទ ដែលកម្មវត្ថុរបស់វាមានច្រើនជាងមួយ ប៉ុន្តែត្រូវបានគេយកមកធានាសិទ្ធិលើបំណុលតែមួយ។

យោងតាមមាត្រា ៨៥៧ នៃក្រមរដ្ឋប្បវេណី ក្នុងករណីដែលម្ចាស់បំណុលមានហ៊ីប៉ូតែកលើអចលនវត្ថុច្រើនដើម្បីធានាសិទ្ធិលើបំណុលតែមួយ បើចែកចំណែកនូវប្រាក់ដែលបានមកពីការលក់ដោយបង្ខំនៅពេលជាមួយគ្នា បន្ទុកនៃសិទ្ធិលើបំណុល ត្រូវចែកទៅតាមសមាមាត្រនៃតម្លៃអចលនវត្ថុនីមួយៗនោះ ។

បើចែកចំណែកតែប្រាក់ដែលបានពីការលក់ដោយបង្ខំនូវអចលនវត្ថុណាមួយ ម្ចាស់បំណុលហ៊ីប៉ូតែកអាចទទួលការសងចំពោះសិទ្ធិលើបំណុលទាំងអស់ ដោយប្រាក់ដែលបានមកពីការលក់ដោយបង្ខំនោះបាន។ ក្នុងករណីនេះ

ម្ចាស់បំណុលហ៊ីប៉ូតែកដែលមានលំដាប់បន្ទាប់ អាចអនុវត្តហ៊ីប៉ូតែករបស់ម្ចាស់បំណុលហ៊ីប៉ូតែកដែលមានលំដាប់នៅខាងលើដោយឧបាទេសកម្មបាន រហូតដល់ចំនួនទឹកប្រាក់ដែលម្ចាស់បំណុលហ៊ីប៉ូតែកដែលមានលំដាប់ខ្ពស់ជាងនោះត្រូវទទួលការសងចំពោះអចលនវត្ថុផ្សេងទៀត ដើម្បីបញ្ចៀសនូវភាពអយុត្តិធម៌ ដែលប្រាក់ដែលបានមកពីការលក់ អាចត្រូវបានផ្លាស់ប្តូរតាមអំពើចិត្តរបស់ម្ចាស់បំណុលហ៊ីប៉ូតែកដែលស្ថិតនៅក្នុងលំដាប់ខ្ពស់ជាង។ និយាយម្យ៉ាងទៀត តាមរយៈឧបាទេសកម្ម រាល់ម្ចាស់បំណុលហ៊ីប៉ូតែកនីមួយៗដែលស្ថិតនៅក្នុងលំដាប់ទាបជាងម្ចាស់បំណុលហ៊ីប៉ូតែករួម អាចទទួលចំនួនទឹកប្រាក់ដូចគ្នានៅចុងបញ្ចប់។ សូមមើលឧទាហរណ៍ខាងក្រោមនេះ :

**ឧទាហរណ៍:**

លោក **ក** គឺជាម្ចាស់បំណុលហ៊ីប៉ូតែកនៅលើដី២កន្លែងដែលជារបស់លោក **ខ** ចំនួន ៦០០ ដុល្លា។ ដីទីមួយមានតំលៃ ៨០០ ដុល្លា។ ដីទី ២ មានតំលៃ ១២០០ ដុល្លា។ នៅពេលដែលលោក **ខ** មិនមានលទ្ធភាពសងនៅកាលបរិច្ឆេទដែលត្រូវសងទេ លោក **ក** អាចអនុវត្តហ៊ីប៉ូតែករបស់ខ្លួនចំពោះដីទាំងពីរកន្លែងរបស់លោក **ខ** ក៏បាន ឬ ជ្រើសរើសការអនុវត្តតែទៅលើដីមួយណាក៏បាន។ តែលោក **គ** គឺជាម្ចាស់បំណុលហ៊ីប៉ូតែកលំដាប់ទី ២ នៅលើដីទី១ ចំនួន ៦០០ ដុល្លា។ លោក **ឃ** គឺជាម្ចាស់បំណុលហ៊ីប៉ូតែកលំដាប់ទី ២ នៅលើដីទី២ ចំនួន ៩០០ ដុល្លា។

នៅក្នុងករណីដែលលោក **ក** អនុវត្តហ៊ីប៉ូតែកទាំងពីរព្រមគ្នា ដោយសារតែហ៊ីប៉ូតែកដែលមានលំដាប់ទាបជាងត្រូវរលត់ ចំនួនទឹកប្រាក់ដែលបានមកពីការលក់ដីទាំងពីរ អាចបូករួមទៅមានចំនួន ២ ០០០ ដុល្លារ។ បន្ទាប់មកយោងតាមមាត្រា ៨៩៧ កថាខណ្ឌទី ១ លោក **ក** ទទួលបានចចំនួន ២៤០ ដុល្លារពីដីទី ១ និង ៣៦០ ដុល្លារពីដីទិ ២។ ហេតុដូច្នេះ លោក **គ** ទទួលបានចំនួន ៥៦០ ដុល្លារដែលនៅសល់ពីដីទី ១ និង លោក **ឃ** ទទួលបានចំនួន ៨៤០ ដុល្លារពីដីទី ២។

ក្នុងករណីដែលលោក **ក** អនុវត្តហ៊ីប៉ូតែករបស់ខ្លួនតែចំពោះដីទី ១ ប្រាក់ដែលបានមកពីការលក់នោះ មានចំនួនប្រហែល ៨០០ ដុល្លា។ ពេលនោះ លោក **ក** ត្រូវទទួលបាន ៦០០ ដុល្លាចេញពីថ្លៃដីទី ១ មិនមែនទទួលបាន ២៤០ ដុល្លារ តាមមាត្រា ៨៩៧ កថាខណ្ឌទី ២ វាក្យខណ្ឌទី ១ ហើយនៅសល់ចំនួន ២០០ ដុល្លាទៀត ត្រូវបានទៅលោក **គ** ហើយនៅក្នុងករណីនេះ ដោយគ្មានមាត្រា ៨៩៧ កថាខណ្ឌទី ២ វាក្យខណ្ឌទី ២ ទេ លោក **គ** មិនអាចទទួលបានអ្វីទៀតពីដីទី ២ នោះទេ ពីព្រោះ ហ៊ីប៉ូតែករបស់គាត់ត្រូវបានរលត់បាត់រួចទៅហើយ ចំណែកឯលោក **ឃ** វិញ អាចទទួលបាននូវការសងគ្រប់ចំនួន ៩០០ ដុល្លារ ពីព្រោះលោក **ក** បានទទួលការសងសិទ្ធិបំណុលរបស់គាត់គ្រប់ចំនួនហើយ។

វាក្យខណ្ឌទី ២ នៃមាត្រា ៨៩៧ កថាខណ្ឌទី ២ អនុញ្ញាតឱ្យលោក **គ** ធ្វើឧបាទេសកម្មហ៊ីប៉ូតែករបស់លោក **ក** លើដីទី ២ ត្រឹមកំរិតដែលលោក **ក** អាចទទួលបានពីប្រាក់ដែលបានមកពីការលក់ដីទី ២ (៣៦០ ដុល្លារ)។ ហេតុដូច្នេះ

សរុបមក លោក ត អាចទទួលបានចំនួន ៥៦០ ដូល្លារ ហើយលោក ឃ ទទួលបានប្រាក់ដែលនៅសល់តែចំនួន ៨៤០ ដូល្លារ តែប៉ុណ្ណោះ។

ក្នុងករណីដែលលោក ក អនុវត្តហ៊ីប៉ូតែករបស់ខ្លួនចំពោះដីទី ២ មុនវិញ ដោយលក់បានតំលៃ ១២០០ ដុល្លា។ ពេលនោះ លោក ក ត្រូវទទួលបាន ៦០០ ដុល្លាចេញពីថ្លៃដីទី ២ នេះយោងតាមមាត្រា ៨៥៧ កថាខណ្ឌទី ២ វាក្យខណ្ឌទី ១ ហើយនៅសល់ចំនួន ៦០០ ដុល្លាទៀត ត្រូវបានទៅលោក ឃ។ នៅក្នុងករណីនេះ យោងតាមមាត្រា ៨៥៧ កថាខណ្ឌទី ២ វាក្យខណ្ឌទី ២ លោក ឃ អាចធ្វើឧបាទេសកម្មហ៊ីប៉ូតែករបស់លោក ក លើដីទី ១ ត្រឹមកំរិតចំនួនទឹកប្រាក់ ដែលលោក ក អាចទទួលបានពីដីទី ១ (២៤០ ដូល្លារ)។ ហេតុដូច្នេះ តាមរយៈឧបាទេសកម្មនេះ លោក ឃ អាចទទួលបាន ២៤០ ដូល្លារពីដីទី ១ ហើយលោក ត អាចទទួលប្រាក់ចំនួន ៥៦០ ដូល្លារដែលនៅសល់ដែលស្មើទៅ នឹងលទ្ធផលនៃការអនុវត្តហ៊ីប៉ូតែកព្រមគ្នា។

## ៥- ការទាមទារហ៊ីប៉ូតែក

### ៥-១ ហ៊ីប៉ូតែកបន្ត

ម្ចាស់បំណុលហ៊ីប៉ូតែក អាចយកហ៊ីប៉ូតែកនេះធ្វើជាប្រាតិភោគសំរាប់កាតព្វកិច្ចរបស់ខ្លួន ឬ តតិយជន បាន។ ករណីនេះ ហៅថា ហ៊ីប៉ូតែកបន្ត។

នៅពេលចែកចំណែកនូវប្រាក់ដែលបានមកពី ការលក់ដោយបង្ខំនូវអចលនវត្ថុហ៊ីប៉ូតែក ម្ចាស់បំណុលហ៊ីប៉ូតែកបន្ត អាចទទួលការសងចំពោះសិទ្ធិលើបំណុលត្រឹមកម្រិតនៃចំនួនទឹកប្រាក់ នៃចំណែកដែលត្រូវចែកទៅឱ្យម្ចាស់បំណុលហ៊ីប៉ូតែក។ ប៉ុន្តែ បើសិទ្ធិលើបំណុលនោះ មិនទាន់ដល់ កំណត់ពេលត្រូវសងទេ ម្ចាស់បំណុលហ៊ីប៉ូតែកបន្ត គ្រាន់តែអាចទាមទារឱ្យតម្កល់ចំនួនទឹកប្រាក់ដែលខ្លួន អាចទទួលការសងប៉ុណ្ណោះ។

ឧទាហរណ៍ : លោក X ជាម្ចាស់បំណុលហ៊ីប៉ូតែកដោយមានការធានាបំណុលរបស់លោក Y ចំនួន ១ 000 ដូល្លារចំពោះដី L ដែលជាកម្មសិទ្ធិរបស់លោក Y ។ លោក X បានជំពាក់បំណុលរបស់ លោក Z ចំនួន ២ 000 ដូល្លារ ហើយបានយកហ៊ីប៉ូតែករបស់ខ្លួនធ្វើជាប្រាតិភោគដើម្បីធានាបំណុល របស់ខ្លួនចំពោះលោក Z ។

- ករណីនេះ លោក Z អាចទទួលបានប្រាក់ចំនួន ១ 000 ដូល្លារ ពីការលក់ដី L ដោយមាន អាទិភាព។
- ប្រសិនបើ កាលបរិច្ឆេទនៃការកំណត់សងនៃកាតព្វកិច្ចរបស់លោក X មិនទាន់បានមកដល់នៅឡើយទេ លោក Z អាចទាមទារឱ្យតម្កល់ប្រាក់ចំនួន ១ 000 ដូល្លារ។

លក្ខខណ្ឌដើម្បីឱ្យមានអានុភាព : ហ៊ីប៉ូតែកបន្ត មិនមានអានុភាពឡើយ ប្រសិនបើមិនធ្វើឡើងដោយលិខិតយថាភូត និង មិនបានចុះបញ្ជីបន្ថែម។

ហ៊ីប៉ូតែកបន្ត មិនអាចតតាំងចំពោះកូនបំណុលដែលមានកាតព្វកិច្ចចម្បង អ្នកធានា អ្នកបង្កើត ហ៊ីប៉ូតែក និង ប្រតិសិទ្ធិរបស់ជនទាំងនោះបានឡើយ បើម្ចាស់បំណុលហ៊ីប៉ូតែក មិនបានជូនដំណឹងទៅកូនបំណុលដែលមានកាតព្វកិច្ចចម្បង ឬ ទទួលការយល់ព្រមពីកូនបំណុលនោះទេ។ ការជូនដំណឹង ឬ ការយល់ព្រមនេះ គឺមាន ភាពចាំបាច់ដើម្បីឱ្យពួកគេអាចដឹងថា តើនរណា គឺជាម្ចាស់បំណុលហ៊ីប៉ូតែក ពិតប្រាកដ។

### ៥-២ អនុប្បទាន ឬ ការបោះបង់ហ៊ីប៉ូតែក មាត្រា ៨៦០

ម្ចាស់បំណុលហ៊ីប៉ូតែក អាចធ្វើអនុប្បទាន ឬ បោះបង់នូវហ៊ីប៉ូតែកបានដើម្បីផលប្រយោជន៍របស់ម្ចាស់បំណុល (ផ្សេងទៀត) ចំពោះកូនបំណុលតែម្នាក់ ។

អនុប្បទានិកនៃហ៊ីប៉ូតែក អាចអនុវត្តហ៊ីប៉ូតែកដែលខ្លួនបានទទួល ដោយយកមកធ្វើជា ប្រាតិភោគនៃសិទ្ធិលើបំណុលរបស់ខ្លួនបាន។ មានន័យថា ប្រសិនបើហ៊ីប៉ូតែក ត្រូវបានធ្វើអនុប្បទាន ម្ចាស់បំណុលហ៊ីប៉ូតែកដែលបានធ្វើអនុប្បទានហ៊ីប៉ូតែកនោះ នឹងក្លាយជាម្ចាស់បំណុលដែលគ្មានហ៊ីប៉ូតែក ចំណែកឯម្ចាស់បំណុលដែលបានទទួលអនុប្បទានហ៊ីប៉ូតែក នឹងក្លាយជាម្ចាស់បំណុលដែលមានហ៊ីប៉ូតែក។ និយាយឱ្យខ្លី រវាងភាគីនៃអនុប្បទានហ៊ីប៉ូតែក សិទ្ធិលើបំណុលរបស់អនុប្បទានិក មានអាទិភាពជាង សិទ្ធិលើបំណុលរបស់អនុប្បទាយី។

បុគ្គលដែលបានបោះបង់ហ៊ីប៉ូតែក ពុំអាចអះអាងអានុភាពហ៊ីប៉ូតែកនោះចំពោះបុគ្គលដែលបាន ទទួលនូវការបោះបង់នោះឡើយ។ ម្ចាស់បំណុលដែលបានបោះបង់ហ៊ីប៉ូតែក មិនអាចអះអាងហ៊ីប៉ូតែក ចំពោះម្ចាស់បំណុលដែលជាភាគីម្ខាងទៀតនៃការបោះបង់ហ៊ីប៉ូតែកបានឡើយ។ មានន័យថា រវាងគូភាគី នៃការបោះបង់ហ៊ីប៉ូតែក ភាគីទាំងសងខាងមិនអាចអះអាងពីសិទ្ធិអាទិភាពទៅវិញទៅមកបានឡើយ។

សរុបមក អនុប្បទាន និង ការបោះបង់ហ៊ីប៉ូតែក គឺជាទស្សនៈដែលមានលក្ខណៈស្រដៀងគ្នា ប៉ុន្តែវាមានភាពខុសគ្នា។ អ្វីដែលត្រូវបានធ្វើអនុប្បទាន ឬ បោះបង់នោះ គឺមានអាទិភាពចំពោះគ្នា។

ឧទាហរណ៍ : លោក X មានហ៊ីប៉ូតែកលំដាប់ទី ១ ចំពោះដី L ដែលបានធានាបំណុលចំនួន ៤០០ ដុល្លារ។ លោក Y មានហ៊ីប៉ូតែកលំដាប់ទី ២ ដែលបានធានាបំណុលចំនួន ២០០ ដុល្លារ។ លោក Z គឺជា ម្ចាស់បំណុលហ៊ីប៉ូតែកលំដាប់ទី ៣ ដែលមានសិទ្ធិលើបំណុលចំនួន ៦០០ ដុល្លារ។ លោក A ជាម្ចាស់បំណុលដែល មានសិទ្ធិលើបំណុលចំនួន ៤០០ ដុល្លារដោយគ្មានប្រាតិភោគ។ លោក B គឺជា អ្នកបង្កើតហ៊ីប៉ូតែកកូនបំណុលនៃដី L ។ ឧបមាថា តម្លៃនៃដី L គឺមានចំនួន ១ ០០០ ដុល្លារ។

១- លោក X បានបោះបង់ហ៊ីប៉ូតែករបស់ខ្លួនដើម្បីជាប្រយោជន៍របស់លោក A ហើយ ការបោះបង់នោះត្រូវបានចុះបញ្ជី។ បន្ទាប់មកលោក X បានអនុវត្តហ៊ីប៉ូតែករបស់ខ្លួន។ តើអ្នកណា អាចទទួលនូវការចែកចំណែកហើយទទួលបានចំនួនប៉ុន្មាន?

២- លោក X បានធ្វើអនុប្បទានហ៊ីប៉ូតែករបស់ខ្លួនដើម្បីប្រយោជន៍របស់លោក A ហើយ អនុប្បទាននេះត្រូវបានចុះបញ្ជី។ បន្ទាប់មកលោក A បានអនុវត្តហ៊ីប៉ូតែករបស់ខ្លួន។ តើអ្នកណា អាចទទួលនូវការចែកចំណែក ហើយទទួលបានចំនួនប៉ុន្មាន?

**សន្និដ្ឋាន**

១- ការចែកចំណែកធម្មតា ត្រូវធ្វើឡើងដូចខាងក្រោមនេះ។ (X =៤០០, Y = ២០០, Z = ៤០០) តាមរយៈការបោះបង់ X មិនអាចអះអាងអំពីអាទិភាពរបស់ខ្លួនចំពោះ A ចំពោះផលប្រយោជន៍របស់គាត់ដែល X បានបោះបង់ហ៊ីប៉ូតែកទៅនោះបានទេ ប៉ុន្តែ X នៅតែអាចអះអាងអំពីហ៊ីប៉ូតែករបស់ខ្លួនចំពោះ Y និង Z ។

ដូច្នេះ ការចែកចំណែករបស់ X ត្រូវចែកទៅឱ្យ X និង Z តាមសមាមាត្រនៃសិទ្ធិលើបំណុលរបស់ពួកគេ ហើយចំណែកដែលនៅសល់ត្រូវចែកទៅឱ្យ Y និង Z ដូចធម្មតា។

២- ក្នុងករណីធ្វើអនុប្បទាន អនុប្បទាយី បាត់បង់នូវសិទ្ធិ ហើយអនុប្បទានិក ត្រូវទទួលបាននូវសិទ្ធិនោះជំនួសវិញ។ ហេតុដូច្នេះ លទ្ធផល គឺមានដូចខាងក្រោមនេះ :

| សិទ្ធិលើបំណុល | ការចែកចំណែកធម្មតា | ការបោះបង់ហ៊ីប៉ូតែក | អនុប្បទានហ៊ីប៉ូតែក |
|---|---|---|---|
| លោក X : ៤០០ | ៤០០ | ២០០ | ០ |
| លោក Y : ២០០ | ២០០ | ២០០ | ២០០ |
| លោក Z : ៦០០ | ៤០០ (ខ្វះ ២០០) | ៤០០ | ៤០០ |
| លោក A : ៤០០ | ០ (ខ្វះ ៤០០) | ២០០ | ៤០០ |

### ៥-៣ អនុប្បទាន ឬ ការបោះបង់ និង ការផ្លាស់ប្តូរលំដាប់នៃហ៊ីប៉ូតែក មាត្រា ៨៦១

ម្ចាស់បំណុលហ៊ីប៉ូតែក អាចធ្វើអនុប្បទាន ឬ បោះបង់លំដាប់នៃហ៊ីប៉ូតែកបាន ដើម្បី ផលប្រយោជន៍របស់ម្ចាស់បំណុលហ៊ីប៉ូតែកផ្សេងទៀតចំពោះកូនបំណុលតែម្នាក់។ ម្ចាស់បំណុលហ៊ីប៉ូតែក ក៏អាចផ្លាស់ប្តូរលំដាប់នៃហ៊ីប៉ូតែកនោះបានដោយការព្រមព្រៀងជាមួយម្ចាស់បំណុលហ៊ីប៉ូតែកផ្សេងទៀត។ ប៉ុន្តែ បើមានបុគ្គលដែលមានទំនាក់ទំនងនឹងផលប្រយោជន៍ចំពោះការផ្លាស់ប្តូរនោះ ម្ចាស់បំណុលហ៊ីប៉ូតែកត្រូវទទួលការយល់ព្រមពីបុគ្គលនោះ។

ម្ចាស់បំណុលហ៊ីប៉ូតែកដែលទទួលអនុប្បទាននូវលំដាប់នៃហ៊ីប៉ូតែក អាចទទួលការសងដោយមានអាទិភាពជាងម្ចាស់បំណុលហ៊ីប៉ូតែកដែលបានធ្វើអនុប្បទាននូវលំដាប់នោះ នូវចំនួនទឹកប្រាក់នៃ សិទ្ធិលើបំណុលទាំងអស់ពីប្រាក់ដែលបានមកពីការលក់ដោយបង្ខំនូវអចលនវត្ថុហ៊ីប៉ូតែកនោះ ត្រឹមកំរិតនៃចំនួនទឹកប្រាក់សរុបនៃចំណែកដែលត្រូវចែកឱ្យទៅម្ចាស់បំណុលហ៊ីប៉ូតែកទាំងពីរនោះ។

ម្ចាស់បំណុលហ៊ីប៉ូតែកដែលទទួលនូវការបោះបង់លំដាប់នៃហ៊ីប៉ូតែក អាចទទួលការសងដោយ មានសមភាពជាមួយម្ចាស់បំណុលដែលបានបោះបង់លំដាប់ហ៊ីប៉ូតែកនោះ តាមសមាមាត្រនៃចំនួន ទឹកប្រាក់នៃសិទ្ធិលើបំណុលនៅក្នុងទំហំនៃចំនួនទឹកប្រាក់សរុបនៃចំណែកដែលត្រូវចែកឱ្យម្ចាស់បំណុល ហ៊ីប៉ូតែកទាំងពីរនោះ ។

ម្ចាស់បំណុលហ៊ីប៉ូតែកដែលបានព្រមព្រៀងក្នុងការផ្លាស់ប្តូរលំដាប់នៃហ៊ីប៉ូតែក អាចអនុវត្តហ៊ីប៉ូតែកបានតាមការព្រមព្រៀងនោះ ។

អនុប្បទាន និង ការបោះបង់លំដាប់ហ៊ីប៉ូតែក មានលក្ខណៈស្រដៀងគ្នាទៅនឹងទស្សនៈ នៃអនុប្បទាន និង ការបោះបង់ហ៊ីប៉ូតែក។ ប៉ុន្តែអ្វីដែលខុសគ្នានោះ គឺកម្មវត្ថុនៃអនុប្បទាន និង ការបោះបង់លំដាប់ គឺលំដាប់។ ជនដែលបានបោះបង់ ឬ ធ្វើអនុប្បទាននូវលំដាប់នៃផលប្រយោជន៍ របស់ខ្លួន គឺជាម្ចាស់បំណុលហ៊ីប៉ូតែកផងដែរ ។

ឧទាហរណ៍ : លោក X មានហ៊ីប៉ូតែកលំដាប់ទី ១ ចំពោះដី L ដែលបានធានាបំណុលចំនួន ៤០០ ដុល្លារ ។ លោក Y មានហ៊ីប៉ូតែកលំដាប់ទី ២ ដែលបានធានាបំណុលចំនួន ២០០ ដុល្លារ លោក Z គឺជាម្ចាស់បំណុលហ៊ីប៉ូតែកលំដាប់ទី ៣ ដែលមានសិទ្ធិលើបំណុលចំនួន ៦០០ ដុល្លារ។ លោក A ជាម្ចាស់បំណុលដែលមានសិទ្ធិលើបំណុលចំនួន ៤០០ ដុល្លារដោយគ្មានប្រាតិភោគ។ លោក B គឺជា អ្នកបង្កើតហ៊ីប៉ូតែកកូនបំណុលនៃដី L ។ ឧបមាថា តម្លៃនៃដី L គឺមានចំនួន ១ ០០០ ដុល្លារ ។

១- លោក X បានបោះបង់លំដាប់នៃហ៊ីប៉ូតែករបស់ខ្លួនដើម្បីជាប្រយោជន៍របស់លោក Z ហើយការបោះបង់នោះ ត្រូវបានចុះបញ្ជី។ បន្ទាប់មកលោក X បានអនុវត្តហ៊ីប៉ូតែករបស់ខ្លួន។ តើអ្នកណាអាចទទួលនូវការចែកចំណែក ហើយទទួលបានចំនួនប៉ុន្មាន?

២- លោក X បានធ្វើអនុប្បទានលំដាប់នៃហ៊ីប៉ូតែករបស់ខ្លួនដើម្បីប្រយោជន៍របស់លោក Z ហើយអនុប្បទាននេះ ត្រូវបានចុះបញ្ជី។ បន្ទាប់មកលោក Z បានអនុវត្តហ៊ីប៉ូតែកដែលត្រូវបានផ្ទេរ។ តើអ្នកណាអាចទទួលនូវការចែកចំណែក ហើយទទួលបានចំនួនប៉ុន្មាន?

៣- លោក X, Y និង Z បានព្រមព្រៀងគ្នាអំពីការផ្លាស់ប្តូរលំដាប់។ លំដាប់ដែលបាន ព្រមព្រៀងគ្នាថ្មីៗនេះគឺ លោក Y លំដាប់ទី ១ លោក Z លំដាប់ទី ២ និង លោក X លំដាប់ទី ៣ ។ តើអាចធ្វើការចែកចំណែកទៅឱ្យម្ចាស់បំណុលនីមួយៗនោះបានប៉ុន្មានម្នាក់?

**សន្និដ្ឋាន**

១- នៅក្នុងករណីនេះ តាមរយៈការបោះបង់ X និង Z ទទួលការចែកចំណែកតាមសមាមាត្រនៃចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលត្រឹមកំរិតនៃការចែកចំណែកដើមចំពោះពួកគេ (៨០០)។ ហេតុដូច្នេះ ប្រាក់ចំនួន ៣២០ ដុល្លារ នៃប្រាក់ ៨០០ ដុល្លារ ត្រូវចែកទៅឱ្យ X ហើយនៅសល់ចំនួន ៤៨០ ដុល្លារត្រូវចែកទៅ Z ។ ករណីនេះ មានមានផលប៉ះពាល់ដល់ចំនួនប្រាក់ចំណែកចំពោះម្ចាស់បំណុលហ៊ីប៉ូតែកដទៃទៀតនោះទេ (Z) ។

២- មិនដូចការបោះបង់នោះ អនុប្បទានិក ធ្វើលទ្ធកម្មនូវអាទិភាពចំពោះអនុប្បទាយី ហេតុដូច្នេះ ការចែកចំណែកត្រូវចែកទៅឱ្យ Z មុនដើម្បីទទួលនូវការសងសិទ្ធិលើបំណុលរបស់គាត់ ហើយបន្ទាប់មកប្រាក់ដែលនៅសល់ចំនួន ២០០ ដុល្លារ ត្រូវចែកទៅឱ្យ Z ។

៣- ការផ្លាស់ប្តូរលំដាប់ មានអានុភាពនៅក្នុងចំណោមភាគីដែលបានព្រមព្រៀងគ្នា ហើយការចែកចំណែកត្រូវចែកតាមការព្រមព្រៀង ។

| សិទ្ធិលើបំណុល | ចំណែកធម្មតា | ការបោះបង់ | អនុប្បទាន | ការផ្លាស់ប្តូរ |
|---|---|---|---|---|
| លោក X : ៤០០ | ៤០០ | ៣២០ | ២០០ | ទី ៣ = ២០០ |
| លោក Y : ២០០ | ២០០ | ២០០ | ២០០ | ទី ១ = ២០០ |
| លោក Z : ៦០០ | ៤០០ (ខ្វះ ២០០) | ៤៨០ | ៦០០ | ទី ២ = ៦០០ |
| លោក A : ៤០០ | 0 (ខ្វះ ៤០០) | 0 | 0 | 0 |

## ៦- ការរលត់ហ៊ីប៉ូតែក

### ៦-១ សេចក្តីផ្តើម

យោងតាមមាត្រា ៧៦៩-៤ ក្នុងករណីដែលសិទ្ធិលើបំណុលដែលត្រូវបានធានា បានរលត់ ដោយសារការសង ឬ អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល ឬ ហេតុផ្សេងៗទៀត សិទ្ធិប្រាតិភោគ ប្រត្យក្ស ក៏ត្រូវរលត់ដែរ ។ ករណីនេះហៅថា ភាពបន្ទាប់បន្សំនៃសិទ្ធិប្រាតិភោគប្រត្យក្ស។

ប៉ុន្តែ ត្រូវកត់សំគាល់ផងដែរថា សិទ្ធិប្រាតិភោគប្រត្យក្ស មិនរលត់ទេ ប្រសិនបើចំនួននៃ សិទ្ធិលើបំណុលដែលត្រូវបានធានាទាំងអស់មិនរលត់ ។ នេះគេហៅថា អវិភាគភាពនៃសិទ្ធិប្រាតិភោគ ប្រត្យក្ស មាត្រា ៧៧១

### ៦-២ ការសងដោយថ្លៃលក់

ក្នុងករណីដែល តតិយជនដែលទិញកម្មសិទ្ធិ សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគ ចំពោះអចលនវត្ថុហ៊ីប៉ូតែក បានសងថ្លៃលក់នោះទៅម្ចាស់បំណុលហ៊ីប៉ូតែក តាមការទាមទាររបស់ម្ចាស់បំណុលហ៊ីប៉ូតែក ហើយហ៊ីប៉ូតែកត្រូវរលត់សំរាប់តតិយជននោះ ។

ហ៊ីប៉ូតែក នឹងត្រូវរលត់ ប្រសិនបើ តតិយជនដែលបានធ្វើលទ្ធកម្មនៃអចលនវត្ថុហ៊ីប៉ូតែក សងថ្លៃលក់អចលនវត្ថុដែលខ្លួនត្រូវបង់ដើម្បីធ្វើលទ្ធកម្មអចលនវត្ថុនោះ តាមការទាមទាររបស់ ម្ចាស់បំណុលហ៊ីប៉ូតែក ។ មានន័យថា ហ៊ីប៉ូតែកនឹងត្រូវរលត់ ប្រសិនបើ ម្ចាស់បំណុលហ៊ីប៉ូតែក ទាមទារ ឱ្យតតិយជនដែលបានធ្វើលទ្ធកម្មសងថ្លៃលក់អចលនវត្ថុ ហើយតតិយជនដែលបានធ្វើលទ្ធកម្មនោះ សងថ្លៃលក់អចលនវត្ថុ ហើយតតិយជនដែល បានធ្វើលទ្ធកម្មនោះ បានសងថ្លៃលក់តាមការទាមទារ នោះ ។

## ៦-៣ អាជ្ញាយុកាលនៃការរលត់

### ៦-៣-១ មាត្រា ៨៦៥

មាត្រា ៨៦៥ បានបញ្ញត្តថា " ហ៊ីប៉ូតែក មិនត្រូវរលត់ដោយអាជ្ញាយុកាលចំពោះកូនបំណុល និង អ្នកដែលដែលបានបង្កើតហ៊ីប៉ូតែកឡើយ ប្រសិនបើសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែកនោះមិនរលត់ព្រមគ្នាទេ" ។

ដោយហេតុថា ហ៊ីប៉ូតែកបង្កើតឡើងដើម្បីធានាសិទ្ធិលើបំណុលនោះ ហ៊ីប៉ូតែកអាចត្រូវរលត់ ដោយអាជ្ញាយុកាល ក្នុងករណីដែលសិទ្ធិលើបំណុលដែលបានធានា ត្រូវរលត់ (លក្ខណៈបន្ទាប់បន្សំ) ។

ប្រសិនបើ ម្ចាស់បំណុលហ៊ីប៉ូតែក បានធ្វើនីតិវិធីផ្អាកអាជ្ញាយុកាល ចំពោះសិទ្ធិលើបំណុលដែលត្រូវបានធានា (មាត្រា ៤៨៩) ទោះបីជាម្ចាស់បំណុលមិនបានធ្វើនីតិវិធីផ្អាកអាជ្ញាយុកាលចំពោះហ៊ីប៉ូតែកក៏ដោយក៏ហ៊ីប៉ូតែក មិនត្រូវរលត់ដោយឯកឯងឡើងឡើយ យោងតាមមាត្រា ៨៦៥ ។

### ៦-៣-២ ការរលត់ហ៊ីប៉ូតែកដោយលទ្ធកម្មនូវអចលនវត្ថុហ៊ីប៉ូតែកដោយអាជ្ញាយុកាល

ហ៊ីប៉ូតែកត្រូវបានរលត់នៅពេលដែល តតិយជនក្រៅពីកូនបំណុល ឬ អ្នកបង្កើតហ៊ីប៉ូតែក បានបំពេញល័ក្ខខ័ណ្ឌសំរាប់អាជ្ញាយុកាលនៃលទ្ធកម្ម ចំពោះអចលនវត្ថុហ៊ីប៉ូតែក (មាត្រា ៨៦៦ វាក្យខ័ណ្ឌទី ១) ។ បញ្ញត្តិនេះត្រូវបានរៀបចំឡើងដោយសារលទ្ធកម្មកម្មសិទ្ធិដោយអាជ្ញាយុកាល គឺមិនមែនជាលទ្ធកម្មបន្តទេ តែវាជាលទ្ធកម្មកម្មសិទ្ធិដំបូង។ មានន័យថា លទ្ធកម្មកម្មសិទ្ធិតាំងពីដំបូង គឺជាការធ្វើលទ្ធកម្មកម្មសិទ្ធិពេញលេញដោយគ្មានជាប់បន្ទុកដែលមាននោះទេ ។

ឧទាហរណ៍ **ក** បានខ្ចីប្រាក់របស់ **ខ** ដោយដាក់ហ៊ីប៉ូតែកលើអចលនវត្ថុដែលកាន់កាប់ដោយ **គ** ។ ប្រសិនបើ **គ** មិនដឹងថា អចលនវត្ថុនោះមានជាប់បន្ទុកហ៊ីប៉ូតែក ហើយ **គ** បានបំពេញល័ក្ខខ័ណ្ឌនៃការកាន់កាប់ដោយអាជ្ញាយុកាលតាមការកំណត់ក្នុងច្បាប់នោះ **គ** អាចធ្វើលទ្ធកម្មនៃកម្មសិទ្ធិលើអចលនវត្ថុនោះបាន។ ករណីនេះហ៊ីប៉ូតែកត្រូវបានរលត់។

ចំណែកឯ លទ្ធកម្មបន្ត ដូចជា លទ្ធកម្មកម្មសិទ្ធិតាមរយៈការលក់ទិញ ប្រសិនបើ អ្នកទិញបានទិញដីដែលមានជាប់បន្ទុកហ៊ីប៉ូតែក អ្នកទិញនោះអាចធ្វើលទ្ធកម្មកម្មសិទ្ធិដែលមានបន្ទុកហ៊ីប៉ូតែក។ ម្យ៉ាងទៀត ហ៊ីប៉ូតែកគឺជាសិទ្ធិប្រត្យក្ស ហើយត្រូវបានយកមកតតាំងចំពោះតតិយជននៅពេលចុះបញ្ជី។ ដូច្នេះ ទោះបីជា អ្នកទិញមិនបានដឹងអំពីអត្ថិភាពនៃហ៊ីប៉ូតែកក៏ដោយ ក៏ម្ចាស់បំណុលហ៊ីប៉ូតែក អាចអះអាងពីហ៊ីប៉ូតែករបស់ខ្លួនចំពោះអ្នកទិញអចលនវត្ថុដែលជាប់ហ៊ីប៉ូតែកបានដែរ។ ប៉ុន្តែ មានករណីបុគ្គលមួយចំនួន ធ្វើលទ្ធកម្មកម្មសិទ្ធិតាមរយៈការលក់ទិញ តែបែរជាអះអាងថា ខ្លួនបានបំពេញលក្ខខណ្ឌនៃអាជ្ញាយុកាលលទ្ធកម្មនៃកម្មសិទ្ធិនៅពេលជាមួយគ្នានោះ។ នៅក្នុងកណីនេះ តតិយជនអាចធ្វើលទ្ធកម្មនូវកម្មសិទ្ធិ ប៉ុន្តែ ហ៊ីប៉ូតែក មិនត្រូវ រលត់ទេ ប្រសិនបើ

តតិយជនដែលបានធ្វើលទ្ធកម្មនូវអចលនវត្ថុដែលជាប់ហ៊ីប៉ូតែកបានដឹងថា ហ៊ីប៉ូតែកត្រូវបាន បង្កើតឡើងលើ អចលនវត្ថុនោះ ( មាត្រា ៨៦៦ វាក្យខ័ណ្ឌទី ២) ។

# ផ្នែកទី ២

# សិទ្ធិឃាត់ទុក

## ១- និយមន័យ

សិទ្ធិឃាត់ទុក គឺជាសិទ្ធិមួយប្រភេទនៃសិទ្ធិប្រាតិភោគប្រត្យក្សដែលមានបញ្ញត្តនៅក្នុងក្រមរដ្ឋប្បវេណី។ សិទ្ធិនេះសំដៅលើសិទ្ធិដែលអាចឃាត់ទុកនូវវត្ថុមួយបាន រហូតដល់ពេលដែលទទួលបានការសងចំពោះសិទ្ធិលើបំណុល ប្រសិនបើអ្នកកាន់កាប់វត្ថុរបស់អ្នកដទៃ មានសិទ្ធិលើបំណុលដែលបានកើតឡើងដោយទាក់ទងនឹងវត្ថុនោះ (មាត្រា ៧៧៤ នៃក្រមរដ្ឋប្បវេណី)។

ម្ចាស់សិទ្ធិឃាត់ទុក ពុំមានសិទ្ធិទទួលការសងដោយមានអាទិភាពទេ។ ក៏ប៉ុន្តែ បើទោះបីជាមានតតិយជនបានទាមទារឱ្យប្រគល់វត្ថុដែលជាកម្មវត្ថុនៃការឃាត់ទុកនោះក៏ដោយ ក៏ម្ចាស់សិទ្ធិឃាត់ទុកអាចបដិសេធមិនប្រគល់វត្ថុដែលឃាត់ទុកនោះបាន រហូតដល់ពេលដែលខ្លួនបានទទួលការសងនូវសំណងរបស់ខ្លួនរួចហើយ (អានុភាពនៃការឃាត់ទុក)។ ដូច្នេះ ជាលទ្ធផលជាក់ស្តែង ម្ចាស់សិទ្ធិឃាត់ទុកទំនងជាអាចទទួលបាននូវការសងសិទ្ធិលើបំណុលដោយមានអាទិភាពជាងជនដទៃផ្សេងទៀតតាមការជាក់ស្តែង។

## ២- ល័ក្ខខ័ណ្ឌនៃសិទ្ធិឃាត់ទុក

សិទ្ធិឃាត់ទុកអាចកើតមានឡើង លុះត្រាតែមានល័ក្ខខ័ណ្ឌទាំងអស់នេះ :

ការកាន់កាប់វត្ថុរបស់អ្នកដទៃ (ក), សិទ្ធិលើបំណុលបានកើតចំពោះវត្ថុដែលកាន់កាប់នោះ(ខ), សិទ្ធិលើបំណុលដល់ពេលកំណត់ត្រូវសង (គ), និង ការកាន់កាប់ត្រូវបានចាប់ផ្តើមមិនមែនដោយអំពើអនីត្យានុកូល (ឃ)។

### ក- ការកាន់កាប់វត្ថុរបស់អ្នកដទៃ

ម្ចាស់សិទ្ធិឃាត់ទុកអាចឃាត់ទុកនូវវត្ថុរបស់អ្នកដទៃបាន លុះណាតែវត្ថុនោះស្ថិតនៅក្រោមការកាន់កាប់របស់ខ្លួន។ ការកាន់កាប់វត្ថុ គឺសំដៅទៅលើការក្តាប់ទុកនូវវត្ថុ។ មានន័យថា វត្ថុត្រូវស្ថិតនៅក្នុងដៃរបស់ម្ចាស់បំណុល។ ការកាន់កាប់នេះត្រូវតែជាការកាន់កាប់ផ្ទាល់ លើវត្ថុមានរូបប៉ុណ្ណោះ ទោះជាវត្ថុនោះជាចលនវត្ថុ ឬអចលនវត្ថុក៏ដោយ។ សិទ្ធិឃាត់ទុក មិនអាចមានលើវត្ថុដែល មិនស្ថិតនៅក្នុងពាណិជ្ជកម្មឡើយ ដូចជារាងកាយមនុស្សជាដើម។

ឧទាហរណ៍ **ក** និង **ខ** បានបង្កើតកិច្ចសន្យាម៉ៅការដែល **ក** ត្រូវជួសជុលរថយន្តរបស់ **ខ** នៅរោងចក្ររបស់ **ក** ។ ករណីនេះគឺ **ក** កំពុងតែកាន់កាប់រថយន្តរបស់ **ខ** ។

សិទ្ធិឃាត់ទុក ក៏អាចអនុវត្តលើវត្ថុដែលពុំមែនជាកម្មសិទ្ធិរបស់កូនបំណុលបានដែរ។

ឧទាហរណ៍នៃករណីជួសជុលរថយន្តខាងលើ ប្រសិនបើ ខ បានឱ្យ ក ជួសជុលឡានដែលខ្លួនបានជួលពី គ ក៏ ក អាចអនុវត្តសិទ្ធិឃាត់ទុកចំពោះថ្លៃជួសជុលឡាននោះបានដែរ រហូតដល់ពេលដែលទទួលបានសិទ្ធិលើបំណុល (ថ្លៃជួសជុលឡាន)។ ដោយសារសិទ្ធិឃាត់ទុកជាសិទ្ធិប្រត្យក្ស សិទ្ធិឃាត់ទុកមានអានុភាពចំពោះតតិយជន។ ហេតុនេះ ក អាចបដិសេធមិនប្រគល់ឡានដែលបានជួសជុលមិនត្រឹមតែ ខ នោះទេ ថែមទាំងចំពោះ គ ផងដែរ។

ក្នុងករណីដែលម្ចាស់សិទ្ធិឃាត់ទុក បានបាត់បង់នូវការកាន់កាប់វត្ថុឃាត់ទុកនោះសិទ្ធិឃាត់ទុកត្រូវរលត់។ ប៉ុន្តែទោះជាម្ចាស់សិទ្ធិឃាត់ទុក ពុំបានកាន់កាប់វត្ថុឃាត់ទុក ក៏សិទ្ធិនេះនៅតែមានដដែលក្នុងករណីខ្លះដូចជាម្ចាស់សិទ្ធិឃាត់ទុក បានយកវត្ថុនោះទៅបញ្ចាំ ឬ ជួល ដោយមានការយល់ព្រមពីកូនបំណុល (មាត្រា ៧៨០ នៃក្រមរដ្ឋប្បវេណី)។

### ខ- សិទ្ធិលើបំណុលបានកើតចំពោះវត្ថុនោះ

ដើម្បីបង្កើតសិទ្ធិឃាត់ទុក ចាំបាច់ត្រូវមានទំនាក់ទំនងរវាងសិទ្ធិលើបំណុល និង វត្ថុនោះ។

ឧទាហរណ៍ ស្តីពីការជួសជុលរថយន្តក្នុងករណីដែល ខ បានឱ្យ ក ជួសជុលរថយន្តឱ្យ តែនៅពេលដែល ក ជួសជុលរួចហើយ ខ មិនទាន់បង់ថ្លៃជួសជុលរថយន្តទេនោះ។ ករណីនេះ សិទ្ធិលើបំណុលនៃថ្លៃជួសជុលរថយន្តរបស់អ្នកជួសជុលបានកើតមានឡើង។ ដូច្នេះ ក អាចឃាត់ទុករថយន្តដែលបានជួសជុលនោះរហូតដល់ពេលដែលខ្លួនបានទទួលការបង់ថ្លៃជួសជុលរថយន្តដោយអនុវត្តនូវសិទ្ធិឃាត់ទុកចំពោះ ខ ។

### គ- សិទ្ធិលើបំណុលដល់ពេលកំណត់ត្រូវសង

បន្ថែមលើល័ក្ខខ័ណ្ឌទាំងពីរខាងលើ សិទ្ធិឃាត់ទុកត្រូវតែគោរពនូវល័ក្ខខ័ណ្ឌចាំបាច់មួយទៀត គឺសិទ្ធិលើបំណុលដល់ពេលកំណត់ត្រូវសង។ មានន័យថា អ្នកកាន់កាប់វត្ថុដែលមានសិទ្ធិលើបំណុលលើវត្ថុនោះ អាចអនុវត្តសិទ្ធិឃាត់ទុកបាន លុះត្រាតែសិទ្ធិឃាត់ទុកនោះដល់ពេលកំណត់ត្រូវសង (មាត្រា ៧៧៤ កថាខណ្ឌទី ១ វាក្យខណ្ឌទី ២)។

ឧទាហរណ៍ ក្នុងករណីជួសជុលរថយន្តខាងលើ ប្រសិនបើ ក និង ខ បានធ្វើការសន្យាពិសេសថា ខ ត្រូវបង់ថ្លៃជួសជុលរថយន្តក្នុងរយៈពេល ១០ ថ្ងៃបន្ទាប់ពីប្រគល់រថយន្ត។ ករណីនេះ ក មិនអាចអនុវត្តសិទ្ធិឃាត់ទុកលើរថយន្តរបស់ ខ ដើម្បីទាមទារប្រាក់ថ្លៃជួសជុលរថយន្តបានទេ ដោយហេតុថា ថេរវេលានៃការកំណត់អំឡុងពេលបង់ប្រាក់ពុំទាន់មកដល់។

ឧទាហរណ៍មួយទៀត ក និង ខ បានចុះកិច្ចសន្យាភតិសន្យាមួយ។ នៅក្នុងអំឡុងពេលនៃការជួលនោះ ភតិកៈ ខ បានចំណាយប្រាក់ផ្ទាល់ខ្លួនដើម្បីជួសជុលផ្ទះនោះ។ អំឡុងពេលនៃការជួលក៏បានកន្លងផុត ហើយភតិបតី ក បានទាមទារឱ្យប្រគល់ផ្ទះមកវិញ។ ក្នុងករណីនេះ ចំពោះសិទ្ធិទាមទារថ្លៃជួសជុលផ្ទះដែល ខ បានចំណាយ ខ

អាចអនុវត្តសិទ្ធិឃាត់ទុកផ្ទះដែលបានជួសជុលនោះទុកដោយមិនព្រមប្រគល់ទៅឱ្យ ក វិញបាន រហូតដល់ពេលបាន ទទួលសំណងថ្លៃជួសជុលនោះ ។

### ឃ- ការកាន់កាប់បានផ្តើមចេញមិនមែនដោយអំពើអនីត្យានុកូល

សិទ្ធិឃាត់ទុកអាចកើតមានឡើងចំពោះការកាន់កាប់លើវត្ថុដែលកើតចេញពីច្បាប់ ពោលគឺមិនមែន កើតឡើងដោយការកាន់កាប់លើវត្ថុដែលកើតចេញពីអំពើអនីត្យានុកូលនោះទេ ( មាត្រា ៧៧៤ កថាខណ្ឌទី ២) ។

ឧទាហរណ៍ ក បានលួចចិញ្ចៀនដែលខ្លួនចពី ខ ហើយ ក បានជួសជុលចិញ្ចៀននោះ។ ក្រោយមក ខ រកឃើញថា ក គឺជាចោរដែលបានលួចចិញ្ចៀននោះក៏បានទាមទារឱ្យ ក ប្រគល់ចិញ្ចៀនមកវិញ។ ប៉ុន្តែ ក បានបដិសេធមិនព្រមប្រគល់ទេ លុះត្រាតែ ខ បង់ថ្លៃជួសជុលចិញ្ចៀននោះ។ ករណីនេះ ក មិនអាចអនុវត្តសិទ្ធិ ឃាត់ទុកបានទេ ពីព្រោះ ការកាន់កាប់លើចិញ្ចៀននោះ គឺកើតចេញពីអំពើអនីត្យានុកូល ។

## ៣- អានុភាព

### ៣-១ សិទ្ធិឃាត់ទុក

អ្នកកាន់កាប់ អាចឃាត់ទុក ( = រក្សាការកាន់កាប់)នូវវត្ថុ ។

នៅប្រទេសជប៉ុននេះគេហៅថា “ អានុភាពនៃការឃាត់ទុក ” ។ តាមរយៈអានុភាពនេះ កូនបំណុល ត្រូវបានបង្ខំឱ្យអនុវត្ត កាតព្វកិច្ច ដើម្បីទទួលបានមកវិញនូវវត្ថុដែលត្រូវបានកាន់កាប់ ។

### ៣-២ សិទ្ធិទទួលសំណងពីផលដោយមានអាទិភាព

មិនដូច សិទ្ធិប្រាតិភោគប្រត្យក្សដទៃផ្សេងទៀតដូចជា ហ៊ីប៉ូតែក នោះទេ ម្ចាស់សិទ្ធិឃាត់ទុកមិនអាច លក់វត្ថុដែលជាកម្មវត្ថុ នៃសិទ្ធិឃាត់ទុកដើម្បីទទួលប្រាក់ពីវត្ថុនោះបានទេ ។

ប៉ុន្តែ ម្ចាស់សិទ្ធិ អាចទទួលផល និង អាចយកផលនោះមកកាត់សិទ្ធិលើបំណុល យោងតាមមាត្រា ៧៧៥ ។

មាត្រា ៧៧៦ តំរូវឱ្យយកផលនោះ មកកាត់ការប្រាក់ ។ ឧទាហរណ៍យ៉ាងសាមញ្ញនៃផល អាចជាកូនគោ ក្របី និង ថ្លៃឈ្នួលនៅក្នុងករណីដែលកម្មវត្ថុត្រូវបានជួលដោយមានការយល់ព្រមពីកូនបំណុល ។

### ៣-៣ ករណីយកិច្ចរបស់ម្ចាស់សិទ្ធិឃាត់ទុក

ម្ចាស់សិទ្ធិឃាត់ទុកត្រូវកាន់កាប់វត្ថុដែលឃាត់ទុកនោះដោយប្រុងប្រយ័ត្ន ក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត (ម.៧៧៦-១)។ ជាពិសេសជាងនេះទៅទៀត ការជួល ការប្រើប្រាស់ ឬ ការយកវត្ថុនោះ ទៅដាក់ប្រាតិភោគដោយគ្មានការយល់ព្រមពីកូនបំណុលត្រូវបានហាមឃាត់ (មាត្រា ៧៧៦ កថាខណ្ឌទី ២)។

ការបំពានទៅនឹងបញ្ញត្តិនេះ នឹងឈានទៅដល់ការរំលត់សិទ្ធិឃាត់ទុក (មាត្រា ៧៧៦ កថាខណ្ឌទី ៣)។

### ៣-៤ សិទ្ធិទាមទារឱ្យសងសោហ៊ុយមកវិញ

ចំណាយជាចាំបាច់ដែលបានចេញត្រូវសងវិញដោយកម្មសិទ្ធិករនៃវត្ថុ (ម. ៧៧៧-១)។

ចំណាយបង្កើនតម្លៃ ត្រូវសងនៅពេលដែលតម្លៃប្រាក់កំណើននោះនៅតែមាន។ ចំនួនទឹកប្រាក់នៃការសងសោហ៊ុយ គឺជាចំនួនទឹកប្រាក់ដែលបានចំណាយ ឬ ចំនួនទឹកប្រាក់នៃតម្លៃប្រាក់កំណើនដោយផ្អែកលើជំរើសរបស់ម្ចាស់កម្មសិទ្ធិ (ហេតុដូច្នេះ តាមការអនុវត្ត ចំនួនទឹកប្រាក់ដែលមានតម្លៃទាបជាងគេ អាចត្រូវបានសង)។ តុលាការត្រូវផ្តល់ អំឡុងពេលសមរម្យ។

## ៤- អាជ្ញាយុកាលនៃការរំលត់សិទ្ធិ

សិទ្ធិឃាត់ទុក អាចត្រូវបានអនុវត្តតែនៅពេលដែលមានសិទ្ធិលើបំណុលដែលនឹងត្រូវបានធានាតែប៉ុណ្ណោះ។

ប៉ុន្តែការអនុវត្តសិទ្ធិឃាត់ទុក ខុសពីការអនុវត្តសិទ្ធិលើបំណុលនោះតែម្តង (ម.៧៧៨)។ ម្ចាស់បំណុល-ម្ចាស់សិទ្ធិឃាត់ទុក ត្រូវចាត់វិធានការដទៃផ្សេងទៀតដើម្បីផ្អាកអាជ្ញាយុកាល។

## ៥- ការរលត់សិទ្ធិឃាត់ទុក

ដូចដែលបានពន្យល់ ការបំពានមាត្រា ៧៧៦ នឹងនាំឱ្យរលត់សិទ្ធិឃាត់ទុក។

លើសពីនេះ មានមូលហេតុមួយចំនួនដែលនាំឱ្យរលត់សិទ្ធិឃាត់ទុក។

ទី ១ ការរលត់នូវសិទ្ធិលើបំណុលដែលត្រូវបានធានា ក៏ជាមូលហេតុនៃការរំលត់សិទ្ធិឃាត់ទុកដែរ។ ជាថ្មីម្តងទៀត នេះគេហៅថាលក្ខខណៈបន្ទាប់បន្សំនៃសិទ្ធិប្រាតិភោគ។

ទី ២ កូនបំណុល អាចរំលត់សិទ្ធិឃាត់ទុកដោយដាក់ប្រាតិភោគគ្រប់គ្រាន់ផ្សេងទៀត (មាត្រា ៧៧៩)។

ទី ៣ ការបាត់បង់នូវការកាន់កាប់ ក៏នាំឱ្យរលត់សិទ្ធិឃាត់ទុកដែរ ពីព្រោះ ការកាន់កាប់ គឺជាកត្តាយ៉ាងសំខាន់នៃសិទ្ធិឃាត់ទុក។

ករណីលើកលែងចំពោះបញ្ញត្តិនេះ គឺករណីដែលវត្ថុ ត្រូវបានជួល ឬ បញ្ចាំដោយមានការយល់ព្រមពីកូនបំណុល និង ករណីដែលម្ចាស់សិទ្ធិឃាត់ទុក ទទួលបាននូវការកាន់កាប់មកវិញតាមមាត្រា ២៣៧ (សិទ្ធិទាមទារឱ្យប្រគល់វត្ថុកាន់កាប់មកវិញ) មើលមាត្រា ៧៨០ កថាខណ្ឌទី ១ និង ទី ២។

# ផ្នែកទី ៣

# សិទ្ធិលើការបញ្ចាំ

## ១- សេចក្ដីផ្ដើម

ម្ចាស់សិទ្ធិលើការបញ្ចាំ មានសិទ្ធិកាន់កាប់វត្ថុ ដែលបានទទួលពីកូនបំណុល ឬ តតិយជនដើម្បីធានា សិទ្ធិលើបំណុលរបស់ខ្លួន និង ទទួលការសងចំពោះសិទ្ធិលើបំណុលរបស់ខ្លួនពីវត្ថុនោះដោយមានអាទិភាពជាង ម្ចាស់បំណុលផ្សេងទៀត។

## ២-ប្រភេទនៃកម្មវត្ថុនៃសិទ្ធិលើការបញ្ចាំ

យោងតាមមាត្រា ៨១៦ ពាក្យវត្ថុ ត្រូវបានប្រើជាកម្មវត្ថុនៃសិទ្ធិលើការបញ្ចាំ ប៉ុន្តែ មាត្រានេះ ពុំមានការបញ្ជាក់ច្បាស់លាស់ច្រើននោះទេ។ ដូច្នេះ កម្មវត្ថុនៃសិទ្ធិលើការបញ្ចាំ គឺ ចលនវត្ថុ (មាត្រា ៨២៩) អចលនវត្ថុ (មាត្រា ៨៣៤) និង សិទ្ធិលើទ្រព្យសម្បត្តិ (មាត្រា ៨៤០)។

## ៣- លក្ខណៈទូទៅ

### ៣-១ លក្ខខណ្ឌ

មាត្រា ៨១៨-១ ចែងថា សិទ្ធិលើការបញ្ចាំត្រូវកើតឡើង ដោយកូនបំណុល ឬ តតិយជនដែលបានបង្កើត សិទ្ធិលើ ការបញ្ចាំនោះ ប្រគល់វត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំ ទៅឱ្យម្ចាស់សិទ្ធិលើការបញ្ចាំ។

មាត្រានេះ មានន័យថា ការបញ្ចាំកើតឡើងដោយការព្រមព្រៀងរបស់ភាគីតែប៉ុណ្ណោះ ដោយមិនទាមទារ ទំរង់ពិសេសណាមួយនោះទេ។ លើសពីនេះ ការប្រគល់វត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំ ក៏ជាលក្ខខណ្ឌចាំបាច់ ដើម្បីឱ្យការបញ្ចាំមានអានុភាពដែរ។ ព្រោះថា ច្បាប់បានហាមឃាត់អ្នកបង្កើតសិទ្ធិលើការបញ្ចាំ កាន់កាប់វត្ថុ ដែលជាកម្មវត្ថុនៃការបញ្ចាំ ដោយផ្ទាល់។

### ៣-២ ទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានា

សិទ្ធិលើការបញ្ចាំ ត្រូវធានានូវប្រាក់ដើម ការប្រាក់ ប្រាក់ធានាសំណងក្នុងករណីមិនគោរពកិច្ចសន្យា សោហ៊ុយ ដើម្បីអនុវត្តសិទ្ធិលើការបញ្ចាំ សោហ៊ុយដើម្បីថែរក្សាវត្ថុបញ្ចាំ ព្រមទាំងសំណងនៃការខូចខាត ដែលកើតឡើងដោយសារ ការមិនអនុវត្តកាតព្វកិច្ច ឬ វិការៈកំបាំងនៃវត្ថុបញ្ចាំ។

### ៣-៣ អានុភាព

#### ៣-៣-១ សិទ្ធិឃាត់ទុក

ការបញ្ចាំត្រូវធ្វើឡើងដោយការព្រមព្រៀង និង ការប្រគល់វត្ថុបញ្ចាំរបស់អ្នកបង្កើតសិទ្ធិលើការបញ្ចាំ ឬ តតិយជនទៅឱ្យម្ចាស់សិទ្ធិលើការបញ្ចាំ។ ហេតុនេះ ម្ចាស់សិទ្ធិលើការបញ្ចាំត្រូវកាន់កាប់វត្ថុបញ្ចាំ។ ការកាន់កាប់នេះ ធ្វើឱ្យម្ចាស់សិទ្ធិលើការបញ្ចាំមានសិទ្ធិឃាត់ទុកវត្ថុ ព្រោះថា កូនបំណុលត្រូវបានបង្ខំតាមផ្លូវចិត្តឱ្យអនុវត្តកាតព្វកិច្ចរបស់ខ្លួនដើម្បីទទួលបាននូវវត្ថុ បញ្ចាំនោះមកវិញតាមរយៈអានុភាពនេះ។

#### ៣-៣-២ ភាពមានអាទិភាពជាងម្ចាស់បំណុលផ្សេងទៀតពីវត្ថុបញ្ចាំ និង សិទ្ធិទទួលសំណង ពីផលដោយមានអាទិភាព ( មាត្រា ៨២២ )

ម្ចាស់សិទ្ធិលើការបញ្ចាំអាចទទួលផលដែលកើតពីវត្ថុបញ្ចាំ និងអាចយកផលនោះមកកាត់សិទ្ធិលើបំណុលរបស់ខ្លួនដោយមានអាទិភាពជាងម្ចាស់បំណុលផ្សេងទៀតបាន។ ផលដែលបានមកនោះ ត្រូវយកមកកាត់ការប្រាក់នៃសិទ្ធិលើ បំណុលជាមុនសិន ហើយ បើមានសំណល់ត្រូវយកទៅកាត់ប្រាក់ដើម។

#### ៣-៣-៣ ករណីយកិច្ចរបស់ម្ចាស់សិទ្ធិលើការបញ្ចាំ

ម្ចាស់សិទ្ធិលើការបញ្ចាំ ត្រូវកាន់កាប់វត្ថុបញ្ចាំនោះដោយប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត ។ ប្រសិនបើ ម្ចាស់សិទ្ធិលើការបញ្ចាំ មិនគោរពតាមកាតព្វកិច្ចនេះទេ កូនបំណុលអាចទាមទារឱ្យរំលត់សិទ្ធិលើការបញ្ចាំនេះ បាន។ មានន័យថា កូនបំណុល អាចទាមទារឱ្យម្ចាស់សិទ្ធិលើការបញ្ចាំប្រគល់វត្ថុបញ្ចាំមកវិញបានក្នុងករណីបំពានករណីយកិច្ចនេះ។

#### ៣-៣-៤ សិទ្ធិទាមទារឱ្យសងសោហ៊ុយរបស់ម្ចាស់សិទ្ធិលើការបញ្ចាំ

ប្រសិនបើ ម្ចាស់សិទ្ធិលើការបញ្ចាំ បានចេញចំណាយជាចាំបាច់សំរាប់គ្រប់គ្រង និង ថែរក្សាវត្ថុចំពោះវត្ថុបញ្ចាំ ម្ចាស់សិទ្ធិលើការបញ្ចាំនោះ អាចទាមទារឱ្យកម្មសិទ្ធិករនៃវត្ថុនោះ សងនូវចំណាយនោះវិញបាន ( មាត្រា ៨២៤ កថាខណ្ឌទី ១) ។

ប្រសិនបើ ម្ចាស់សិទ្ធិលើការបញ្ចាំបានចេញចំណាយបង្កើនតម្លៃនៃវត្ថុបញ្ចាំ ម្ចាស់សិទ្ធិលើការបញ្ចាំនោះ អាចទាមទារឱ្យកម្មសិទ្ធិករនៃវត្ថុបញ្ចាំនោះ សងនូវចំណាយទាំងអស់ដែលខ្លួនបានចេញ ឬ សងនូវតម្លៃប្រាក់ដែលកើន នោះវិញតាមជម្រើសរបស់ខ្លួនបាន ក្នុងករណីដែលកំណើនតម្លៃនោះនៅតែមាន។ ប៉ុន្តែ តុលាការ អាចកំណត់ពេលសមរម្យ ដើម្បីសង តាមការទាមទាររបស់កម្មសិទ្ធិករបាន ( មាត្រា ៨២៤ កថាខណ្ឌទី ២) ។

### ៣-៤ អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

ការប្រើសិទ្ធិលើការបញ្ចាំ មិនរារាំងដំណើរការនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលឡើយ ។

ការប្រើសិទ្ធិលើការបញ្ចាំ មានន័យខុសគ្នាពីការអនុវត្តសិទ្ធិលើការបញ្ចាំ ដោយសារ ការប្រើសិទ្ធិលើការបញ្ចាំ មិនរារាំងដំណើរការនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល ម្ចាស់សិទ្ធិលើការបញ្ចាំត្រូវចាត់វិធានការដទៃផ្សេងទៀតដើម្បីផ្អាកអាជ្ញាយុកាល ។

### ៣-៥ ការបញ្ចាំបន្ត

#### ៣-៥-១ ការបញ្ចាំបន្តដោយមានការយល់ព្រមពីអ្នកបង្កើតសិទ្ធិលើការបញ្ចាំ

ម្ចាស់សិទ្ធិលើការបញ្ចាំ អាចយកវត្ថុបញ្ចាំនោះ ទៅដាក់បញ្ចាំបន្តទៀតបានដោយទទួលការយល់ព្រមពីអ្នកបង្កើតសិទ្ធិលើការបញ្ចាំនោះ ដើម្បីធានានូវកាតព្វកិច្ចរបស់ខ្លួន ។

#### ៣-៥-២ ការបញ្ចាំបន្តក្រោមការទទួលខុសត្រូវរបស់ម្ចាស់សិទ្ធិលើការបញ្ចាំ

ទោះបីជាគ្មានការយល់ព្រមពីអ្នកបង្កើតសិទ្ធិលើការបញ្ចាំក៏ដោយ ម្ចាស់សិទ្ធិលើការបញ្ចាំអាចយកវត្ថុបញ្ចាំនោះ ទៅបញ្ចាំបន្តទៀតបានទោះបីជាមានករណីប្រធានសក្តិក៏ដោយ ។

ឧទាហរណ៍ : លោក X បានដាក់បញ្ចាំគ្រឿងអលង្ការ J នៅនឹងលោក Y ដើម្បីធានាបំណុលចំនួន ១ ០០០ ដុល្លារ ចំពោះលោក Y ។ លោក Y បានយកគ្រឿងអលង្ការ J ទៅដាក់បញ្ចាំបន្តនៅនឹងលោក Z ដើម្បីធានាបំណុល ចំពោះលោក Z ចំនួន ២ ០០០ ដុល្លារ ដោយគ្មានការយល់ព្រមពីលោក X នោះទេ ។

១- លោក Y មិនបានអនុវត្តកាតព្វកិច្ចរបស់ខ្លួននោះទេ ហើយលោក Z ក៏បានអនុវត្តសិទ្ធិលើការបញ្ចាំបន្តរបស់ខ្លួន ។ តើលោក Z អាចទទួលបានប្រាក់ចំនួនប៉ុន្មាន? ករណីនេះលោក Z អាចទទួលបានប្រាក់ចំនួន ១ ០០០ ដុល្លារ ដែលជាកម្រិតនៃចំនួនទឹកប្រាក់ដែលត្រូវចែកចំណែកទៅឱ្យម្ចាស់សិទ្ធិលើការបញ្ចាំ ។

២- លោក Z បានធ្វើឱ្យគ្រឿងអលង្ការនោះខូចដោយសារតែកំហុសរបស់ខ្លួន ។ តើលោក X អាចទាមទារអ្វី បានពី Y ប្រសិនបើលោក X បាន ដឹងពីករណីនេះ? ករណីនេះ លោក Y ត្រូវទទួលខុសត្រូវចំពោះការខូចខាតនេះ ( មាត្រា ៨២៦ កថាខណ្ឌទី ២) ។

### ៣-៦ ការចាត់កិច្ចសន្យាបញ្ចាំផ្តាច់

ថ្វីត្បិតតែកិច្ចសន្យាបញ្ចាំ ត្រូវបានធ្វើឡើងផ្អែកលើការព្រមព្រៀងរវាងម្ចាស់សិទ្ធិលើការបញ្ចាំ និង អ្នកបង្កើតកិច្ចសន្យាបញ្ចាំតាម "គោលការណ៍ស្វ័យភាពនៃបុគ្គលឯកជន" ប៉ុន្តែច្បាប់បានកំរិតនូវសិទ្ធិមួយចំនួន ចំពោះភាគីនៃការបញ្ចាំ មិនឱ្យបង្កើតនូវកិច្ចសន្យាបញ្ចាំផ្តាច់ដែលបានធ្វើមុនកំណត់ពេលត្រូវសងតាមការ ព្រមព្រៀងរបស់ភាគីទេ បើពុំមានបញ្ញត្តិពិសេសនៅក្នុងក្រមរដ្ឋប្បវេណី ឬ ច្បាប់ផ្សេងទៀត។ មូលហេតុដែល ច្បាប់មិនឱ្យបង្កើត កិច្ចសន្យាបញ្ចាំផ្តាច់នៅមុនកំណត់ពេលត្រូវសង គឺក្នុងគោលបំណងដើម្បីការពារដល់អ្នកបង្កើត សិទ្ធិលើការបញ្ចាំ និង ហាមឃាត់ម្ចាស់សិទ្ធិលើការបញ្ចាំមិនឱ្យទទួលបានផលប្រយោជន៍ច្រើនហួសប្រមាណ។ ផ្ទុយមកវិញ បើកិច្ចសន្យា ឬ សកម្មភាពបង្កើតសិទ្ធិលើការបញ្ចាំដែលនាំឱ្យម្ចាស់សិទ្ធិលើការបញ្ចាំទទួលកម្មសិទ្ធិ លើវត្ថុបញ្ចាំ ឬចាត់ចែងវត្ថុ បញ្ចាំ ធ្វើក្រោយពេលកំណត់សងនៃកិច្ចសន្យាបញ្ចាំ គឺមិនត្រូវបានហាមឃាត់ទេ (ម. ៨២៧)។

## ៤- ការបញ្ចាំចលនវត្ថុ

### ៤-១ លក្ខខណ្ឌតតាំងនៃសិទ្ធិលើការបញ្ចាំ

កិច្ចសន្យាបញ្ចាំចលនវត្ថុ មិនតម្រូវឱ្យមានការចុះបញ្ជីទេ គឺគ្រាន់តែអ្នកបង្កើតសិទ្ធិលើការបញ្ចាំប្រគល់ វត្ថុបញ្ចាំទៅឱ្យម្ចាស់សិទ្ធិលើការបញ្ចាំដើម្បីធ្វើការកាន់កាប់ដោយផ្ទាល់ នោះកិច្ចសន្យាបញ្ចាំនឹងមានអានុភាព ហើយ។ ហេតុដូច្នេះ បើម្ចាស់សិទ្ធិលើការបញ្ចាំបានកាន់កាប់វត្ថុបញ្ចាំជានិរន្តរ៍នៅក្នុងដៃរបស់ខ្លួន ម្ចាស់សិទ្ធិលើ ការបញ្ចាំនឹងអាចយកសិទ្ធិនេះទៅធ្វើការតតាំងជាមួយនឹងតតិយជនបាន (ម. ៨២៩)។

យ៉ាងណាវិញ បើម្ចាស់សិទ្ធិលើការបញ្ចាំបាត់បង់ការកាន់កាប់វត្ថុបញ្ចាំ តាមរយៈការដកហូតរបស់ តតិយជន ម្ចាស់សិទ្ធិលើការបញ្ចាំនៅតែអាចតតាំងជាមួយនឹងតតិយជនដែលបានដកហូតនោះ និង អាចយក វត្ថុបញ្ចាំ មកវិញតាមរយៈបណ្តឹងទាមទារឱ្យប្រគល់វត្ថុកាន់កាប់មកវិញ (មាត្រា ៨៣០)។

ដូច្នេះ លក្ខខណ្ឌតតាំងនៃសិទ្ធិលើការបញ្ចាំ គឺការកាន់កាប់វត្ថុបញ្ចាំ។

### ៤-២ ការប្រើប្រាស់ ឬ ការអាស្រ័យផលលើវត្ថុបញ្ចាំដោយម្ចាស់សិទ្ធិលើការបញ្ចាំ

ជាគោលការណ៍ ម្ចាស់សិទ្ធិលើការបញ្ចាំ មិនអាចយកវត្ថុដែលដាក់បញ្ចាំមកប្រើប្រាស់ដើម្បីជាប្រយោជន៍ ផ្ទាល់ខ្លួន ឬ ជួលបានទេ ប៉ុន្តែបើមានការអនុញ្ញាត និងយល់ព្រមពីសំណាក់អ្នកបង្កើតសិទ្ធិលើការបញ្ចាំ អាចប្រើប្រាស់ និង ជួលវត្ថុបញ្ចាំនោះបាន ព្រោះយើងត្រូវគោរពនូវសេរីភាពនៃឆន្ទៈរបស់បុគ្គលឯកជន។ លើសពីនេះទៅទៀត ដើម្បីជៀសវាងនូវការខូចខាត និង ថែរក្សាវត្ថុបញ្ចាំ ម្ចាស់សិទ្ធិលើការបញ្ចាំអាចប្រើប្រាស់វត្ថុ បញ្ចាំត្រឹមកំរិតចាំបាច់ក្នុងការរក្សាវត្ថុបញ្ចាំនោះ ដោយមិនចាំបាច់មានការយល់ព្រមពីអ្នកបង្កើតសិទ្ធិលើការបញ្ចាំ

ប៉ុន្តែមិនអាចជួលវត្ថុបញ្ចាំបានទេ។ បើម្ចាស់សិទ្ធិលើការបញ្ចាំប្រើប្រាស់ ឬ ជួលវត្ថុបញ្ចាំដោយគ្មាន ការយល់ព្រមពីម្ចាស់សិទ្ធិលើការបញ្ចាំ ឬ មិនមានភាពចាំបាច់ក្នុងការរក្សាវត្ថុបញ្ចាំទេនោះ អ្នកបង្កើតសិទ្ធិលើ ការបញ្ចាំអាចទាមទាររំលត់សិទ្ធិលើការបញ្ចាំបានតាមបញ្ញត្តិនៃមាត្រា ៨៣១ នៃក្រមរដ្ឋប្បវេណី។

### ៤-៣ ការអនុវត្តសិទ្ធិលើការបញ្ចាំដោយសង្ខេប

ការអនុវត្តសិទ្ធិលើការបញ្ចាំដោយសង្ខេបនេះ គឺសំដៅទៅលើការអនុវត្តសិទ្ធិរបស់ម្ចាស់សិទ្ធិលើការបញ្ចាំក្នុងការទទួលបានវត្ថុបញ្ចាំមកធ្វើជាកម្មសិទ្ធិរបស់ខ្លួនតែម្តង តាមរយៈតុលាការ ដោយមិនចាំបាច់ឆ្លងកាត់នីតិវិធីនៃការអនុវត្តដោយបង្ខំ មានន័យថា នៅពេលដល់កំណត់សងសិទ្ធិលើបំណុលហើយ ម្ចាស់សិទ្ធិលើការបញ្ចាំមិនបានទទួលការសងទេ ម្ចាស់សិទ្ធិលើការបញ្ចាំអាចទាមទារឱ្យតុលាការយកវត្ថុបញ្ចាំនោះមកសងខ្លួនផ្ទាល់តែម្តង ដើម្បីកាត់សិទ្ធិបំណុល (ម. ៨៣២)។

បើយើងមើលទៅ វាហាក់បីដូចជាការបញ្ចាំផ្តាច់ដែលក្រមបានហាមមិនឱ្យធ្វើក្នុងមាត្រា ៨២៧ នៃក្រមរដ្ឋប្បវេណីដែរ ប៉ុន្តែការអនុវត្តសិទ្ធិលើការបញ្ចាំចលនវត្ថុដោយសង្ខេបក្នុងមាត្រា ៨៣២ មិនដូចការហាមការបញ្ចាំផ្តាច់ក្នុងមាត្រា ៨២៧ទេ ពីព្រោះ មាត្រា ៨២៧ ហាមមិនឱ្យភាគីធ្វើកិច្ចសន្យាដែលនាំឱ្យ ម្ចាស់សិទ្ធិលើការបញ្ចាំទទួលបាននូវកម្មសិទ្ធិលើវត្ថុបញ្ចាំដោយសកម្មភាពបង្កើតសិទ្ធិលើការបញ្ចាំ ឬ ដោយកិច្ចសន្យាដែលធ្វើនៅមុនពេលកំណត់ត្រូវសង រីឯមាត្រា ៨៣២ វិញគឺម្ចាស់សិទ្ធិលើការបញ្ចាំ ទទួលបាននូវកម្មសិទ្ធិលើវត្ថុបញ្ចាំ មិនមែនដោយសកម្មភាពបង្កើតសិទ្ធិលើការបញ្ចាំ ឬ ដោយកិច្ចសន្យាដែលធ្វើមុនពេលកំណត់ត្រូវសងទេ គឺបានតាមរយៈតុលាការ ហើយត្រូវបំពេញលក្ខខណ្ឌយ៉ាងតឹងរឹងចំនួន ៤ មានដូចជា តាមរយៈតុលាការ មានការវាយតម្លៃត្រឹមត្រូវ ជូនដំណឹងដល់អ្នកបង្កើតសិទ្ធិលើការបញ្ចាំ (កូនបំណុល) និង មានមូលហេតុត្រឹមត្រូវ។ មូលហេតុដែលតម្រូវឱ្យមានមូលហេតុតឹងរឹងយ៉ាងនេះ គឺដើម្បីការពារប្រយោជន៍របស់អ្នកបង្កើតសិទ្ធិលើការបញ្ចាំ និង អ្នកធានាដោយវត្ថុ។

### ៤-៤ លំដាប់នៃសិទ្ធិលើការបញ្ចាំ

ជាធម្មតា នៅពេលដែលយកចលនវត្ថុមួយទៅដាក់បញ្ចាំដើម្បីធានាសិទ្ធិលើបំណុល ចលនវត្ថុនោះត្រូវផ្ទេរឱ្យម្ចាស់បំណុលធ្វើការកាន់កាប់ ហេតុនេះ កូនបំណុលមិនទំនងជាអាចយកចលនវត្ថុនោះទៅដាក់បញ្ចាំទៀតបានទេ។ ប៉ុន្តែ មានករណីខ្លះចលនវត្ថុអាចយកទៅដាក់បញ្ចាំដើម្បីធានាសិទ្ធិលើបំណុលចំពោះម្ចាស់បំណុលច្រើន ដែលជាហេតុនាំ ឱ្យយើងត្រូវគិតពិចារណាពីលំដាប់នៃសិទ្ធិលើការបញ្ចាំ។ ជាគោលការណ៍ លំដាប់នៃសិទ្ធិលើការបញ្ចាំលើចលនវត្ថុ តែមួយដើម្បីធានាសិទ្ធិលើបំណុលច្រើនលំដាប់នៃសិទ្ធិលើការបញ្ចាំនោះត្រូវអនុលោមទៅតាមពេលវេលាដែលបាន បង្កើតសិទ្ធិលើការបញ្ចាំ (ម.៨៣៣)។ ឧទាហរណ៍ **ក** យកកង់ទៅបញ្ចាំ **ខ** ហើយកង់នោះត្រូវបាន យកទៅផ្ញើ **គ** ។ **ក** បានផ្ទេរការកាន់កាប់កង់នោះដោយការបញ្ជាទៅឱ្យ **គ** (មើលមាត្រា ២២៩

កថាខណ្ឌទី ៤)បន្ទាប់មក **ក** យកកង់នោះទៅបញ្ចាំ **ឃ** ទៀត។ ករណីនេះលំដាប់នៃសិទ្ធិលើការបញ្ចាំគឺ **ខ** មានលំដាប់មុន **ឃ** ព្រោះកង់នោះបានយកទៅបញ្ចាំ **ខ** មុន **ឃ** ។

## ៥- ការបញ្ចាំអចលនវត្ថុ

### ៥-១ សិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យផលរបស់ម្ចាស់សិទ្ធិលើការបញ្ចាំ

ជាគោលការណ៍ ម្ចាស់សិទ្ធិលើការបញ្ចាំ មិនអាចយកវត្ថុបញ្ចាំទៅប្រើប្រាស់ ឬ អាស្រ័យផលដោយគ្មានការយល់ព្រមពីអ្នកបង្កើតសិទ្ធិលើការបញ្ចាំ (កូនបំណុល)ទេ ដូចជាការប្រើប្រាស់ចលនវត្ថុដាក់បញ្ចាំ គឺត្រូវមានការយល់ព្រមពីកូនបំណុលដែលមានបញ្ញត្តិក្នុងមាត្រា ៨៣១។ ប៉ុន្តែមានការប្រែប្រួលមួយយ៉ាងខ្លាំងដែលម្ចាស់សិទ្ធិលើការបញ្ចាំ អាចប្រើប្រាស់ និង អាស្រ័យផល ក្នុងករណីដែល វត្ថុដែលជាកម្មវត្ថុនៃសិទ្ធិលើការបញ្ចាំ គឺជាអចលនវត្ថុដោយពុំចាំបាច់មានការយល់ព្រមពីកូនបំណុល (ម. ៨៣៤-១)។ ឧទាហរណ៍ **ក** យកដីស្រែបញ្ចាំ **ខ** ។ **ខ** អាចប្រើប្រាស់ និង អាស្រ័យផលលើដីស្រែនោះ មិនចាំបាច់មានការយល់ព្រមពី **ក** ទេ។

ទោះបីជាម្ចាស់សិទ្ធិលើការបញ្ចាំ អាចប្រើប្រាស់ និង អាស្រ័យផលលើអចលនវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិលើការបញ្ចាំដោយមិនចាំបាច់មានការយល់ព្រមពីកូនបំណុលក៏ដោយ ប៉ុន្តែការប្រើប្រាស់ និងអាស្រ័យផលនោះគឺត្រូវគោរពវិធីនៃការប្រើប្រាស់នៃអចលនវត្ថុនោះ ឬសិទ្ធិលើបំណុលដែលគ្មានកំណត់ពេល និង មានកំណត់ពេល ទាក់ទិននឹងបទបញ្ញត្តិពិសេសស្តីពីដីសំរាប់ធ្វើកសិកម្ម។

### ៥-២ ការគោរពតាមវិធីប្រើប្រាស់ធម្មតា

ម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុ អាចប្រើប្រាស់ និង អាស្រ័យផលលើអចលនវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិលើការបញ្ចាំដើម្បីជាប្រយោជន៍ផ្ទាល់ខ្លួនបានទៅតាមវិធីប្រើប្រាស់នៃអចលនវត្ថុនោះ។ វិធីប្រើប្រាស់ធម្មតានៃអចលនវត្ថុសំដៅលើការប្រើប្រាស់តាមលក្ខណៈដើមនៃអចលនវត្ថុ។ ក្នុងករណីដែលដី គឺសំរាប់ធ្វើកសិកម្ម ត្រូវយកដីនោះទៅធ្វើកសិកម្ម មិនអាចយកដីកសិកម្មទៅធ្វើជាផ្ទះសំរាប់ជួលទេ។ មូលហេតុដែលឱ្យម្ចាស់សិទ្ធិលើការបញ្ចាំត្រូវអនុវត្ត តាមវិធីប្រើប្រាស់ធម្មតានៃអចលនវត្ថុ គឺដើម្បីជៀសវាងនូវការខូចខាតធ្ងន់ធ្ងរដល់កូនបំណុល ក្នុងករណី ម្ចាស់បំណុលកែប្រែ និងផ្លាស់ប្តូរវិធីប្រើប្រាស់នៃអចលនវត្ថុនោះ។

### ៥-៣ បទបញ្ញត្តិពិសេសស្តីពីដីសំរាប់ធ្វើកសិកម្ម

#### ៥-៣-១ សិទ្ធិលើបំណុលដែលគ្មានកំណត់ពេល

បើសិទ្ធិលើបំណុលដែលមានកំណត់ច្បាស់លាស់ ម្ចាស់បំណុលនឹងធ្វើការត្រៀមខ្លួនរួចជាស្រេចក្នុងការប្រគល់ដីសំរាប់ធ្វើកសិកម្មឱ្យទៅកូនបំណុលវិញនៅពេលដល់កំណត់នៃកិច្ចសន្យា ដែលវាមិនធ្វើឱ្យប៉ះពាល់ដល់

ប្រយោជន៍ម្ចាស់បំណុលទេ។ ផ្ទុយមកវិញសិទ្ធិលើបំណុលដែលគ្មានកំណត់ពេល អ្នកធានាដោយវត្ថុ អាចធ្វើការរំលត់ហ៊ីប៉ូតែកនៅពេលណាក៏បាន ដោយអនុវត្តកាតព្វកិច្ចដែលត្រូវបានធានាដោយហ៊ីប៉ូតែក។ ដូច្នេះ បើកូនបំណុលរំលត់ហ៊ីប៉ូតែកក្នុងពេលដែលម្ចាស់បំណុល បានដាំដំណាំនៅលើដីសំរាប់ធ្វើកសិកម្ម ហើយច្បាប់តំរូវឱ្យម្ចាស់បំណុលប្រគល់ដីនោះឱ្យកូនបំណុល វានឹងធ្វើឱ្យប៉ះពាល់ប្រយោជន៍យ៉ាងធ្ងន់ធ្ងរដល់ម្ចាស់បំណុល។ កត្តានេះហើយទើបច្បាប់ផ្តល់សិទ្ធិដល់ម្ចាស់សិទ្ធិលើការបញ្ចាំអាចប្រើដីសំរាប់ធ្វើកសិកម្មនោះ ទោះបីជាសិទ្ធិលើបំណុលត្រូវបានរលត់ដោយការសងចំពោះសិទ្ធិលើបំណុលដែលគ្មានកំណត់ពេលក៏ដោយ បើរដូវប្រមូលផលដំណាំដែលម្ចាស់បំណុលបានសាប ឬ ដាំពីមុននឹងដល់នៅក្នុងអំឡុងពេល ១ ឆ្នាំ រហូតដល់រដូវប្រមូល ផល ( ម. ៨៣៤-២) ។

### ៥-៣-២ សិទ្ធិលើបំណុលដែលមានកំណត់ពេល

ស្តីពីសិទ្ធិលើបំណុលដែលមានកំណត់ពេលច្បាស់លាស់វិញ ទោះបីជាម្ចាស់បំណុលបានសាប ឬ ដាំដំណាំនៅលើដីសំរាប់ធ្វើកសិកម្ម បើពេលកំណត់បានមកដល់ ហើយកូនបំណុលបានសងធ្វើឱ្យសិទ្ធិលើបំណុលបានរលត់ ម្ចាស់បំណុលត្រូវប្រគល់ដីនោះមកឱ្យកូនបំណុលវិញ ម្ចាស់បំណុលមិនអាចអះអាងមិនប្រគល់ដីដោយមូលហេតុរដូវប្រមូលផលនឹងដល់ក្នុងអំឡុងពេល ១ ឆ្នាំ ដូចសិទ្ធិលើបំណុលដែលគ្មានកំណត់ពេលទេ។ ប៉ុន្តែ ប្រសិនបើសិទ្ធិលើបំណុលបានរលត់មុនពេលកំណត់ដោយការសង នោះម្ចាស់សិទ្ធិលើការបញ្ចាំ អាចប្រើដីនោះដើម្បីធ្វើកសិកម្ម បើរដូវប្រមូលផលពីដំណាំដែលខ្លួនបានសាប ឬ ដាំពីមុននឹងដល់ក្នុងអំឡុងពេល ១ ឆ្នាំរហូតដល់រដូវប្រមូលផល ព្រោះសិទ្ធិលើបំណុលបានរលត់មុនពេលកំណត់ និងមិនមែនជាកំហុសរបស់ម្ចាស់បំណុល។

ប៉ុន្តែទោះបីជានៅក្នុងករណីនេះក៏ដោយ ប្រសិនបើ កាលបរិច្ឆេទនៃការកំណត់សងនឹងដល់មុនពេលប្រមូលផល បញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយ ពីព្រោះ ការបាត់បង់នូវការប្រមូលផល គឺអាចរំពឹងបានចាប់តាំងពីពេលចាប់ផ្តើម ( មាត្រា ៨៣៤ កថាខណ្ឌទី ៣ វាក្យខណ្ឌទី ២) ។

### ៥-៤ បន្ទុកសោហ៊ុយគ្រប់គ្រងវត្ថុបញ្ចាំ

ក្រមរដ្ឋប្បវេណីកម្ពុជា តំរូវឱ្យម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុ ( ម្ចាស់បំណុល) ចេញសោហ៊ុយគ្រប់គ្រង និងត្រូវទទួលបន្ទុកផ្សេងៗចំពោះអចលនវត្ថុនោះ ហេតុផលដោយសារតែម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុមានសិទ្ធិប្រើប្រាស់ និងអាស្រ័យផលដែលកើតចេញពីអចលនវត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំនោះ។ ប៉ុន្តែម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុ មិនទទួលខុសត្រូវក្នុងការបង់ពន្ធលើអចលនវត្ថុនោះទេ ពីព្រោះការបង់ពន្ធគឺជាបន្ទុករបស់ម្ចាស់កម្មសិទ្ធិករនៃដី។

## ៥-៥ ការប្រាក់នៃសិទ្ធិលើបំណុល

ម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុ មិនអាចទាមទារការប្រាក់នៃសិទ្ធិលើបំណុលរបស់ខ្លួនបានទេ ពីព្រោះខ្លួនអាចទទួលបាននូវផលប្រយោជន៍ដែលចេញមកពីការប្រើប្រាស់ និង អាស្រ័យផលលើអចលនវត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំនោះហើយ (មាត្រា ៨៣៦ នៃក្រមរដ្ឋប្បវេណី)។

## ៥-៦ ការសន្យាពិសេសនៅក្នុងកិច្ចសន្យាបញ្ចាំ

ដូចដែលបានលើកឡើងហើយថា ម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុអាចប្រើប្រាស់ និង អាស្រ័យផលពីអចលនវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិលើការបញ្ចាំ និងត្រូវចេញសោហ៊ុយគ្រប់គ្រង និង ទទួលបន្ទុកផ្សេងៗ ចំពោះអចលនវត្ថុនោះ ហើយ មិនអាចទាមទារការប្រាក់នៃសិទ្ធិលើបំណុលរបស់ខ្លួនបានទេ ទោះបីយ៉ាងណាក៏ដោយភាគី ទាំងពីរនៃកិច្ចសន្យាបញ្ចាំ អាចធ្វើការព្រមព្រៀងទាក់ទងទៅនឹងលក្ខខណ្ឌទាំងនោះ ដែលផ្ទុយពីនេះ នៅក្នុងកិច្ចសន្យាបញ្ចាំរបស់ខ្លួនបានដោយផ្អែកលើ ការសន្យាពិសេសនៅក្នុងសកម្មភាពបង្កើតសិទ្ធិលើការបញ្ចាំ (មាត្រា ៨៣៧)។

ឧទាហរណ៍ បើសិនជាមានកិច្ចព្រមព្រៀងមួយ ម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុ អាចរួចផុតពីការចេញសោហ៊ុយគ្រប់គ្រង ឬ បន្ទុកផ្សេងទៀតទាក់ទងនឹងអចលនវត្ថុ បើទោះបីជា ម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុមានសិទ្ធិប្រើប្រាស់ និងអាស្រ័យផល។ ដូចគ្នាដែរ បើសិនជាមាន កិច្ចព្រមព្រៀងមួយ ដែលអនុញ្ញាតឱ្យម្ចាស់បំណុលទាមទារការប្រាក់នៃសិទ្ធិលើបំណុល ទោះបីជា ម្ចាស់បំណុលមាន សិទ្ធិប្រើប្រាស់ និង អាស្រ័យផលលើអចលនវត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំក៏ដោយ កិច្ចព្រមព្រៀងនោះ នឹងត្រូវបានទទួលស្គាល់អានុភាព ហើយម្ចាស់បំណុលអាចទាមទារការប្រាក់ នៃសិទ្ធិលើបំណុល នោះបាន។

## ៥-៧ អំឡុងពេលនៃសិទ្ធិលើការបញ្ចាំដែលមានអត្ថិភាព

អំឡុងពេលដែលមានអត្ថិភាពនៃសិទ្ធិលើការបញ្ចាំអចលនវត្ថុ មិនអាចលើសពី ៥(ប្រាំ)ឆ្នាំបានឡើយ។ ប្រសិនបើបានបង្កើតសិទ្ធិលើការបញ្ចាំអចលនវត្ថុវែងជាងអំឡុងពេល ៥ឆ្នាំ អំឡុងពេលត្រូវបន្ថយមកត្រឹម ៥(ប្រាំ) ឆ្នាំ ប៉ុន្តែ កិច្ចសន្យាបង្កើតសិទ្ធិលើការបញ្ចាំអចលនវត្ថុអាចធ្វើបន្តទៀតបាន។ ប៉ុន្តែអំឡុងពេលនៃការបន្តនេះមិនអាច ធ្វើឱ្យលើសពី ៥ (ប្រាំ) ឆ្នាំ គិតចាប់ពីពេលបន្តបានឡើយ (មាត្រា ៨៣៨ នៃក្រមរដ្ឋប្បវេណី)។

### ៥-៤ ការអនុវត្តដូចគ្នានៃបញ្ញត្តិស្តីពីហ៊ីប៉ូតែក

យោងតាមមាត្រា ៨៣៩ នៃក្រមរដ្ឋប្បវេណី បានចែងថា ក្រៅពីបញ្ញត្តិនៃផ្នែកទី៣ ដែលស្តីអំពីការបញ្ចាំអចលនវត្ថុ បញ្ញត្តិនៃជំពូកទី ៥ (ដែលស្តីអំពីហ៊ីប៉ូតែក) ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការបញ្ចាំអចលនវត្ថុ ។

ខាងក្រោមនេះ គឺជាឧទាហរណ៍មួយចំនួនស្តីពីការអនុវត្តដូចគ្នានៃបញ្ញត្តិទាក់ទងនឹងហ៊ីប៉ូតែក ។

បញ្ញត្តិស្តីពីការតតាំងនៃហ៊ីប៉ូតែក ដែលមានចែងនៅក្នុងមាត្រា ៨៤៥ នៃក្រមរដ្ឋប្បវេណី ក៏ត្រូវអនុវត្តដូចគ្នានឹងការបញ្ចាំដែរ ។ ហេតុនេះ ដើម្បីឱ្យការបញ្ចាំមួយអាចតតាំងនឹងតតិយជនបាន សិទ្ធិលើការ បញ្ចាំនោះត្រូវធ្វើឡើងដោយលិខិតយថាភូត និង ត្រូវចុះបញ្ជី ។

ហើយចំពោះទំហំនៃអានុភាពហ៊ីប៉ូតែក ដែលមានចែងនៅក្នុងមាត្រា ៨៤៦ ក៏អនុវត្តដូចគ្នាជាមួយនឹងការបញ្ចាំដែរ ពោលគឺ នៅពេលដែលការបញ្ចាំមួយត្រូវបានបង្កើតឡើងនៅលើដីមួយកន្លែង ការបញ្ចាំនោះមានអានុភាពលើវត្ថុដែលភ្ជាប់នឹងដីនោះរួមទាំងអាគារ ដែលមាននៅលើដីដែលជាប់ការបញ្ចាំនោះផងដែរ ។ ទោះបីជាអាគារនោះត្រូវបានសង់នៅមុនពេល ឬក្រោយពេលបង្កើតសិទ្ធិលើការបញ្ចាំក៏ដោយ ហើយដែលភាគីមិនអាចកំណត់នូវលក្ខខណ្ឌផ្សេងពីនេះនៅក្នុងកិច្ចសន្យាបញ្ចាំរបស់ខ្លួនបានឡើយ (មាត្រា ៨៤៦ នៃក្រមរដ្ឋប្បវេណី) ដោយហេតុថា ជាទូទៅ យោងតាមមាត្រា ១២២ នៃក្រមរដ្ឋប្បវេណី វត្ថុដែលនៅជាប់នឹងដី ឬវត្ថុដែលក្លាយជាភាគមួយនៃដីជាពិសេស អាគារ ឬ សំណង់ដែលសង់នៅលើដីហើយមិនអាចប្តូរកន្លែងបានគឺជាសមាសភាគនៃដី ។ ហេតុនេះ នាំឱ្យសិទ្ធិលើការបញ្ចាំដែលមាននៅលើដីមួយកន្លែងនឹងមានអានុភាពទៅលើអ្វីដែលជា សមាសភាគនៃដីនោះដែរ ។

ទន្ទឹមនឹងនេះ មាត្រា ៨៥១ ដែលស្តីអំពីលំដាប់នៃហ៊ីប៉ូតែក ក៏ត្រូវយកមកអនុវត្តដូចគ្នានឹងការបញ្ចាំដែរ មានន័យថា អាទិភាពនៃសិទ្ធិលើការបញ្ចាំ គឺអាស្រ័យ លើពេលវេលានៃការចុះបញ្ជីសុរិយោដីនៃសិទ្ធិទាំងនោះ ។

ដូចគ្នាដែរ មាត្រា ៨៥២ ទំហំនៃសិទ្ធិលើបំណុលដែលត្រូវធានា ដែលអនុវត្តចំពោះហ៊ីប៉ូតែក ក៏ត្រូវអនុវត្តចំពោះសិទ្ធិលើការបញ្ចាំដែរ ។ មានន័យថា ក្នុងករណីដែលម្ចាស់បំណុលនៃសិទ្ធិលើការបញ្ចាំមានសិទ្ធិទាមទារការប្រាក់ ឬធនលាភផ្សេងទៀត ម្ចាស់បំណុលនៃសិទ្ធិលើការបញ្ចាំអាចអនុវត្តសិទ្ធិលើការបញ្ចាំនោះបានតែចំពោះចំនួននៃការសងដែលដល់កំណត់ពេលសម្រាប់អំឡុងពេល ២ (ពីរ) ឆ្នាំ ចុងក្រោយតែប៉ុណ្ណោះ ។ ប៉ុន្តែចំពោះធនលាភដែលមានពីមុនមក ប្រសិនបើបានចុះបញ្ជីពិសេសក្រោយពីបានដល់ពេលកំណត់ត្រូវសងសិទ្ធិលើការបញ្ចាំនេះអាចអនុវត្តបានចាប់ពីពេលដែលបានចុះបញ្ជីនោះ ។

ការកំណត់ដូច្នេះ ពីព្រោះវាមានភាពចាំបាច់សំរាប់ការពារម្ចាស់បំណុលនៃសិទ្ធិប្រាតិភោគប្រត្យក្សដទៃផ្សេងទៀតដែលស្ថិតនៅក្នុងលំដាប់ទាបជាង ដើម្បីឱ្យដឹងថាតើ នៅសល់ចំនួនប៉ុន្មានដែលមិនត្រូវបានធានា ដើម្បីឱ្យពួកគេដឹងថា តើពួកគេត្រូវឱ្យខ្ចីចំនួនប៉ុន្មាន ។

## ៦- ការបញ្ចាំសិទ្ធិ

ដូចដែលបានដឹងហើយថា ការបញ្ចាំអាចត្រូវបានធ្វើឡើងក្រោមរូបភាពបីយ៉ាងគឺ ការបញ្ចាំចលនវត្ថុ ការបញ្ចាំអចលនវត្ថុ និងការបញ្ចាំសិទ្ធិ។

ការបញ្ចាំចលនវត្ថុ ឬ អចលនវត្ថុ គឺត្រូវយកចលនវត្ថុ ឬ អចលនចវត្ថុនោះ ទៅប្រគល់ឱ្យ ម្ចាស់សិទ្ធិលើការបញ្ចាំ។ ផ្ទុយទៅវិញ ការបញ្ចាំសិទ្ធិ សំដៅលើការដែលកូនបំណុលយកសិទ្ធិលើបំណុលរបស់ខ្លួនដែលមានចំពោះកូនបំណុលទី ៣ ទៅដាក់បញ្ចាំអោយម្ចាស់សិទ្ធិ លើការបញ្ចាំរបស់ខ្លួន ដើម្បីធានានូវការសងបំណុលនោះ។

ឱ. លោក ក ជាម្ចាស់បំណុលរបស់ លោក គ ចំនួន ២០០០ ដុល្លា។ តែ លោក ក ចង់ខ្ចីបំណុលពី លោក ខ ចំនួន ១០០០ ដុល្លា។ បើសិនជា លោក ក គ្មានទ្រព្យអ្វីផ្សេងយកមកបញ្ចាំឱ្យ លោក ខ ដើម្បីធានាបំណុលទេ លោក ក អាច យកសិទ្ធិលើបំណុលរបស់ខ្លួនដែលមានចំពោះ លោក គ ទៅដាក់បញ្ចាំឱ្យ លោក ខ ដើម្បីធានានូវការសងបំណុលដែលខ្លួនមានចំពោះ លោក ខ បាន។

**តើការបញ្ចាំសិទ្ធិលើបំណុលមានសារៈប្រយោជន៍យ៉ាងណា?**




តើការបញ្ចាំសិទ្ធិលើបំណុលមានសារៈប្រយោជន៍យ៉ាងណា?

ឧទាហរណ៍ លោក ក ជាម្ចាស់បំណុលរបស់ លោក គ ចំនួន ២០០០ ដុល្លា។ តែលោក ក ចង់ខ្ចីបំណុលពី លោក ខ ចំនួន ១០០០ ដុល្លា។ លោក ក យកសិទ្ធិលើបំណុលរបស់ខ្លួនដែលមានចំពោះ លោក គ ចំនួន ១០០០ ដុល្លា (ក្នុងចំនួនទឹកប្រាក់ ២០០០ ដុល្លាដែល លោក គ ជំពាក់) ទៅដាក់បញ្ចាំឱ្យ លោក ខ ដើម្បីធានា នូវការសងបំណុលដែលខ្លួនមានចំពោះ លោក ខ។

សារៈប្រយោជន៍ចំពោះ ការបញ្ចាំសិទ្ធិលើបំណុលនេះកើតមាន ចំពោះម្ចាស់សិទ្ធិលើការបញ្ចាំ ជាពិសេសជាទូទៅ នៅពេលដែលមានម្ចាស់បំណុលដទៃផ្សេងទៀតដូចជាលោក **ឃ** និង លោក **ង**។

ក្នុងករណីនេះ បើសិនជា លោក ក យកសិទ្ធិលើបំណុលរបស់ខ្លួន ដែលមានចំពោះ លោក គ ចំនួន ១០០០ ដុល្លា (នៅក្នុងសិទ្ធិលើបំណុល ២០០០ ដុល្លា) ទៅដាក់ឱ្យលោក ខ។ នោះ លោក ខ នឹងទទួលបាន នូវសិទ្ធិជា

អាទិភាពនៃទឹកប្រាក់ចំនួន ១០០០ ដុល្លា ដែលលោក គ សងទៅលោក ក មុន លោក ឃ និង លោក ង ដែលជាម្ចាស់បំណុលធម្មតារបស់លោក ក ។

ប៉ុន្តែ តើម្ចាស់សិទ្ធលើការបញ្ចាំអាចតតាំងចំពោះការបញ្ចាំសិទ្ធិលើបំណុល ចំពោះម្ចាស់បំណុលផ្សេងដទៃទៀតបានយ៉ាងដូចម្តេច? បញ្ហានេះ នឹងលើកយកមកបង្ហាញនៅក្នុងប្រធានបទខាងក្រោមនេះ ។

### ៦-១ លក្ខខណ្ឌសុពលភាពនៃការបញ្ចាំសិទ្ធិលើបំណុលចំពោះគូភាគី

ពាក់ព័ន្ធនឹងការបញ្ចាំសិទ្ធិ ជាទូទៅ ការព្រមព្រៀងត្រូវបានចាត់ទុកថាជាលក្ខខណ្ឌដើម្បីបង្កើតឱ្យមានអានុភាពសំរាប់បង្កើត ពីព្រោះសិទ្ធិ គឺជាទ្រព្យអរូបីយ៍ ហើយមិនអាចប្រគល់បានទេ។ ជាករណីលើកលែង ប្រសិនបើដែលការអនុវត្តសិទ្ធិនោះ តំរូវឱ្យមានការកាន់កាប់នូវឯកសារ ដូចជា មូលប្បទានប័ត្រ ការបង្កើតសិទ្ធិនោះតំរូវឱ្យមានការប្រគល់នូវឯកសារនោះតាមលក្ខណៈនៃការបញ្ចាំ ។

### ៦-២ លក្ខខណ្ឌតតាំងនៃការបញ្ចាំសិទ្ធិលើបំណុលចំពោះតតិយជន

ដើម្បីឱ្យម្ចាស់សិទ្ធិលើបំណុល អាចតតាំងជាមួយនឹងកូនបំណុលទី ៣ (ករណីខាងលើគឺ **គ**) និងតតិយជនផ្សេងទៀត (ករណីខាងលើគឺ **ឃ** និង **ង**)ជនដែលយកសិទ្ធិលើបំណុលដែលមានចំពោះកូនបំណុលទី ៣ ទៅដាក់បញ្ចាំនោះ ត្រូវតែជូនដំណឹងអំពីការបង្កើតសិទ្ធិលើការបញ្ចាំបំណុលរបស់ខ្លួនដល់កូនបំណុលទី ៣ ឬ មានការយល់ព្រមពីកូនបំណុលទី៣នោះ។ ហើយការជូនដំណឹង ឬ ការយល់ព្រមខាងលើនេះ មិនអាចតតាំងចំពោះតតិយជនក្រៅពីកូនបំណុលទី ៣ បានឡើយប្រសិនបើមិនបានធ្វើឡើងដោយលិខិតដែលមានកាលបរិច្ឆេទស្អាត ។

នៅក្នុងករណីខាងលើនេះ ដោយគ្មានការយល់ព្រម ឬ ការជូនដំណឹងណាមួយនោះ លោក **គ** អាចបដិសេធមិនសងទៅលោក **ខ** បាន ពីព្រោះ លោក **ខ** មិនអាចតតាំងសិទ្ធិលើការបញ្ចាំរបស់ខ្លួនចំពោះលោក **គ** បានទេ។ បន្ទាប់មក ដើម្បីឱ្យលោក **ខ** អាចតតាំងសិទ្ធិលើការបញ្ចាំរបស់ខ្លួនចំពោះលោក **គ** លោក **ខ** ត្រូវការនូវការយល់ព្រម ឬ ការជូនដំណឹង ហើយលោក **គ** មិនអាចបដិសេធនូវការសងចំពោះលោក **ខ** បានទេ។

ដោយគ្មានការយល់ព្រម ឬ ការជូនដំណឹងដោយគ្មានកាលបរិច្ឆេទស្អាត លោក **ខ** មិនអាចតតាំងអំពីអាទិភាពរបស់ខ្លួនចំពោះលោក **ឃ** និង លោក **ង** បានទេ ហេតុដូច្នេះ លោក **ឃ** និង លោក **ង** ឧទាហរណ៍ អាចរឹបអូសសិទ្ធិលើបំណុល ហើយទទួលបាននូវការចែកចំណែកតាមសមាមាត្រនៃចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុល ពីព្រោះ លោក **ខ** មិនអាចអះអាងអំពីអាទិភាពរបស់ខ្លួនបាន។ ប្រសិនបើ លោក **ខ** ចង់អះអាងអំពីសិទ្ធិលើការបញ្ចាំរបស់ខ្លួនចំពោះលោក **ឃ** និងលោក **ង** បន្ថែមលើលោក **គ** លោក **ខ** ត្រូវការនូវការជូនដំណឹង ឬ ការយល់ព្រមដោយមានកាលបរិច្ឆេទស្អាត

យោងតាមមាត្រា ៨ នៃច្បាប់ស្តីពីការអនុវត្តន៍ក្រមរដ្ឋប្បវេណី លិខិតដែលមានកាលបរិច្ឆេទស្ថាពរ សំដៅដល់:

ក- លិខិតយថាភូតៈ ចំពោះលិខិតយថាភូត កាលបរិច្ឆេទនៃការធ្វើលិខិតនោះ ត្រូវក្លាយជាកាលបរិច្ឆេទស្ថាពរ ។

ខ- លិខិតឯកជនដែលសារការី ឬ ក្រឡាបញ្ជីតុលាការចុះនិទ្ទេសអំពីកាលបរិច្ឆេទ ដែលខ្លួនត្រូវបានបង្ហាញលិខិតឯកជននេះ និង ចុះហត្ថលេខា ។ ក្នុងករណីនេះ កាលបរិច្ឆេទនោះនឹងត្រូវក្លាយជាកាលបរិច្ឆេទស្ថាពរ ។

គ- លិខិតឯកជនដែលមានជនណាម្នាក់ក្នុងចំណោមជនដែលបានចុះហត្ថលេខាលើលិខិតនោះ បានទទួលមរណៈភាព ។ ក្នុងករណីនេះ ថ្ងៃដែលជននោះទទួលមរណភាពនឹងត្រូវក្លាយជាកាលបរិច្ឆេទស្ថាពរ ។

ឃ- លិខិតឯកជនដែលត្រូវបានយកជាអាគតដ្ឋាន នៅក្នុងលិខិតដែលមានកាលបរិច្ឆេទស្ថាពរ ។ ក្នុងករណីនេះ កាលបរិច្ឆេទនៅក្នុងលិខិតដែលមានកាលបរិច្ឆេទស្ថាពរនោះ នឹងត្រូវក្លាយជាកាលបរិច្ឆេទស្ថាពរសម្រាប់លិខិតឯកជនដែលត្រូវបានយកជាអាគតដ្ឋាននោះ ។

តើលិខិតអ្វីខ្លះ ត្រូវចាត់ទុកជាលិខិតយថាភូតនោះ? មានចែងនៅក្នុង មាត្រា ៩ នៃ ច្បាប់ស្តីពីការអនុវត្តន៍ក្រមរដ្ឋប្បវេណី គឺសំដៅដល់លិខិតដែលធ្វើឡើងដោយសារការី ឬ កុងស៊ុល ឬ ជាលិខិតដែលមន្ត្រីមានសមត្ថកិច្ចធ្វើឡើងដើម្បីធ្វើនីតិវិធីនៃការចុះបញ្ជី ។

## ៦-៣ ការអនុវត្តសិទ្ធិលើការបញ្ចាំដោយប្រមូលសិទ្ធិលើបំណុល

ផ្អែកតាមមាត្រា ៨៤២ កថាខណ្ឌទី ១ ម្ចាស់សិទ្ធិលើការបញ្ចាំ មិនចាំបាច់ដាក់ពាក្យសុំឱ្យអនុវត្តសិទ្ធិប្រាតិភោគដើម្បីប្រមូលប្រាក់នោះទេ ។

ប្រសិនកម្មវត្ថុនៃសិទ្ធិលើបំណុល គឺជាប្រាក់ ទំហំនៃការប្រមូលត្រូវបានកំរិតត្រឹមចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលដែលត្រូវបានធានា ( ប្រៀបធៀបមាត្រា ៨៤២-២) ។

បើការកំណត់ពេលត្រូវសងនៃសិទ្ធិលើបំណុលដែលជាកម្មវត្ថុនៃសិទ្ធិលើការបញ្ចាំបានមកដល់ មុនកំណត់ពេលត្រូវសងនៃសិទ្ធិលើបំណុលរបស់ម្ចាស់សិទ្ធិលើការបញ្ចាំ កូនបំណុលទីពាអាចដាក់ប្រាក់តម្កល់ ហើយសិទ្ធិលើការបញ្ចាំមានអត្ថិភាព លើប្រាក់តម្កល់នោះ ( មាត្រា ៨៤២-៣) ។

ប្រសិនបើ កម្មវត្ថុនៃសិទ្ធិលើបំណុល មិនមែនជាប្រាក់ទេ ម្ចាស់សិទ្ធិលើការបញ្ចាំមានសិទ្ធិលើការបញ្ចាំលើវត្ថុដែលខ្លួនបានទទួលជាការសង ( មាត្រា ៨៤២-៤) ។

| | **ការបញ្ចាំចលនវត្ថុ** | **ការបញ្ចាំអចលនវត្ថុ** | **ការបញ្ចាំសិទ្ធិលើបំណុល** |
|---|---|---|---|
| **កម្មវត្ថុនៃការបញ្ចាំ** | ចលនវត្ថុ | អចលនវត្ថុ | សិទ្ធិលើបំណុល |
| **លក្ខខណ្ឌសុពលភាពនៃកិច្ចសន្យាចំពោះគូរភាគី** | ការព្រមព្រៀង | ការព្រមព្រៀង | ការព្រមព្រៀង |
| **លក្ខខណ្ឌតតាំងនៃកិច្ចសន្យាចំពោះតតិយជន** | ការកាន់កាប់ជានិរន្តរ៍នូវវត្ថុបញ្ចាំនោះ | លិខិតយថាភូត និង ការចុះបញ្ជី សុរិយោដី | ការជូនដំណឹងទៅកូនបំណុលទី ៣ ឬ ការយល់ព្រមពីកូនបំណុល ទី ៣ ដែលត្រូវធ្វើឡើងដោយ លិខិតដែលមានកាលបរិច្ឆេទស្ថាពរ |
| **លំដាប់នៃអាទិភាពក្នុងករណីប្រជែងជាមួយសិទ្ធិប្រត្យក្សផ្សេងទៀត** | អាស្រ័យទៅលើលំដាប់នៃការចាប់ផ្ដើមកាន់កាប់ | អាស្រ័យលើពេលវេលានៃការចុះបញ្ជីសុរិយោដី | អាស្រ័យទៅលើ កាលបរិច្ឆេទស្ថាពរនៃលិខិតជូនដំណឹង នោះ |

# ផ្នែកទី ៤

# ប្រាតិភោគដោយអនុប្បទាន

## ១- សេចក្តីផ្តើម

X គឺជាអ្នកលក់ដុំ ហើយគាត់មានបំណងចង់ខ្ចីប្រាក់ពី Y ។ ជាជំនួសឱ្យការខ្ចីប្រាក់ Y ទាមទារឱ្យដាក់ប្រាតិភោគ ។

X មិនមានអចលនវត្ថុនោះទេ ហេតុដូច្នេះ X មិនអាចបង្កើតហ៊ីប៉ូតែកបានទេ ហើយទ្រព្យសម្បត្តិរបស់គាត់ គឺមានតែទំនិញ ដែលស្តុកទុកនៅក្នុងឃ្លាំងតែប៉ុណ្ណោះ ហើយគាត់មិនអាចធ្វើជំនួញបានទេ ក្នុងករណីដែលគាត់យកទំនិញនៅក្នុងឃ្លាំងនោះទៅដាក់បញ្ចាំឱ្យ Y ដោយសារថា ទំនិញទាំងនោះ គឺជាទំនិញដែលនឹងត្រូវលក់ទៅឱ្យអ្នកលក់រាយ ។

លើសពីនេះ ទំនិញទីមួយៗត្រូវបានប្តូរពីមួយថ្ងៃទៅមួយថ្ងៃ ហេតុដូច្នេះ វាហាក់បីដូចជាមិនអាចយកមកដាក់ជាប្រាតិភោគបានទេ ។ តើ X ត្រូវធ្វើយ៉ាងដូចម្តេច ?

ប្រាតិភោគដោយគ្មានការផ្ទេរការកាន់កាប់ គឺមានសារប្រយោជន៍ចំពោះកូនបំណុល នៅក្នុងករណីដែលកូនបំណុលទទួលផលប្រយោជន៍ពីវត្ថុដែលជាកម្មវត្ថុនៃប្រាតិភោគ ។

ស្តីពីអចលនវត្ថុ ហ៊ីប៉ូតែក អាចត្រូវបានបង្កើតឡើងដោយគ្មានការផ្ទេរការកាន់កាប់ ។

ស្តីពីចលនវត្ថុវិញ ប្រាតិភោគដោយអនុប្បទានអាចត្រូវបានបង្កើតឡើងដោយគ្មានការផ្ទេរការកាន់កាប់ដោយចំពោះ ហើយប្រាតិភោគដោយអនុប្បទាននេះ អាចត្រូវបានបង្កើតឡើងលើចលនវត្ថុច្រើនជាងមួយ ដោយមានការព្រមព្រៀងតែមួយប៉ុណ្ណោះ ដើម្បីឱ្យកូនបំណុលអាចបន្តទទួលផលប្រយោជន៍ពីចលនវត្ថុនោះ ។

ទោះបីមើលទៅ ហ៊ីប៉ូតែក និងប្រាតិភោគដោយអនុប្បទាន មានលក្ខណៈខុសគ្នាក៏ដោយ ក៏មានអ្វីម្យ៉ាងដែលមានលក្ខណៈរួមដែរ។ ឧទាហរណ៍ មានតតិយជនដែលមានផលប្រយោជន៍ត្រឹមត្រូវតាមច្បាប់ចំពោះវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគ។ នៅក្នុងករណីនៃហ៊ីប៉ូតែក មានប្រព័ន្ធចុះបញ្ជីដើម្បីឱ្យតតិយជនដឹងអំពីស្ថានភាពគតិយុត្តនៃវត្ថុដែលជាកម្មវត្ថុ។

ផ្ទុយទៅវិញ ស្តីពីចលនវត្ថុ គ្មានប្រព័ន្ធចុះបញ្ជីដូចគ្នានឹងអចលនវត្ថុ ដើម្បីជូនដំណឹងអំពីស្ថានភាពគតិយុត្តជាសាធារណៈនោះទេ ។ ហេតុដូច្នេះ ចាំបាច់ត្រូវមានវិធាន នៅក្នុងករណីដែលតតិយជនមានការទាក់ទងនឹងផលប្រយោជន៍តាមផ្លូវច្បាប់អំពីកម្មវត្ថុ ដូចជាករណីដែលតតិយជនទិញវត្ថុដែលជាកម្មវត្ថុ ជាពិសេសករណីដែលតតិយជននោះមិនបានដឹងថាវត្ថុនោះ គឺ ជាកម្មវត្ថុនៃប្រាតិភោគ ។

## ២- លក្ខខណ្ឌ

យោងតាម មាត្រា ៨៨៨ និងមាត្រា ៨៨៩ លក្ខខណ្ឌដើម្បីបង្កើតប្រាតិភោគដោយអនុប្បទាន គឺមានដូចខាងក្រោមនេះ :

ក-ចលនវត្ថុមួយ ឬច្រើនជាងមួយ

ក្នុងករណីដែលមានចលនវត្ថុច្រើនជាងមួយ ចលនវត្ថុទាំងនោះត្រូវកំណត់តាមមាត្រដ្ឋាន ដូចជា ប្រភេទនៃចលនវត្ថុ ឬ ទីកន្លែងស្ថិតនៅនៃចលនវត្ថុ ជាចលនវត្ថុផ្គុំគ្នា។ ប្រាតិភោគដោយអនុប្បទានចំពោះចលនវត្ថុផ្គុំគ្នា មានសារៈប្រយោជន៍ក្នុងករណីដែល ជនណាម្នាក់ដូចជា ពាណិជ្ជករ ឬ អាជីវករ ចង់យកទំនិញមកដាក់ជាប្រាតិភោគ ពីព្រោះ ពាណិជ្ជករ ឬ អាជីវករនោះ អាចដាក់ប្រាតិភោគបានតែម្តង។

ខ-ការព្រមព្រៀង

គ-ការផ្ទេរការកាន់កាប់ ដើម្បីតតាំងសិទ្ធិប្រាតិភោគដោយអនុប្បទាន ចំពោះតតិយជន ។

ស្តីពីការផ្ទេរការកាន់កាប់ លក្ខខណ្ឌនេះមិនដកចេញនូវទំរង់ណាមួយ នៅក្នុងចំណោមទំរង់ទាំងបួននៃការផ្ទេរការកាន់កាប់នោះទេ ហេតុដូច្នេះ ការប្តូរលក្ខណៈនៃការកាន់កាប់ អាចបំពេញនូវលក្ខខណ្ឌនេះបាន ។

នៅក្នុងករណីដែល X និង Y បានព្រមព្រៀងគ្នាថា X ត្រូវធ្វើអនុប្បទានកម្មសិទ្ធិនៃចលនវត្ថុនៅក្នុងឃ្លាំងជាប្រាតិភោគ ហើយ X ផ្ទេរការកាន់កាប់ (ដោយប្រយោល) ទៅឱ្យ Y តាមរយៈការប្តូរលក្ខណៈនៃការកាន់កាប់ Y អាចតតាំងអនុប្បទាននេះ ចំពោះតតិយជន ។

## ៣- អានុភាព

### ៣-១ ទំហំនៃអានុភាព

សិទ្ធិប្រាតិភោគដោយអនុប្បទាន មានអានុភាពលើវត្ថុភ្ជាប់នឹងវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគ ដោយអនុប្បទានមុន ឬក្រោយការបង្កើតសិទ្ធិប្រាតិភោគប្រត្យក្ស តាមមាត្រា ៨៩១ កថាខណ្ឌទី ១ ។

ភាគីអាចធ្វើការសន្យាពិសេសដែលផ្ទុយនឹងបញ្ញត្តិមាត្រា ៨៩១ កថាខណ្ឌទី ១ ។

### ៣-២ អានុភាពចំពោះផល

ក្នុងករណីដែល អ្នកបង្កើតប្រាតិភោគដោយអនុប្បទាន ឬ តតិយជនដែលបានទទួលការបញ្ជាពីអ្នកបង្កើតកាន់កាប់វត្ថុដែលជាកម្មវត្ថុដោយចំពោះនោះ អានុភាពមិនមានចំពោះផលឡើយ ។ ចំណុចនេះ គឺជាចំណុចដែលមានលក្ខណៈ ស្រដៀងគ្នាយ៉ាងខ្លាំងទៅនឹងហ៊ីប៉ូតែក ។

មូលហេតុដែលមិនឱ្យមានអានុភាព ព្រោះថា អ្នកបង្កើត និងតតិយជនដែលទទួលការបញ្ជា មានសិទ្ធិប្រើប្រាស់ និងអាស្រ័យផលពីវត្ថុ ដែលខ្លួនកំពុងបានកាន់កាប់ដោយចំពោះ ។

ឧទាហរណ៍ :

លោក X បានយកម៉ូតូជាច្រើនគ្រឿងដែលខ្លួនទុកសំរាប់ជួលឱ្យអ្នកដទៃនោះ ទៅបង្កើតប្រាតិភោគដោយអនុប្បទាន ជាមួយលោក Y ហើយបានផ្ទេរការកាន់កាប់ដោយការព្រមព្រៀង ដើម្បីខ្ចីប្រាក់ពីលោក Y ។ លោក X ជាអ្នកកាន់កាប់ដោយចំពោះ លើម៉ូតូ ដែលជាកម្មវត្ថុ នៃប្រាតិភោគនោះ ។ ហេតុដូច្នេះ លោក X មានសិទ្ធិទទួលផលពីកម្មវត្ថុនោះតាមរយៈការជួលកង់នោះ ហើយលោក Y មិនអាចទទួលផល ដូចជា ថ្លៃឈ្នួលឡើយ ( អានុភាពនៃប្រាតិភោគដោយអនុប្បទាន មិនមានចំពោះផលឡើយ) ។

ផ្ទុយទៅវិញ ក្នុងករណីដែលម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ឬ តតិយជនដែលបានទទួលការបញ្ជាកាន់កាប់វត្ថុដែលជាកម្មវត្ថុដោយចំពោះ មាត្រា ៨២២ (សិទ្ធិទទួលការសងពីផលដោយមានអាទិភាព) ត្រូវយកមកអនុវត្តដូចគ្នា ។ មានន័យថា ផលដែលបានពីកម្មវត្ថុ នៃប្រាតិភោគដោយអានុប្បទាននេះ ត្រូវយកមកកាត់សិទ្ធិលើបំណុលរបស់ម្ចាស់សិទ្ធិ ដោយមានអាទិភាពជាងម្ចាស់បំណុលផ្សេងទៀតបាន ។ ចំពោះ វិធីនៃការកាត់សិទ្ធិលើបំណុលនោះ គឺត្រូវកាត់ការប្រាក់ជាមុនសិន ហើយប្រសិនបើមានសល់ ត្រូវយកទៅកាត់ប្រាក់ដើម ។

### ៣-៣ ឧបាទេសកម្ម

ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន អាចធ្វើឧបាទេសកម្មចំពោះប្រាក់ ឬវត្ថុផ្សេងដទៃទៀត ដែលត្រូវទទួលដោយការលក់ ការបាត់បង់ ឬការខូចខាតនូវវត្ថុដែលជាកម្មវត្ថុនៃប្រាតិភោគដោយអនុប្បទាន ។

មានករណីលើកលែង ចំនួនពីរ ចំពោះបញ្ញត្តិនេះ :

ទី ១ គឺម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានមិនអាចធ្វើឧបាទេសកម្មបានទេ ក្រោយពេលដែលប្រាក់ ឬវត្ថុ ដទៃផ្សេងទៀតនោះ ត្រូវបានសង ឬប្រគល់ទៅឱ្យអ្នកបង្កើត រួចហើយ ។

ទី ២ ក្នុងករណីចលនវត្ថុជុំគ្នា ហើយចលនវត្ថុនោះត្រូវមានគម្រោងលក់តាំងពីដំបូង នូវចលនវត្ថុនេះទៅឱ្យ អ្នកផ្សេងទៀត ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានមិនអាចធ្វើឧបាទេសកម្មបានទេ ។

ឧទាហរណ៍ ១:

លោក X បានយកទំនិញរបស់ខ្លួន ទៅបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទានជាមួយលោក Y ។ ក្រោយមកលោក X បានលក់សាងទំនិញទាំងអស់នោះទៅឱ្យលោក Z ។

ក្នុងករណីនោះ លោក Y អាចធ្វើឧបាទេសកម្មលើប្រាក់ដែលជាថ្លៃសាងទំនិញនោះពីលោក Z បាន ។ ប៉ុន្តែក្នុងករណីដែលប្រាក់នោះត្រូវប្រគល់ទៅឱ្យលោក X ហើយនោះ គឺ លោក Y មិនអាច ធ្វើឧបាទេសកម្មបានទេ ។

ឧទាហរណ៍ ២ :

លោក X បានយកទំនិញរបស់ខ្លួននៅក្នុងឃ្លាំងដែលជាចលនវត្ថុជុំគ្នាដែលត្រូវបានគ្រោងលក់ ទៅបង្កើតប្រាតិភោគដោយអនុប្បទានជាមួយលោក Y ។ នៅក្នុងករណីនេះ អ្វីក៏ដោយដែលចូល ឬ ចេញ ទំនិញដែលមាន

នៅក្នុងឃ្លាំងនាពេលនេះ ត្រូវបានចាត់ទុកថាជា ចលនវត្ថុផ្តុំគ្នា ។ ហេតុដូច្នេះ អានុភាពនៃប្រាតិភោគ មិនមានចំពោះវត្ថុដែលត្រូវបានយកចេញនោះទេ ។

ក្នុងករណីនេះ លោក Y មិនអាចធ្វើឧបាទេសកម្មលើទឹកប្រាក់ដែលបានពីការលក់ទំនិញនោះទេ ។

### ៣-៤ ទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានា

ទំហំនៃសិទ្ធិលើបំណុលដែលត្រូវធានារួមមាន ប្រាក់ដើម ការប្រាក់ ប្រាក់ធានាសំណងក្នុង ករណីបំពានកិច្ចសន្យា សោហ៊ុយដើម្បីអនុវត្តសិទ្ធិប្រាតិភោគដោយអនុប្បទាន សោហ៊ុយដើម្បីថែរក្សាវត្ថុ ព្រមទាំងសំណងនៃការខូចខាតដែលកើតឡើងដោយសារការមិនអនុវត្តកាតព្វកិច្ច ឬ វិការៈកំបាំងនៃវត្ថុដែលជាកម្មវត្ថុយោងមាត្រា ៨៩៥ ។ មានន័យថានៅពេលម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ធ្វើការអនុវត្តសិទ្ធិប្រាតិភោគដោយអនុប្បទានតើទំហំសិទ្ធិលើបំណុលមានដល់កម្រិតណា?ដូចបាន លើកឡើងខាងលើវាមានអានុភាពធានាដល់ ប្រាក់ដើម ការប្រាក់ ប្រាក់ធានាសំណងក្នុងករណីបំពានកិច្ចសន្យា សោហ៊ុយដើម្បីអនុវត្តសិទ្ធិប្រាតិភោគដោយអនុប្បទាន សោហ៊ុយដើម្បីថែរក្សាវត្ថុព្រមទាំងសំណងនៃការខូចខាត ដែល កើតឡើងដោយសារការមិនអនុវត្តកាតព្វកិច្ច ឬ វិការៈកំបាំងនៃវត្ថុដែលជាកម្មវត្ថុ ។មាត្រានេះ ដូចគ្នាជាលក្ខណៈសារធាតុ នឹងបញ្ញត្តិអំពីសិទ្ធិលើការបញ្ចាំមានចែងក្នុងមាត្រា ៨២០ ។

### ៣-៥ ការចាត់ចែងវត្ថុដែលជាកម្មវត្ថុដោយអ្នកធានាដោយវត្ថុ និង ម្ចាស់សិទ្ធិប្រាតិភោគប្រគុំប្រគល់

#### ៣-៥-១ ការចាត់ចែងវត្ថុដែលជាកម្មវត្ថុដោយអ្នកធានាដោយវត្ថុ

##### ៣-៥-១-១ ចលនវត្ថុធម្មតា

នៅក្នុងករណីដែល ចលនវត្ថុត្រូវបានធ្វើអនុប្បទានជាប្រាតិភោគ ចលនវត្ថុនោះ នៅតែអាច ស្ថិតនៅក្រោមការកាន់កាប់របស់អ្នកធានាដោយវត្ថុ ។ នៅក្នុងករណីនេះ ដោយឆ្លៀតឱកាសដែលខ្លួនកំពុងតែ កាន់កាប់ជាក់ស្តែង អ្នកធានាដោយវត្ថុ អាចធ្វើអនុប្បទាននូវចលនវត្ថុនោះទៅឱ្យតតិយជន ឬ ដាក់ជាប្រាតិភោគបាន ។ នៅក្នុងករណីនេះ គេចាំបាច់ត្រូវកំណត់ថាតើ ម្ចាស់សិទ្ធិប្រាតិភោគ ឬ តតិយជន អាចអះអាងអំពីអាទិភាពអំពីចលនវត្ថុចំពោះអ្នកផ្សេងទៀត ។

**ឧទាហរណ៍**

យោងតាមមាត្រា ៨៩៤ បញ្ញាតិ ថាតើតតិយជនបានបំពេញល័ក្ខខណ្ឌនៃលទ្ធកម្មដោយសុចរិតនូវកម្មសិទ្ធិលើចលនវត្ថុដែរឬអត់ ។ នៅក្នុងករណីដែល X បានជំពាក់បំណុល Y, X បានធ្វើអនុប្បទានឡានរបស់ខ្លួនជាប្រាតិភោគ ប៉ុន្តែ X នៅតែបន្តការកាន់កាប់ ហើយ X បានលក់ឡាននោះទៅឱ្យ Z ដែលមិនបានដឹងអំពីការបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាននៅក្នុងករណីនេះ ដោយផ្អែកតាមលទ្ធកម្ម ដោយសុចរិតនូវកម្មសិទ្ធិលើ

អចលនវត្ថុ Z អាចបង្កើតលទ្ធកម្មកម្មសិទ្ធិ ហើយករណីនេះ វាឆ្លុះបញ្ចាំងពីការបាត់បង់ប្រាតិភោគចំពោះ X ។ ក្នុងករណីនេះ Y មិនអាចអនុវត្តសិទ្ធិប្រាតិភោគដោយអនុប្បទាន ចំពោះឡានបាននោះទេ ។ ផ្ទុយទៅវិញ នៅក្នុងករណីដែល Z មិនបានបំពេញលក្ខខណ្ឌលទ្ធកម្មដោយសុចរិត ទេ Y អាចអះអាងពីអាទិភាពជាម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានដោយផ្អែកតាមមាត្រា ៧៧២ ។

តើមានវិធីណាការពារ Y ពីការដែល Z ធ្វើលទ្ធកម្មនូវកម្មវត្ថុ ? មានវិធីដែលអាចធ្វើបាន អាចជាការ ដាក់ជាសញ្ញាសំគាល់លើឡាននោះដើម្បីបង្ហាញថាជាកម្មវត្ថុដោយអនុប្បទាន ។ តាមរយៈការធ្វើបែបនេះ Y អាចធ្វើឱ្យតតិយជនដែលមានបំណងទិញរថយន្តនោះ ជាទុច្ចរិត និងមានកំហុស ។

### ៣-៥-១-២ ចលនវត្ថុផ្តុំគ្នា

នៅក្នុងករណីដែលចលនវត្ថុផ្តុំគ្នា អ្នកធានាដោយវត្ថុអាចចាត់ចែងវត្ថុដែលមានគម្រោង នឹងលក់ដោយសេរីយោងតាមមាត្រា៨៩៤-២ ។

ឧទាហរណ៍ នៅក្នុងករណី X បានជំពាក់បំណុល Y, Xបានធ្វើអនុប្បទានទំនិញក្នុងហាងដែលជាចលនវត្ថុផ្តុំគ្នាជាប្រាតិភោគ ដោយ X នៅតែបន្តការកាន់កាប់ដោយ X បានកាន់កាប់ដោយចំពោះ ហើយ X បានលក់ទំនិញដែលមានគម្រោងនឹងលក់តាំងពីដំបូងនោះទៅឱ្យ Z ដែលបានដឹងអំពីការបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទានដោយ X ។ នៅក្នុងករណីនេះ យោងតាមមាត្រា ៨៩៤ កថាខណ្ឌទី ២ ទោះបីជា Z បានដឹងអំពីអត្ថិភាពនៃសិទ្ធិប្រាតិភោគប្រត្យក្សរបស់ Y ក៏ដោយ ក៏ Z អាចធ្វើលទ្ធកម្មកម្មសិទ្ធិនៃទំនិញបានដែរ ។ នេះក៏ព្រោះតែ ទំនិញទាំងនោះ នឹងលែងជាផ្នែកនៃចលនវត្ថុផ្តុំគ្នា នៅពេលដែលនៅក្រៅទំហំនៃចលនវត្ថុផ្តុំគ្នា ។

### ៣-៥-២ ការចាត់ចែងដោយម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន

ក្នុងករណីដែលវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន ត្រូវបានចាត់ចែងដោយម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានដែលគាត់បានកាន់កាប់ដោយផ្ទាល់ មាត្រា ៨៩៧ ត្រូវយកមកអនុវត្ត ។

នៅក្នុងករណីនៃការចាត់ចែងដោយម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន វាមានលក្ខណៈស្រដៀងគ្នាទៅនឹងការចាត់ចែងវត្ថុដែលជាកម្មវត្ថុដោយអ្នកធានាដោយវត្ថុ គឺបញ្ហានៅត្រង់ថា តើតតិយជន បានបំពេញល័ក្ខខណ្ឌនៃលទ្ធកម្មដោយសុចរិតនូវកម្មសិទ្ធិលើចលនវត្ថុដែរឬអត់ ។ នៅក្នុង ករណីខាងលើ Y បានធ្វើលទ្ធកម្មនូវការកាន់កាប់ទំនិញនៅក្នុងឃ្លាំងពី X, Y ដោយគ្មានការយល់ព្រមពី X បានលក់ទំនិញនោះទៅឱ្យ Z ។ Z មិនបានដឹងថា វត្ថុដែលជាកម្មវត្ថុនៃកិច្ចសន្យាលក់ទិញនេះ ជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគ ដោយអនុប្បទាននោះទេ ។នៅក្នុងករណីនេះ Z អាចទទួលបាននូវកម្មសិទ្ធិនៃចលនវត្ថុនោះដោយស្របច្បាប់ ដោយ X គ្រាន់តែ

អាចទាមទារសំណងពី Y ផ្ទុយទៅវិញ បើសិនជា Z មានកំហុស ឬ ជាជនទុច្ចរិត X អាចទទួលបាននូវចលនវត្ថុនោះត្រឡប់មកវិញ។

### ៣-៦ បញ្ញត្តិពិសេសនៅក្នុងករណីដែលម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានកាន់កាប់វត្ថុដែលជាកម្មវត្ថុ

មាត្រា ៨៩៦ ចែងថា បញ្ញត្តិ មាត្រា ៨២១ អានុភាពនៃការឃាត់ទុក មាត្រា ៨២៣ ករណីយកិច្ចរបស់ម្ចាស់សិទ្ធិលើការបញ្ចាំក្នុងការរក្សាទុកនូវវត្ថុបញ្ចាំ និង មាត្រា ៨២៤ សិទ្ធិទាមទារឱ្យសងសោហ៊ុយរបស់ម្ចាស់សិទ្ធិលើការបញ្ចាំ ត្រូវយកមកអនុវត្តដូចគ្នាចំពោះករណីដែលម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ឬតតិយជនដែលបានទទួលការបញ្ចាំពីម្ចាស់សិទ្ធិនោះ កាន់កាប់ដោយចំពោះនូវវត្ថុដែលជាកម្មវត្ថុ។ មូលហេតុគឺដោយសារ ទំនាក់ទំនងរវាងម្ចាស់សិទ្ធិ និង វត្ថុដែលជាកម្មវត្ថុ គឺ ស្រដៀងគ្នានឹង ទំនាក់ទំនងរវាងម្ចាស់សិទ្ធិលើការបញ្ចាំ និង វត្ថុដែលជាកម្មវត្ថុ។

## ៤-ការអនុវត្តសិទ្ធិប្រាតិភោគដោយអនុប្បទាន

មានវិធីពីរយ៉ាង ក្នុងការអនុវត្តសិទ្ធិប្រាតិភោគដោយអនុប្បទាន។ ទី ១ គឺ ការប្តូរវត្ថុដែលជាកម្មវត្ថុជាប្រាក់ ហើយមួយទៀតគឺ អនុប្បទានជាស្ថាពរ យោងតាមមាត្រា ៨៩៨ កថាខណ្ឌទី ១។ ឧទាហរណ៍ X គឺជាអ្នកលក់ដុំ ហើយគាត់មានបំណងចង់ខ្ចីប្រាក់ពី Y។ Y ទាមទារឱ្យដាក់ប្រាតិភោគ ជំនួសឱ្យការខ្ចីប្រាក់ ។ X មិនមានអចលនវត្ថុនោះទេ ហេតុដូច្នោះ X និង Y បានព្រមព្រៀងគ្នាថា X ធ្វើអនុប្បទានកម្មសិទ្ធិលើចលនវត្ថុនៅក្នុងឃ្លាំងជាប្រាតិភោគ ហើយ X បានផ្ទេរការកាន់កាប់ដោយប្រយោលទៅឱ្យ Y តាមរយៈការប្តូរលក្ខណៈនៃការកាន់កាប់ដើម្បីតតាំងសិទ្ធិប្រាតិភោគដោយអនុប្បទាន ចំពោះតតិយជន។ ចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលដែលត្រូវបានធានា មានចំនួន ២០០ ដុល្លា ប៉ុន្តែ មិនត្រូវបានសងដោយ X នោះទេ។ Y មានបំណងចង់អនុវត្តសិទ្ធិប្រាតិភោគរបស់ ខ្លួន។ ដូចនេះ មានវិធី ២ យ៉ាងដែល Y អាចជ្រើសរើសបាន។

### ៤-១ ការប្តូរជាប្រាក់

ក្នុងករណីដល់កាលបរិច្ឆេទកំណត់សង X មិនសងនោះ Y អាចធ្វើការចាត់ចែងវត្ថុដែលជាកម្មវត្ថុ នោះជាប្រាក់ដោយផ្ទាល់ខ្លួនបាន ដោយគ្រាន់តែជូនដំណឹងទៅអ្នកបង្កើត។

### ៩-២ អនុប្បទានជាស្ថាពរ

ក្រៅពីជម្រើសនៃការចាត់ចែងប្តូរជាប្រាក់ ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានអាចប្រើជម្រើស ដោយធ្វើអនុប្បទានជាស្ថាពរ មានន័យថាយកវត្ថុដែលជាកម្មវត្ថុជាកម្មសិទ្ធិតែម្តង។

### ៩-៣ ករណីយកិច្ចត្រូវបង់ទឹកប្រាក់ដែលលើស

ផ្អែកតាមមាត្រា ៨៩៨ កថាខណ្ឌទី ៣ ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានធ្វើការបង់នូវចំនួនទឹកប្រាក់ដែលលើសពីចំនួនទឹកប្រាក់កាតព្វកិច្ចទៅអ្នកបង្កើតវិញដោយចាត់ទុកជាប្រាក់ជម្រះ ។ មានន័យថា ទោះបីជាម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានប្រើជម្រើសណាមួយក៏ដោយ ក៏ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន មានករណីយកិច្ចត្រូវបង់ចំនួនទឹកប្រាក់ដែលលើសដោយចាត់ជាប្រាក់ជម្រះ បើតម្លៃនៃវត្ថុមានចំនួនលើសទឹកប្រាក់នៃកាតព្វកិច្ចដែលត្រូវសង យោងតាមមាត្រា កថាខណ្ឌទី៣ ។

### ៩-៤ សិទ្ធិទទួលយកមកវិញរបស់អ្នកបង្កើត

ជាគោលការណ៍ ដល់កាលបរិច្ឆេទសង មិនសង នោះ ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានអាចប្រើជម្រើសណាមួយដើម្បីអនុវត្ត ប៉ុន្តែ បើ អ្នកបង្កើតបានសង ទោះបីជានៅក្រោយពេលកំណត់សង ក៏ដោយ ប៉ុន្តែនៅមុនពេលបង់ប្រាក់ដែលលើស នោះ កម្មសិទ្ធិត្រូវផ្ទេរទៅអ្នកបង្កើតវិញ។

ក្រោយដល់ពេលកំណត់សង Y បានជូនដំណឹងទៅ X ហើយបានយកទំនិញនោះពីក្នុងឃ្លាំងដើម្បីវាយតម្លៃ ហើយលក់ទំនិញទាំងនោះ។ មុនពេលបញ្ចប់ការវាយតម្លៃ X ពិតជាមានសំណាងដោយមានទឹកប្រាក់គ្រប់គ្រាន់ដើម្បីសងបំណុល ហើយបានទាមទារឱ្យ Y ប្រគល់ទំនិញនោះត្រឡប់មកវិញ ។ X អាចទាមទារបាន។ ប៉ុន្តែ បើ Y លក់ឱ្យ Z ហើយ X ពុំអាចទាមទារមកវិញទេ ប៉ុន្តែ អាចទាមទារសំណង ពីព្រោះ សិទ្ធិទទួលបានមកវិញ ត្រូវបានរលត់ដោយការបញ្ចប់ការអនុវត្តសិទ្ធិប្រាតិភោគដោយអនុប្បទាន ។

# ផ្នែកទី ៥

## ការធានា

### ១- សេចក្តីផ្តើម

ការធានាគឺជាកិច្ចសន្យាដែលត្រូវបានធ្វើឡើងដោយបុគ្គលដែលមានចែងក្នុងមាត្រា ៩០០ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណីដែលបានបញ្ញត្តិថា *អ្នកធានា បានសន្យាធានាជាមួយនឹងម្ចាស់បំណុលថា ខ្លួនយល់ព្រមអនុវត្តកាតព្វកិច្ចមួយផ្នែក ឬ ទាំងមូលកូនបំណុលដែលមានកាតព្វកិច្ចចម្បង ក្នុងករណីដែលកូនបំណុលដែលមានកាតព្វកិច្ចចម្បង មិនបានបំពេញកាតព្វកិច្ចរបស់ខ្លួនចំពោះម្ចាស់បំណុល*។ ក្នុងករណីប្រសិនបើ ម្ចាស់បំណុលសង្ស័យថា ប្រសិនបើកូនបំណុលដែលមានកាតព្វកិច្ចចម្បង ក្លាយជាអ្នកអសាធនីយ៍ ឬ មិនព្រមអនុវត្តនូវកាតព្វកិច្ចនោះទេ គឺម្ចាស់បំណុល មានកូនបំណុលម្នាក់ទៀត មកជំនួសដែលគេហៅថាអ្នកធានានេះឯង ។

ករណីនេះ ដូចគ្នាទៅនឹងសិទ្ធិប្រាតិភោគប្រត្យក្សដូចជា ហ៊ីប៉ូតែក ប៉ុន្តែមានផ្នែកមួយចំនួនខុសគ្នា។ នៅក្នុងករណីហ៊ីប៉ូតែត ប្រាតិភោគដោយអនុប្បទាន ឬ សិទ្ធិលើការបញ្ចាំ អ្វីដែលធានា គឺមានតំលៃវត្ថុជាក់លាក់ណាមួយ ចំណែកឯអ្នកធានាវិញគឺធានាបំណុលជាមួយ នឹងទ្រព្យសម្បត្តិ របស់ខ្លួននៅក្នុងចំនួនទឹកប្រាក់ដែលត្រូវបានធានា ។

### ២- ការបង្កើតកិច្ចសន្យាធានា

#### ២-១ លក្ខខណ្ឌជាមូលដ្ឋាន

យោងតាមមាត្រា ៩០០ កថាខណ្ឌទី១ ព្រមព្រៀងរវាងបុគ្គលដែលមានចំណងធ្វើជាអ្នកធានា និងម្ចាស់បំណុលគឺ តំរូវអោយមានប៉ុន្តែឆន្ទៈរបស់កូនបំណុលមិនតំរូវអោយមាននោះទេ ។ អាចនិយាយម្យ៉ាងទៀតថាប្រសិនបើកូនបំណុលមិន យល់ព្រមចំពោះការធានា កិច្ចសន្យាធានាក៏អាចយកមកអនុវត្តបានដែរ ។ កិច្ចសន្យាត្រូវបានបង្កើតដោយកិច្ចសន្យាដែល បង្កើតអនុភាពតាមការព្រមព្រៀង រវាងអ្នកធានា និងម្ចាស់បំណុល ។

#### ២-២ ការការពារអ្នកធានា

ដូចដែលបានពន្យល់នៅក្នុងសេក្តីផ្តើមរួចហើយ អ្នកធានា ត្រូវធានាក្នុងទំហំនៃការធានាជាមួយនឹងទ្រព្យសម្បត្តិទាំអស់របស់គាត់ដែលជួនកាលវាជាបន្ទុកមួយយ៉ាងធ្ងន់ចំពោះអ្នកធានា។ ដូច្នេះ ក្រមរដ្ឋប្បវេណីការពារអ្នកធានាដើម្បីកុំឱ្យទទួលនូវការបាត់បង់ដែលមិនអាចរំពឹងទុកតាមវិធីមួយចំនួន ។

### ក- ការផ្តល់ពត៌មានសំខាន់ៗ

យោងតាមមាត្រា ៩០០ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណី គឺក្នុងករណីដែលអ្នកដែលមានបំណងធ្វើជាអ្នកធានា មិនមែនជាអ្នកប្រកបអាជីវកម្មធានានោះទេ ម្ចាស់បំណុលត្រូវផ្តល់ពត៌មានសំខាន់ៗ ស្តីពីការណ៍ដែលអ្នកនោះក្លាយជាអ្នក ធានាទៅអោយអ្នកដែលមានបំណងធ្វើជាអ្នកធានានោះ នឹងត្រូវផ្តល់ឱកាសឱ្យអ្នកនោះគិតពិចារណាអោយបានហ្មត់ចត់ ។ មានន័យថាត់រូវអោយម្ចាស់បំណុលផ្តល់ពត៌មានសំខាន់ៗ នឹងផ្តល់ឱកាសឱ្យអ្នកនោះគិតពិចារណាអោយបានហ្មត់ចត់សំរាប់ អ្នកធានាដែលមិនមែនជាអ្នកមានបទពិសោធន៏ក្នុងការធានា ។ បើពុំបានធ្វើដូចនោះទេ គឺអ្នកធានាអាចលុបចោលកិច្ចសន្យា ធានានោះបាន ។

### ខ- លិខិតជាលាយលក្ខណ៍អក្សរ

យោងតាមមាត្រា ៩០១ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី កិច្ចសន្យាធានាអាចត្រូវបានធ្វើឡើងដោយផ្ទាល់មាត់ ប៉ុន្តែ អ្នកធានា មានសិទ្ធិដកការធានាវិញនៅពេលណាក៏បាន។ ប៉ុន្តែ បើសិនជា អ្នកធានា បានចាប់ផ្តើមអនុវត្តកាតព្វកិច្ចធានាដោយស្ម័គ្រចិត្តហើយនោះ គឺអ្នកធានាមិនអាចដកវិញបានទេ ។ ប៉ុន្តែជាគោលការណ៍កិច្ចសន្យាធានា គឺត្រូវធ្វើជាលាយល័ក្ខណអក្សរ លិខិតជាលាយល័ក្ខណអក្សរនៃការធានា ត្រូវបានបញ្ជាក់ឱ្យច្បាស់លាស់ អំពីខ្លឹមសារនៃកាតព្វកិច្ចធានា ។

### គ- ការសសេរអក្សរដោយផ្ទាល់ដៃ

យោងតាមមាត្រា ៩០១ កថាខណ្ឌទី២ កិច្ចសន្យាធានាគឺបើកាតព្វកិច្ចធានាជាកាតព្វកិច្ចដែល មានគោលបំណង អោយសងជាប្រាក់នោះ គឺចំនួនទឹកប្រាក់នៃកាតព្វកិច្ចធានាត្រូវសសេរជាអក្សរដោយផ្ទាល់ដៃរបស់អ្នកធានា ។ មានន័យថា ចំនួនទឹកប្រាក់នៃកាតព្វកិច្ចធានាវិញនោះ គឺដើម្បីបង្ហាញថា ជាការសម្រេចចិត្តយ៉ាងហ្មត់ចត់ និងច្បាស់លាស់របស់អ្នកធានា ហេតុនេះគឺត្រូវទាមទារឱ្យសសេរចំនួនទឹកប្រាក់ដោយផ្ទាល់ដៃដែលនេះជាចំនុចដែលសំខាន់មួយ ដើម្បីឱ្យអ្នកធានាទទួលស្គាល់ ចំណងនៃកិច្ចសន្យាធានា។ ដូច្នេះក្នុងករណីនៃការធានាកាតព្វកិច្ចដែលជាទឹកប្រាក់នោះ បើអ្នកធានាមិនបានសសេរនូវចំនួនទឹកប្រាក់នៃកាតព្វកិច្ចដោយផ្ទាល់ដៃទេនោះ គឺកាតព្វកិច្ចធានា អ្នកធានាអាចដកកិច្ចសន្យាធានានោះបាន ។

## ៣- អានុភាពនៃកិច្ចសន្យាធានា

### ៣-១ ទំហំកាតព្វកិច្ចធានា

ជាទូទៅកិច្ចសន្យាធានាត្រូវរាប់បញ្ចូលទាំងការប្រាក់ ប្រាក់ធានាសំណងក្នុងករណីបំពានកិច្ចសន្យា និងសំណងតាម ការខូចខាត ដែលទាក់ទង និងកាតព្វកិច្ចចម្បង និងអ្វីដែលកើតឡើងបន្ទាប់បន្សំ ពីកាតព្វកិច្ច

ចម្បងនោះ ដោយគ្មានការសន្យា ពិសេសណាមួយ ។ លើសពីនេះ កិច្ចសន្យាធានា អាចបញ្ជាក់ពីចំនួនប្រាក់ធានាសំណងក្នុងករណីបំពានកិច្ចសន្យា និងសំណងអំពី ការខូចខាតចំពោះការមិនអនុវត្តកាតព្វកិច្ច នៃកិច្ចសន្យាធានាក្រៅពីការមិនអនុវត្តកាតព្វកិច្ចចម្បង ។ ដោយយោងតាម មាត្រា ៩០៣ កថាខណ្ឌទី១ អ្នកធានាត្រូវបានរាប់បញ្ចូលកាតព្វកិច្ចធានានូវប្រាក់ នោះជាការប្រាក់បំពានសំណងក្នុងករណី ដែលបានបំពានកិច្ចសន្យាធានា និងសំណងការខូចខាតដែលទាក់ទងនឹងកាតព្វកិច្ចចម្បង ព្រមទាំងអ្វីដែលកើតឡើងបន្ទាប់បន្សំ ពីកាតព្វកិច្ចចម្បងនេះ ។ ប្រសិនបើភាគីនៃកិច្ចសន្យា ពិសេសផ្សេងទៀត ត្រូវអនុលោមតាមការសន្យាពិសេសនេះ ។

បើយោងតាមមាត្រា ៩០៣ កថាខណ្ឌទី២ គឺកិច្ចសន្យាធានា អាចកំណត់នូវចំនួនទឹកប្រាក់ធានាសំណងក្នុងករណី បំពានកិច្ចសន្យា ឬប្រាក់សំណងការខូចខាតចំពោះការមិនអនុវត្តកាតព្វកិច្ចធានាដាច់ដោយឡែកបានពីកាតព្វកិច្ចចម្បង ។

ឧទាហរណ៍ : A មានកាតព្វកិច្ចចំនួន ១០,០០០ ដុល្លាអាមេរិកចំពោះ B ។ ការប្រាក់ និងប្រាក់សំណង (ក្នុងករណី យឺតយ៉ាវ) ត្រូវបានព្រមព្រៀងគ្នារវាង១ខ្លួន គឺចំនួន ៧% ។

- C មិនត្រឹមតែធានាចំពោះប្រាក់ដើមចំនួន១០,០០០ ដុល្លាទេគឺថែមទាំងការប្រាក់និងប្រាក់ធានាសំណងក្នុងករណី បំពានកិច្ចសន្យាដែលអាចមានថែមទៀតផង ក្នុងករណីប្រសិនបើ C និង A បង្កើតកិច្ចសន្យាធានាដោយគ្មានការសន្យា ពិសេសណាមួយនោះ ។

- តាមរយៈកិច្ចសន្យាពិសេស C អាចធានានៃប្រាក់ដើម ឬការប្រាក់ដែលអាចមានតែប៉ុណ្ណោះ ។

- ក៏ដូចជា ការធានាមួយផ្នែក C និង A អាចសន្យាពិសេសស្តីពីការប្រាក់យឺតយាវចំពោះការមិនអនុវត្តកាតព្វ កិច្ចរបស់ខ្លួនបាន។ ឧទាហរណ៍ A និង C អាចសន្យាថា C ត្រូវបង់ការប្រាក់ចំនួន ១0% ចំពោះការយឺតយាវនៃកាតព្វកិច្ចធានា។ ក្នុងករណីនេះគឺ C មានកាតព្វកិច្ចបង់ប្រាក់ចំនួន ១0 000 ដុល្លាដែលជាប្រាក់ដើមការប្រាក់ចំនួន ៥% និងការប្រាក់ក្នុងការ យឺតយាវចំនួន ៧% ដែលកើតចេញពីប្រាក់ដើម និងប្រសិនបើ គាត់ធ្វើឱ្យយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ចធានា គាត់ត្រូវបង់ ការប្រាក់ចំនួន ១0% ចំពោះការយឺតយាវនៃកាតព្វកិច្ចធានា ។

## ៣-២ លក្ខណៈនៃកាតព្វកិច្ចធានា

យោងតាមមាត្រា ៩០៤ កថាខ័ណ្ឌទី១ បញ្ជាក់ថា *កិច្ចសន្យាធានាមិនអាចកើតឡើងបាន ឡើយនៅក្នុងករណីដែលគ្មានកាតព្វកិច្ចចម្បងទេ* ។ គឺមានការបញ្ជាក់យ៉ាងច្បាស់លាស់អំពីលទ្ធផលមួយចំនួនដែលកើតឡើងដោយសារលក្ខណៈនៃកាតព្វកិច្ចធានា ដែលត្រូវបានគេហៅថា ជាកាតព្វកិច្ចបន្ទាប់បន្សំនៃកាតព្វកិច្ចចម្បង ។ម្យ៉ាងទៀត មានកិច្ចសន្យាធានាការខូចខាតដែលមិនមានភាពបន្ទាប់បន្សំ ។

អ្នកធានាក៏មិនត្រូវមានកាតព្វកិច្ចធានាធ្ងន់ធ្ងរជាងកាតព្វកិច្ចចម្បងរបស់កូនបំណុលដែរ ។ ( ៩០៤ កថាខ័ណ្ឌទី២) ក្នុងករណីដែលកាតព្វកិច្ចចម្បងរលត់កាតព្វកិច្ចធានាក៏ត្រូវរលត់ផងដែរ ព្រោះការអនុវត្តកាតព្វកិច្ចធានាគឺជាការធានាកាតព្វកិច្ចចម្បង ហេតុនេះ បើកាតព្វកិច្ចចម្បងរលត់ដោយសារមូលហេតុណាមួយនោះគឺ កាតព្វកិច្ចធានាក៏រលត់តាម ផងដែរ ។ ( ៩០៤ កថាខ័ណ្ឌ ទី ៣)

ដើម្បីកុំឱ្យកាតព្វកិច្ចធានារលត់មុនកាតព្វកិច្ចចម្បង ហើយដើម្បីឱ្យអាចប្រមូលសិទ្ធិលើបំណុលចម្បងបាននោះ គឺការផ្អាកអាជ្ញាយុកាលចំពោះកូនបំណុលដែលមាន កាតព្វកិច្ចចម្បង ដូចជាការទាមទារឱ្យកូនបំណុលអនុវត្តក៏មាន អានុភាពចំពោះអ្នកធានាដែរ ។ ( ៩០៤ កថាខ័ណ្ឌទី៤)

ក្នុងករណីដែលសិទ្ធិលើបំណុលដែលមានកាតព្វកិច្ចធានា ត្រូវបានធ្វើអនុប្បទាន នោះការចាត់ចែង ចំពោះអ្នកធានានូវសិទ្ធិលើបំណុល ត្រូវបានអនុលោមតាមឆន្ទៈរបស់ភាគីនៃកិច្ចសន្យាអនុប្បទានសិទ្ធិលើបំណុល នោះ ។ តាមទំនៀមទំលាប់នៃកិច្ចការជំនួញ ការធ្វើអនុប្បទានព្រមគ្នានូវសិទ្ធិលើបំណុលចំពោះអ្នកធានា ដែលជាសិទ្ធិបន្ទាប់បន្សំផងដែរ ។

### ៧-៣ សិទ្ធិរបស់អ្នកធានា

មូលហេតុមួយចំនួនទាក់ទងនឹងកាតព្វកិច្ចចម្បង គឺមានឥទ្ធិពលទៅលើកាតព្វកិច្ចធានា។ ចំណុចនេះក៏ឆ្លុះបញ្ចាំងអំពីលក្ខណៈបន្ទាប់បន្សំនៃកាតព្វកិច្ចធានាផងដែរ។

សូមមើលឧទាហរណ៍មួយចំនួន :

អង្គហេតុជាមូលដ្ឋាន X មានសិទ្ធិលើបំណុលចំពោះ Y ហើយ Z គឺជាអ្នកធានាកាតព្វកិច្ចរបស់ Y ។

១- ក្នុងករណីដែលអំឡុងពេលអាជ្ញាយុកាលនៃកាតព្វកិច្ចចម្បងត្រូវបានបញ្ចប់ Z ក៏អាចលើកឡើងពីអាជ្ញាយុកាលដើម្បីរលត់កាព្វកិច្ចធានាបានដែរតាមមាត្រា ៩០៥ កថាខណ្ឌទី ១។

២- នៅក្នុងករណីទី ១ ទោះបីជា X បោះបង់ចោលនូវផលប្រយោជន៍នៃអាជ្ញាយុកាល Z នៅតែអាចលើកឡើងពីអាជ្ញាយុកាលដើម្បីផលប្រយោជន៍របស់ខ្លួនគាត់ផ្ទាល់ តាមមាត្រា ៩០៥ កថាខណ្ឌទី ២។

៣- នៅក្នុងករណីដែល Y មានសិទ្ធិតវ៉ាដូចជា ការតវ៉ាឱ្យអនុវត្តព្រមគ្នា Z ក៏អាចអះអាងអំពីសិទ្ធិដូចគ្នាតាមមាត្រា ៩០៥ កថាខណ្ឌទី ៣។ ដូចគ្នានេះដែរ ក្នុងករណីដែល Yមានសិទ្ធិលើបំណុលចំពោះ X, Z ក៏អាចបដិសេធមិនព្រមសងត្រឹមកំរិតដែលកាតព្វកិច្ចចម្បងបានរលត់ ដោយការទូទាត់ តាមមាត្រា ៩០៥ កថាខណ្ឌទី ៥។

៤- ក្នុងករណីដែល Y ទទួលបន្ទុកករណីយកិច្ចដោយសារការគំរាមកំហែង ការឆបោក ជាដើមរបស់ X ប៉ុន្តែមិនទាន់ត្រូវបានលុបចោលនៅឡើយ Z អាចបដិសេធមិនព្រមសងកាតព្វកិច្ចធានាតាមមាត្រា ៩០៥ កថាខណ្ឌទី ៤។

**កំណត់សំគាល់ ១ :**

Z អាចបដិសេធមិនព្រមសង ប៉ុន្តែ Z មិនអាចអនុវត្តសិទ្ធិលុបចោលបានទេ ពីព្រោះវាអាស្រ័យទៅលើកូនបំណុលដែលមានកាតព្វកិច្ចចម្បងថាតើកូនបំណុលចម្បងត្រូវលុបចោល ឬ មិនលុបចោលនោះ ដោយឈរលើទស្សនៈនៃគោលការណ៍ស្វ័យភាពនៃបុគ្គលឯកជន។

**កំណត់សំគាល់ ២ :**

ក្នុងករណីដែល Z បានដឹងថា កិច្ចសន្យារវាង X និង Y អាចលុបចោលបាន ហើយបានធានាកាតព្វកិច្ចជាផ្នែកមួយនៃជំនួញរបស់គាត់ Z ត្រូវទទួលបន្ទុកករណីយកិច្ចដាច់ដោយឡែកចំពោះកម្មវត្ថុដូចគ្នានៃកាតព្វកិច្ចចម្បងតាមមាត្រា ៩០៦។

### ៧-៤ លក្ខណសម្បត្តិរបស់អ្នកធានា

ក្នុងករណីដែលកូនបំណុល ទទួលបន្ទុកនូវករណីយកិច្ចត្រូវរកអ្នកធានា អ្នកធានានេះ ត្រូវតែជាសមត្ថជន និងមានសាធនភាពដើម្បីសងបំណុល យោងតាមមាត្រា ៩០៧ កថាខណ្ឌទី ១ ហើយ ម្ចាស់បំណុលអាចទាមទារឱ្យកូនបំណុលដាក់ប្រាតិភោគផ្សេងទៀតបាន តាមមាត្រា ៩០៧ កថាខណ្ឌទី ៣។

ក្នុងករណីដែលអ្នកធានា បានបាត់បង់នូវលក្ខណសម្បត្តិ ម្ចាស់បំណុល អាចទាមទារឱ្យកូនបំណុលរកអ្នកធានាផ្សេងទៀតដែលមានលក្ខណៈសម្បត្តិដូចខាងលើមកជំនួសបាន តាមមាត្រា ៩០៧ កថាខណ្ឌទី ២។

គោលបំណងនៃបញ្ញត្តិទាំងនេះ គឺថា កូនបំណុលត្រូវបានតំរូវឱ្យដាក់ប្រាតិភោគឱ្យបានគ្រប់គ្រាន់ដើម្បីសង ចំណែកឯមាត្រា ៩០៧ កថាខណ្ឌទី ៤ បានចែងថា *បញ្ញត្តិនៃមាត្រានេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលម្ចាស់បំណុលបានជ្រើសតាំងអ្នកធានា* ពីព្រោះថា ម្ចាស់បំណុលត្រូវទទួលខុសត្រូវចំពោះការជ្រើសតាំងរបស់ខ្លួនផ្ទាល់។

### ៧-៥ គោលការណ៍នៃការធានាដោយសាមគ្គី

បុគ្គលដែលទទួលបន្ទុកកាតព្វកិច្ច ត្រូវធានាដោយសាមគ្គីភាពជាមួយនឹងកូនបំណុលដែលមានកាតព្វកិច្ចចម្បង មិនអាច ទាមទារឱ្យម្ចាស់បំណុល ទាមទារពីកូនបំណុលដែលមានកាតព្វកិច្ចចម្បងជាមុនសិន ឬ មិនអាច

រួចផុតពីការអនុវត្តចំពោះខ្លួនផ្ទាល់ដោយសំអាងថា កូនបំណុលដែលមានកាតព្វកិច្ចចម្បង មានសាធនភាពគ្រប់គ្រាន់ដើម្បីសង និង អាចអនុវត្តចំពោះកូនបំណុលនោះដោយងាយស្រួលបានឡើយ ។

អ្នកធានាមានការតវ៉ាដូចខាងក្រោមនេះ តែក្នុងករណីដែលពួកគេបានសន្យាពិសេស :

១-ទាមទារឱ្យម្ចាស់បំណុលទាមទារពីកូនបំណុលដែលមានកាតព្វកិច្ចចម្បងមុនអ្នកធានា

២-រួចផុតពីការអនុវត្តចំពោះខ្លួន នៅពេលដែលកូនបំណុលដែលមានកាតព្វកិច្ចចម្បង មានសាធនភាពគ្រប់គ្រាន់ដើម្បីសង និង អាចអនុវត្តចំពោះកូនបំណុលនោះដោយងាយស្រួលបាន ។

### ៣-៦ អានុភាពនៃហេតុដែលកើតឡើងទាក់ទងនឹងអ្នកធានា

ផ្ទុយទៅវិញ ហេតុដែលកើតឡើងទាក់ទងនឹងកូនបំណុលដែលមានកាតព្វកិច្ចចម្បងទេ ហេតុដែលកើតឡើងទាក់ទងនឹង អ្នកធានា ពុំមានអានុភាពចំពោះកូនបំណុលដែលមានកាតព្វកិច្ចចម្បងនោះទេ យោងតាមមាត្រា ៩០៩ ។

ករណីលើកលែងមួយគឺ *ការទាមទារ ឬ ហេតុផ្សេងនៃការផ្អាកអាជ្ញាយុកាល ចំពោះអ្នកធានាដែលទទួលអាណត្តិពី កូនបំណុលដែលមានកាតព្វកិច្ចចម្បង* យោងតាមមាត្រា ៩០៩ វាក្យខណ្ឌទី ២ ។

ឧទាហរណ៍ ករណីដែលម្ចាស់បំណុល ទាមទារចំពោះអ្នកធានាដែលទទួលអាណត្តិពីកូនបំណុលដែលមានកាតព្វកិច្ចចម្បង អំឡុងពេលអាជ្ញាយុកាលទាក់ទងនឹងកាតព្វកិច្ចចម្បងត្រូវផ្អាក រីឯ ការទាមទារចំពោះអ្នកធានាដែលមិនទទួលអាណត្តិពីកូនបំណុល ដែលមានកាតព្វកិច្ចចម្បង មិនផ្អាកអាជ្ញាយុកាលនោះទេ ។

### ៣-៧ អ្នកធានារួម

ជាទូទៅ ក្នុងកិច្ចសន្យាដែលមានអ្នកធានាច្រើននាក់ អ្នកធានាម្នាក់ៗមានករណីយកិច្ចចំពោះចំនួនទឹកប្រាក់ទាំងអស់នៃកាតព្វកិច្ចចម្បង យោងតាមមាត្រា ៩១០ កថាខណ្ឌទី ១ ។

ផ្ទុយទៅវិញ តាមរយៈការសន្យាពិសេសចំពោះការបែងចែកការធានា អ្នកធានារួមអាចកំរិតនូវការទទួលខុសត្រូវរបស់ខ្លួន បាន ។ បន្ទុកត្រូវបានសន្មតថា ស្មើគ្នា ។

ភាពខុសគ្នារវាង ***ការបង់ថែក*** និង ***បន្ទុក*** គឺមានដូចខាងក្រោមនេះ

| |
|---|
| X បានខ្ចីប្រាក់ពី ៣ 000 ដូល្លារពី Y ។Z1, Z2 និង Z3 ជាអ្នកធានាកាតព្វកិច្ចរបស់ X ។ នៅកាលបរិច្ឆេទនៃការសង Y ទាមទារឱ្យ X សង ប៉ុន្តែ X មិនអាចសងទេ។ |
| ១- ករណីដែល Y ទាមទារប្រាក់ចំនួន ៣ 000 ដូល្លារពី Z1, Z1 មិនអាចតវ៉ាថា Z1 ត្រូវបង់តែចំនួន ១ 000 ដូល្លារនោះទេ។ |
| ២- ក្រោយពីការសងចំនួន ៣ 000 ដូល្លារហើយ Z1 ត្រូវទាមទារប្រាក់ចំនួន ១ 000 ដូល្លារពី Z2 និង Z3 យោងតាមចំនួនភាគនៃបន្ទុក។ |

តាមមាត្រា៩១០ បើមិនមានការសន្យាពិសេស អ្នកធានាម្នាក់ៗមានករណីយកិច្ចទទួលបន្ទុកនូវចំនួនទឹកប្រាក់ទាំងអស់នៃកាតព្វកិច្ចចម្បង។ មានន័យថា ម្ចាស់បំណុលអាចទាមទារពីអ្នកធានាមួយណាក៏បាន ឬទាមទារពីអ្នកធានាច្រើននាក់ក៏បាន។

បើគ្មានការសន្យាពិសេស បន្ទុករបស់អ្នកធានា ត្រូវសន្មត់ថាស្មើរគ្នា។ ដូច្នេះបើអ្នកធានាណាម្នាក់បានចំណាយនូវសោហ៊ុយ របស់ខ្លួនលើសពីបន្ទុក អាចទាមទារពីអ្នកធានាផ្សេងទៀតបាន។

តាមឧទាហរណ៍ខាងលើ X បានទាមទារ Z1 ចំនួន ៣ 000 ដុល្លារ ក្នុងករណីនេះ Z បានចេញលើសពីចំនួនបន្ទុករបស់ខ្លួន ១ 000 ដុល្លារ ផ្ទុយទៅវិញ Z2 និង Z3 មិនទាន់បានបំពេញបន្ទុករបស់ខ្លួននៅឡើយ ដូច្នេះ Z1 អាចទាមទារចំណែកដែលចេញលើស ពី Z2 បាន និង Z3។ ជាពិសេស Z1 ទាមទារចំនួន ១ 000 ដូល្លាររៀងខ្លួនៗបានពី Z2 និង Z3 ។

### ៤- ប្រភេទនៃការធានា

#### ក- ការធានាធម្មតា

សំដៅទៅលើទំរង់ជាគោលការណ៍នៃការធានាបំណុល និង ប្រាក់ដើម។

ឧទាហរណ៍: (ក) បានឱ្យ (ខ) ខ្ចីប្រាក់ ២0000ដុល្លារ ដោយមាន (គ) ជាអ្នកធានា ហើយមួយឆ្នាំក្រោយមក គឺនៅពេលដែលកាលកំណត់សង បានមកដល់ ម្ចាស់បំណុល (ក) មិនចាំបាច់ទាមទារប្រាក់ ២៤000ដុល្លារ (ប្រាក់ដើម + ការប្រាក់) ពីកូនបំណុល (ខ) ដែលមានកាតព្វកិច្ចចម្បងទេ គឺ(ក) អាចទាមទារប្រាក់

២៤០០០ដុល្លារ នោះ ពី (គ) ភ្លាមបានតែម្តង ហើយប្រសិនបើ (គ) មិនព្រមសងទេ ម្ចាស់បំណុល(ក) អាចអនុវត្ត ដោយបង្ខំចំពោះ (គ) ដោយផ្អែកលើសិទ្ធិលើបំណុលជាប្រាក់បាន ។

**ខ- ការធានាការខូចខាត**

តាមធម្មតា កាតព្វកិច្ចធានា មិនអាចកើតឡើងបានឡើយ នៅក្នុងករណីដែលគ្មានកាតព្វកិច្ចចម្បងទេ (មាត្រា ៩០៤ កថាខណ្ឌទី ១) ។ កាតព្វកិច្ចរបស់អ្នកធានា ត្រូវបន្ថយមកត្រឹមកម្រិតនៃកាតព្វកិច្ចចម្បង (មាត្រា ៩០៤ កថាខណ្ឌទី ២) ហើយ ក្នុងករណីដែលកាតព្វកិច្ចចម្បងរលត់ កាតព្វកិច្ចធានា ក៏ត្រូវរលត់ផងដែរ (មាត្រា ៩០៤ កថាខណ្ឌទី ៣) ។ ទាំងនេះ គឺជាការឆ្លុះបញ្ចាំងពីលក្ខណៈបន្ទាប់បន្សំ ។

ផ្ទុយទៅវិញ នៅក្នុងករណីនៃការធានាការខូចខាត អ្នកធានា ត្រូវទទួលបន្ទុកកាតព្វកិច្ចដាច់ដោយឡែក ។ នៅក្នុងន័យនេះ ការធានាការខូចខាត គឺជាករណីលើកលែងចំពោះលក្ខណៈបន្ទាប់បន្សំ ។

| |
|---|
| ឧទាហរណ៍: X បានខ្ចីប្រាក់ពី Y ហើយ Z គឺជាអ្នកធានា ។ ក្នុងករណីកាតព្វកិច្ចធានានេះ គឺជាកាតព្វកិច្ចធានាធម្មតា កាតព្វកិច្ចរបស់ Z នឹងមិនត្រូវបានបង្កើតឡើងនោះទេ នៅពេលដែលកាតព្វកិច្ចចម្បងត្រូវបានលុបចោល ដោយផ្អែកតាមមាត្រា ៩០៤ កថាខណ្ឌទី ១ ប៉ុន្តែផ្ទុយទៅវិញ Z ត្រូវទទួលបន្ទុកកាតព្វកិច្ច ក្នុងករណី ដែលការធានា គឺជាការធានាការខូចខាត ។ |

**គ- ការធានាបំណុលអណ្តែត**

នៅក្នុងកិច្ចសន្យាធានាធម្មតា ខ្លឹមសារ និងចំនួនទឹកប្រាក់នៃកាតព្វកិច្ចចម្បង ត្រូវបានបញ្ជាក់ច្បាស់លាស់ (មាត្រា ៩០១ កថាខណ្ឌទី ៣) ។ ករណីនេះ គឺវាអាចជួយការពារអ្នកធានា កុំឱ្យទទួលបន្ទុកនូវការបាត់បង់ដែលមិនអាចរំពឹងទុកបាន ។

ការធានាបំណុលអណ្តែត គឺជាករណីលើកលែងចំពោះបញ្ញត្តិជាគោលការណ៍ ហើយអ្នកធានា ត្រូវធានាកាតព្វកិច្ចមិនកំណត់ ដែលអាចកើតមានឡើងនៅពេលអនាគត ដោយសារទំនាក់ទំនងគតិយុត្តជានិរន្តរ៍ ។

នេះគឺជាកិច្ចសន្យាដែលមានលក្ខណៈប្រថុយប្រថានច្រើនចំពោះ អ្នកធានា ។ ហេតុដូច្នេះ អ្នកធានាត្រូវបានគេផ្តល់នូវការការពារមួយចំនួន ។

| |
|---|
| ឧទាហរណ៍: X និង Y បានធ្វើជំនួញជាមួយគ្នាជាញឹកញាប់ ហើយ Z គឺជាអ្នកធានាកាតព្វកិច្ចរបស់ X ដែលបានកើតឡើង ពីការធ្វើជំនួញនោះ ។ <br> ១- ក្នុងករណីដែលការធ្វើជំនួញនោះ ត្រូវបានបញ្ជាក់ច្បាស់លាស់ ដូចជា កិច្ចសន្យាលក់ទិញចំណីអាហារ ការធានាបំណុលអណ្តែត នឹងមានសុពលភាព ផ្ទុយទៅវិញ ការធានាបែបនេះនឹងគ្មានសុពលភាពនោះ ទេ ករណីប្រសិនបើ Z ធានា រាល់កាតព្វកិច្ចទាំងអស់ដែលកើតឡើងពីប្រភេទណាមួយនៃទំនាក់ទំនងគតិយុត្ត |

រវាងពួកគេ (ប្រៀបធៀបមាត្រា ៩០២ កថាខណ្ឌទី ១ ) ។ ការធានាបំណុលអណ្តែត ត្រូវឱ្យមានទំនាក់ទំនងគតិយុត្តជាក់លាក់ ។

២- ក្នុងករណីដែលអំឡុងពេលធានាបំណុលអណ្តែត មិនត្រូវបានបញ្ជាក់ច្បាស់លាស់ទេ Z អាចរំលាយកិច្ចសន្យាធានាបំណុលអណ្តែតនោះបាន ក្រោយពីហួសអំឡុងពេលសមរម្យ ។ អំឡុងពេលសមរម្យ ត្រូវបានកំណត់ដោយផ្អែកមូលដ្ឋានករណីនីមួយៗ (ប្រៀបធៀប មាត្រា ៩០២ កថាខណ្ឌទី ២) ។

៣- នៅក្នុងករណីដែលស្ថានភាពសេដ្ឋកិច្ចរបស់ X ធ្លាក់អន់ថយយ៉ាងខ្លាំង Z អាចរំលាយកិច្ចសន្យាធានាបំណុលអណ្តែតនោះ ដោយឆ្ពោះទៅអនាគតដោយភ្លាមៗបាន (ប្រៀបធៀបមាត្រា ៩០២ កថាខណ្ឌទី៣) ។

៤- ដើម្បីការពារសន្តតិជន ការធានាបំណុលអណ្តែតមិនចងសន្តតិជននោះទេ ។ មានតែកាតព្វកិច្ចធានាបំណុលអណ្តែត ចំពោះកាតព្វកិច្ចចម្បងដែលបានកើតឡើងមកត្រឹមពេលអ្នកធានានោះទទួលមរណភាពទេ ទើបត្រូវបន្តដោយសន្តតិកម្ម ។

## ៥- សិទ្ធិទាមទារសំណង

អ្នកធានា អាចទាមទារសំណង នៅក្នុងករណីមួយចំនួន ប៉ុន្តែចំនួន និងពេលវេលានៃការទាមទារសំណងខុសគ្នា យោងតាមអត្ថិភាពនៃអាណត្តិ និងកត្តាផ្សេងៗមួយចំនួនទៀត ។

### ៥-១ លក្ខខណ្ឌនៃការទាមទារសំណង

### ៥-១-១ ការជូនដំណឹងជាមុន

ក្នុងករណីដែលអ្នកធានាមិនបានជូនដំណឹង ទៅកូនបំណុលដែលមានកាតព្វកិច្ចថា ម្ចាស់បំណុលបានទាមទារពីខ្លួន តែអ្នកធានានោះបានរួចផុតពីបំណុល ដោយការសង ឬការចេញចំណាយរបស់ខ្លួន ហើយកូនបំណុលដែលមានកាតព្វកិច្ចចម្បង មានហេតុដែលអាចតតាំងចំពោះម្ចាស់បំណុលបាន កូនបំណុលដែលមានកាតព្វកិច្ចចម្បងអាចយកហេតុនោះ ទៅតតាំងនឹងការទាមទាររបស់អ្នកធានាបាន ( មាត្រា ៩១៣ កថាខ័ណ្ឌទី១ វាក្យខ័ណ្ឌទី១) ។

### ៥-១-២ ការជូនដំណឹងក្រោយពេលសង

ឧទាហរណ៍: X បានទិញរថយន្តមួយគ្រឿងពី Y ។ Z ធានាកាតព្វកិច្ចចំពោះការបង់ថ្លៃលក់ ។

១- Z បានបង់ថ្លៃលក់ដោយមិនបានជូនដំណឹងជាមុននោះទេ ។ ជាក់ស្តែង X មានសិទ្ធិតវ៉ាឱ្យអនុវត្តព្រមគ្នា ពីព្រោះរថយន្តមិនទាន់ត្រូវបានប្រគល់ឱ្យនៅឡើយទេ ។ នៅក្នុងករណីនេះ តាមមាត្រា ៩១៣ កថាខណ្ឌទី១ X អាចបដិសេធ ការសងរហូតទាល់តែគាត់បានទទួលរថយន្តដែលត្រូវប្រគល់ ។

២- Z បានជូនដំណឹងដល់ X អំពីការទាមទាររបស់ Y ជាមុនរួចហើយ ហើយបានបង់ថ្លៃលក់រួចហើយដែរ ប៉ុន្តែ Z មិនបានជូន ដំណឹងដល់ X អំពីការបង់ថ្លៃលក់នេះទេ។ X ក៏បានបង់ថ្លៃលក់នោះដែរ ដោយសារតែមិនបានដឹងថា Z បានបង់ថ្លៃលក់នោះ (Y ស្ងៀមស្ងាត់អំពីបញ្ហានេះ)។ នៅក្នុងករណីនេះ តាមមាត្រា ៩១៣ កថាខណ្ឌទី ២ X អាច បដិសេធនូវការទាមទារសំណង ពីព្រោះថា ការសងរបស់ X មានអាទិភាពជាង។

Z ត្រូវទាមទារឱ្យ Y ត្រូវប្រគល់ថ្លៃលក់ដែលបានបង់រួចហើយនោះមកវិញដោយផ្អែកលើសេចក្តីចម្រើនឥតហេតុ។

### ៩-២ ទំហំនៃការទាមទារសំណង

ក្នុងករណីដែលអ្នកធានាដែលបានទទួលអាណត្តិ ទំហំនៃការទាមទារសំណងរាប់បញ្ចូលទាំង ចំនួនទឹកប្រាក់ជាកំណត់ ការប្រាក់ និងសំណងការខូចខាត ចំណែកឯអ្នកធានាដោយស្ម័គ្រចិត្ត (អ្នកធានាដោយគ្មានអាណត្តិ) អាចទាមទារសំណង ត្រឹមតែកម្រិតនៃផលប្រយោជន៍ដែលកូនបំណុលដែលមានកាតព្វកិច្ចចម្បងបានទទួលតែប៉ុណ្ណោះ។

ជាងនេះទៀត ប្រសិនបើការធានា ត្រូវបានធ្វើឡើងដោយផ្ទុយពីឆន្ទៈរបស់កូនបំណុលដែលមានកាតព្វកិច្ចចម្បង ទំហំនៃការទាមទារសំណងត្រូវបានកម្រិតត្រឹមតែផលប្រយោជន៍ជាក់ស្តែងដែលនៅតែមានតែប៉ុណ្ណោះ។

### ៩-៣ ការទាមទារសំណងជាមុន

ជួនកាល អ្នកដែលធានាដែលបានទទួលអាណត្តិ អាចទាមទារសំណងជាមុនផងដែរ យោងតាមមាត្រា ៩១១។ ករណីមួយចំនួនដែលការទាមទារសំណងជាមុនអាចធ្វើឡើងបានគឺ:

ក- ករណីដែលសាលក្រម ឬសាលដីកាស្ថាពរបានបង្គាប់ឱ្យអ្នកធានាសងទៅម្ចាស់បំណុល

ខ- ករណីដែលកូនបំណុលដែលមានកាតព្វកិច្ចចម្បងក្ស័យធន

គ- កាតព្វកិច្ចចម្បងដល់ពេលកំណត់ត្រូវសង

ឃ- ករណីដែលពេលកំណត់ត្រូវអនុវត្តកាតព្វកិច្ចចម្បងនោះមិនច្បាស់លាស់ ហើយអំឡុងពេល ៥ ឆ្នាំបានកន្លងហួស។

នៅក្នុងករណីនេះ កូនបំណុលដែលមានកាតព្វកិច្ចចម្បង អាចទាមទារឱ្យអ្នកធានាដាក់ប្រាតិភោគ ឬទាមទារឱ្យខ្លួនរួចផុតពីកាតព្វកិច្ចបាន (មាត្រា ៩១១ កថាខណ្ឌទី៤) ឬ អាចតម្កល់ ឬធ្វើឱ្យអ្នកធានារួចផុតពីកាតព្វកិច្ច (មាត្រា ៩១១ កថាខណ្ឌទី៥)។

### ៥-៤ សិទ្ធិទាមទាររបស់អ្នកធានារួម

មាត្រា ៩១៥ គឺជាបញ្ញត្តិពាក់ព័ន្ធទៅនឹងការទាមទារសំណងនៅក្នុងចំណោមអ្នកធានារួម។

ពាក្យពេចន៍នៅក្នុងមាត្រានេះ គឺមានភាពស្មុគ្រស្មាញពិបាកយល់ ប៉ុន្តែ លទ្ធផលជាក់ស្តែងនៃការអនុវត្ត មាត្រា ៩១៥ គឺមាន ដូចខាងក្រោមនេះ :

**អង្គហេតុជាមូលដ្ឋាន**

X ខ្ចីប្រាក់ចំនួន ១ 000 ដុល្លារ ពី Y ហើយ Z1, Z2, Z3 និង Z4 គឺជាអ្នកធានារួមនូវកាតព្វកិច្ចរបស់ X ។ បន្ទុកនៃការធានាកាតព្វកិច្ចរបស់ពួកគេម្នាក់ៗ គឺ Z1 ៤០ %, Z2 ៣០ %, Z3 ២០ % និង Z4 ១០ % ។

១- ប្រសិនបើ Z1 បានសងនូវចំនួនទឹកប្រាក់នៃកាតព្វកិច្ចទាំងអស់ ជាការពិតណាស់ Z1 អាចទាមទារ សំណងពី X បាន ឬ Z1 ក៏អាចទាមទារសំណងពីអ្នកធានារួមឯទៀតៗបាន យោងតាមមាត្រា ៩១៥ កថាខណ្ឌទី ១ ។ ចំនួនទឹកប្រាក់នៃសំណង គឺ ៣00 ដុល្លារ ពី Z2 ២00 ដុល្លារ ពី Z3 និង ១00 ដុល្លារពី Z4 ។ លើសពីនេះ Z1 អាចទាមទារការប្រាក់ តាមមាត្រា ៩១៥ កថាខណ្ឌ ទី ២ ។

២- ក្នុងករណីដែល Z1 បានសងដើម្បីឱ្យរួចផុតពីកាតព្វកិច្ចមួយផ្នែក ដូចជាការសងកាតព្វកិច្ចចំនួន ៦00 ដុល្លារ Z1 អាចទាមទារ សំណងពី X ឬ Z1 ក៏អាចទាមទារពីអ្នកធានារួមឯទៀតបានផងដែរ។ ចំនួនទឹកប្រាក់នៃ ការសងគឺ ១៨0 ដុល្លារ ពី Z2 ១២0 ដុល្លារពី Z3 និង ៦0 ដុល្លារពី Z4 ។

៣- ក្នុងករណីដែលមានការសន្យាពីការបែងចែកបន្ទុក អ្នកធានារួមនីមួយៗ ត្រូវបង់ច្រើនជាងចំនួននៃបន្ទុក របស់ខ្លួន។

ឧទាហរណ៍ ប្រសិនបើ Z1 បង់ចំនួន ៦00 ដុល្លារ Z1 អាចទាមទារសំណងតែ ១00 ដុល្លារចំពោះ អ្នកធានាឯទៀតៗ យោងតាមមាត្រា ៩១៥ កថាខណ្ឌទី ៣ ។

## ៦- ឧបាទេសកម្ម

ឧបាទេសកម្ម គឺជាប្រព័ន្ធគតិយុត្តមួយដើម្បីធានានូវការទាមទារសំណងចំពោះផលប្រយោជន៍របស់ អ្នកធានា (ប្រៀបធៀបមាត្រា ៩១៦ កថាខណ្ឌទី ១) ។

ជាការអនុវត្ត វាមានប្រយោជន៍ណាស់ នៅពេលដែលម្ចាស់បំណុល មានសិទ្ធិប្រាតិភោគចំពោះកូនបំណុល ដែលមានកាតព្វកិច្ចចម្បង ពីព្រោះ អ្នកធានា អាចធ្វើឧបាទេសកម្មនូវសិទ្ធិប្រាតិភោគបែបនេះ។

# ផ្នែកទី ៦

# អនុប្បទានសិទ្ធិលើបំណុល

## ១- ភាពដែលអាចធ្វើអនុប្បទានសិទ្ធិលើបំណុល

### ១-១ បញ្ញត្តិទូទៅ

ម្ចាស់សិទ្ធិលើបំណុល អាចធ្វើអនុប្បទានសិទ្ធិលើបំណុលរបស់ខ្លួនទៅឱ្យអ្នកផ្សេងបាន លើកលែងតែក្នុងករណីដែលសិទ្ធិនោះ មានលក្ខណៈមិនអាចធ្វើអនុប្បទានបាន ( មាត្រា ៥០១ កថាខណ្ឌទី ១ កថាខណ្ឌទី ២) ។

ឧទាហរណ៍នៃសិទ្ធិលើបំណុលដែលលក្ខណៈនៃសិទ្ធិនោះមិនអាចធ្វើអនុប្បទានបានគឺ សិទ្ធិលើបំណុលរបស់និយោជកចំពោះនិយោជិតរបស់ខ្លួន (បុគ្គលិកលក្ខណៈរបស់ម្ចាស់បំណុល គឺមានសារៈសំខាន់នៅក្នុងទំនាក់ទំនងការងារ) សិទ្ធិដែលកូនបំណុលត្រូវតួរូបភាពរបស់ម្ចាស់បំណុល (ការប្តូរម្ចាស់បំណុល ក៏ប្តូរនូវខ្លឹមសារនៃសិទ្ធិលើបំណុលដែរ) ។

### ១-២ ការសន្យាពិសេសហាមមិនឱ្យធ្វើអនុប្បទាន

ដូចដែលបានពន្យល់ពីខាងលើរួចមកហើយ សិទ្ធិលើបំណុល អាចធ្វើអនុប្បទានបានដោយសេរី និង ដូចដែលបានពន្យល់ពេលក្រោយ ការចូលរួមរបស់កូនបំណុល ជាគោលការណ៍ គឺមិនតំរូវឱ្យមាននោះទេ ។

ហេតុដូច្នេះ ក្នុងករណីដែលកូនបំណុល មិនមានបំណងឱ្យម្ចាស់បំណុលធ្វើអនុប្បទានសិទ្ធិលើបំណុលទៅឱ្យអ្នកផ្សេងទេ កូនបំណុល ត្រូវធ្វើការសន្យាពិសេសជាមួយនឹងអ្នកធ្វើអនុប្បទានបាន យោងតាមមាត្រា ៥០១ កថាខណ្ឌទី ៣ ។

ប៉ុន្តែ ការសន្យាបែបនេះ គឺគ្មានអានុភាពខ្លាំងនោះទេ ដោយសារតែ ការសន្យាហាមមិនឱ្យធ្វើអនុប្បទាន មិនអាចតតាំង ចំពោះតតិយជនសុចរិត និង គ្មានកំហុសធ្ងន់ធ្ងរ ។

## ២- លក្ខខណ្ឌដើម្បីធ្វើអនុប្បទានសិទ្ធិលើបំណុល

លក្ខខណ្ឌដើម្បីធ្វើអនុប្បទានសិទ្ធិលើបំណុល គឺ

ក- ការព្រមព្រៀងរវាង អនុប្បទាយី ( ម្ចាស់បំណុល) និង អនុប្បទានិក ( តតិយជន)

ខ- សិទ្ធិលើបំណុលមានលក្ខណៈអាចធ្វើអនុប្បទានបាន

គ- គ្មានការសន្យាពិសេសដែលហាមមិនឱ្យធ្វើអនុប្បទាន

## ៣- ល័ក្ខខ័ណ្ឌតតាំង

មានល័ក្ខខ័ណ្ឌតតាំងចំនួនពីរ។ ទី ១ គឺ ល័ក្ខខ័ណ្ឌតតាំងចំពោះ កូនបំណុល ហើយមួយទៀត គឺ ល័ក្ខខ័ណ្ឌតតាំងចំពោះ អនុប្បទានិកដទៃទៀត។

### ៣-១ ល័ក្ខខ័ណ្ឌតតាំងចំពោះ កូនបំណុល

ការជូនដំណឹងរបស់ ***អនុប្បទាយី*** ឬ ការយល់ព្រមរបស់កូនបំណុល គឺជាល័ក្ខខ័ណ្ឌតតាំង។

ការជូនដំណឹង ឬ ការយល់ព្រមនេះ មិនតំរូវឱ្យមានទំរង់ពិសេសណាមួយនោះទេ។

មូលហេតុដែលអនុប្បទាយី ត្រូវធ្វើការជូនដំណឹង គឺដើម្បីការពារអនុប្បទានិកក្លែងក្លាយកុំឱ្យផ្តល់ពត៌មានមិនពិត។

នៅពេលដែលផ្តល់ការយល់ព្រម ឬ ត្រូវបានជូនដំណឹង អនុប្បទានិក មិនត្រូវបដិសេធនូវអានុភាពនៃការធ្វើអនុប្បទាននោះទេ។

| |
|---|
| X មានសិទ្ធិលើបំណុលចំពោះ Y ។ X បានធ្វើអនុប្បទាន សិទ្ធិលើបំណុល (លក់សិទ្ធិលើបំណុល) របស់ខ្លួនទៅឱ្យ Z ។<br>១- មុនពេលជូនដំណឹង Y អាចតវ៉ាចំពោះសងចំពោះការទាមទាររបស់ Z បាន។<br>២- ទោះបីជា Z ជូនដំណឹងក៏ដោយ Y ក៏អាចតវ៉ាចំពោះការសងចំពោះការទាមទាររបស់ Z បានដែរ ដោយសារថា វាមិនមានភាពច្បាស់លាស់ថាតើ X ពិតជាបានធ្វើអនុប្បទានសិទ្ធិលើបំណុលរបស់ខ្លួនឱ្យទៅ Z ឬអត់នោះ។<br>៣- ក្រោយពីមានការជូនដំណឹងពី X ឬ ក្រោយពីមានការយល់ព្រម Z មិនអាចបដិសេធថា Y មិនមែនជាម្ចាស់បំណុល បាននោះទេ។ |

### ៣-២ លក្ខខណ្ឌតតាំងចំពោះអនុប្បទានិកដទៃទៀត

ក្នុងករណីដែល អនុប្បទាយី ធ្វើអនុប្បទានសិទ្ធិលើបំណុលតែមួយទៅឱ្យភាគីជាច្រើន ជាការពិតណាស់មានតែអនុប្បទានិកតែមួយប៉ុណ្ណោះ អាចអះអាងថាជា អនុប្បទានិកចំពោះអ្នកដទៃ។ (ភាគីដែលចាញ់ អាចទាមរតែសំណងតែប៉ុណ្ណោះចំពោះអនុប្បទាយី ដោយផ្អែកតាមការបំពានករណីយកិច្ច)។

ក្នុងករណីនេះ ត្រូវមាន លក្ខខណៈវិនិច្ឆ័យដើម្បីកំណត់ថា តើអនុប្បទានមួយណាត្រូវមានអានុភាពនៅក្នុងចំណោមអនុប្បទានិក។ លក្ខណៈវិនិច្ឆ័យនោះ គឺ ការជូនដំណឹង និង ការយល់ព្រមនៅក្នុងលិខិតដែលមានកាលបរិច្ឆេទស្អាតរ។

| |
|---|
| X មានសិទ្ធិលើបំណុលចំពោះ Y ។ X បានធ្វើអនុប្បទាន សិទ្ធិលើបំណុល (លក់សិទ្ធិលើបំណុល) របស់ខ្លួនទៅឱ្យ Z1 ហើយបន្ទាប់មកលក់ឱ្យ Z2 ។<br>ដំបូងឡើយ X គ្រាន់តែបានជូនដំណឹងអំពីការធ្វើអនុប្បទានសិទ្ធិលើបំណុលរវាង X និង Z1 តែប៉ុណ្ណោះ។ បន្ទាប់មក X បានជូនដំណឹងអំពីការធ្វើអនុប្បទានសិទ្ធិលើបំណុលរវាង X និង Z2 ដោយលិខិតដែលមានកាលបរិច្ឆេទស្អាតរ។ Z1 និង Z2 ទាមទារឱ្យ Y សង។ |

បន្ទាប់មកទៀត ថាតើវាយ៉ាងមេចទៅវិញក្នុងករណីដែលមានអនុប្បទានិកជាច្រើនដែលបានជូនដំណឹងនៅក្នុងលិខិតដែលមានកាលបរិច្ឆេទស្អាតរ។

| |
|---|
| X មានសិទ្ធិលើបំណុលចំពោះ Y ។ X បានធ្វើអនុប្បទាន សិទ្ធិលើបំណុល (លក់សិទ្ធិលើបំណុល) របស់ខ្លួនទៅឱ្យ Z1 ហើយបន្ទាប់មកលក់ឱ្យ Z2 ។<br>១- X បានជូនដំណឹងអំពីការធ្វើអនុប្បទានសិទ្ធិលើបំណុលរវាង X និង Z1 ដោយលិខិតដែលមានកាលបរិច្ឆេទស្អាតរនៅថ្ងៃទី ០១ ខែ វិច្ឆិកា។ ការជូនដំណឹងដែលធ្វើឡើងដោយលិខិតដែលមានកាលបរិច្ឆេទស្អាតរនេះបានដល់ Y នៅថ្ងៃទី ០៦ ខែ វិច្ឆិកា។ បន្ទាប់មក X បានជូនដំណឹងអំពីការធ្វើអនុប្បទានសិទ្ធិលើបំណុលរវាង X និង Z2 ដោយលិខិតដែលមានកាលបរិច្ឆេទស្អាតរនៅថ្ងៃទី ០៣ ខែ វិច្ឆិកា។ ការជូនដំណឹងដែលធ្វើឡើងដោយលិខិតដែលមានកាលបរិច្ឆេទស្អាតរនេះបានដល់ Y នៅថ្ងៃទី ០៤ ខែ វិច្ឆិកា។ Z1 និង Z2 ទាមទារឱ្យ Y សង។<br>២- នៅក្នុងករណីទី ១ ពេលដែលការជូនដំណឹងបានដល់ មិនមានភាពច្បាស់លាស់ទេ។ |

នៅក្នុងកណីនេះ លក្ខណៈវិនិច្ឆ័យ គឺមិនមែនកាលបរិច្ឆេទស្លាពរនោះទេ ប៉ុន្តែគឺជា ពេលវេលាដែលការជូនដំណឹងនោះ បានដល់ដៃកូនបំណុលយោងតាមមាត្រា ៥០៤ កថាខណ្ឌទី ១។

ក្នុងករណីដែលលំដាប់នៃពេលវេលា មិនមានភាពច្បាស់លាស់ទេ ភាគីទាំងពីរ អាចទាមទារត្រឹមកំរិតដែលកូនបំណុលអាចរួចផុតពីកាតព្វកិច្ចរបស់គាត់ដោយការសងចំពោះភាគីម្ខាង។ និយាយម្យ៉ាងទៀត អ្នកណាមកមុន អ្នកនោះនឹងទទួលការសង នៅក្នុងករណីនេះយោងតាមមាត្រា ៥០៤ កថាខណ្ឌទី ២។

## ៤- អានុភាពនៃការជូនដំណឹង និង ការយល់ព្រម

ក្នុងករណីប្រសិនបើ ការយល់ព្រមដោយគ្មានការតវ៉ា ត្រូវបានផ្តល់ឱ្យទៅអនុប្បទានិក អនុប្បទានិកអាចទាមទារចំពោះកូនបំណុល ហើយកូនបំណុលមិនអាចអះអាងអំពីការតវ៉ាតាមមាត្រា ៥០៥ បានទេ។

មាត្រាការពារកូនបំណុល មិនឱ្យលើកឡើងនូវការតវ៉ាដែលគាត់បានបញ្ជាក់ដើម្បីការពារទំនុកចិត្តរបស់អនុប្បទានិក។

| |
|---|
| X មានសិទ្ធិលើបំណុលចំនួន ១000 ដុល្លារ ចំពោះ Y ។X បានធ្វើអនុប្បទានសិទ្ធិលើបំណុល (លក់សិទ្ធិលើបំណុល) របស់ខ្លួនទៅឱ្យ Z ។<br>១- X បានលើកលែងបំណុលឱ្យ Y ចំនួន ៥00 ដុល្លារ ហើយក៏បានជូនដំណឹងអំពីការធ្វើអនុប្បទានសិទ្ធិលើបំណុលចំនួន ១000 ដុល្លារ រវាង X និង Z ហើយ Y ក៏បានយល់ព្រមដោយគ្មានតវ៉ាចំពោះការលើកលែងនេះទេ។<br>២- សិទ្ធិលើបំណុលរបស់ X បានកើតឡើងពីកិច្ចសន្យាលក់ទិញដែលមានខ្លឹមសារថា X ត្រូវលក់រថយន្តក្នុងតម្លៃ ១000 ដុល្លារ។X បានលក់សិទ្ធិលើបំណុលរបស់គាត់ទៅឱ្យ Y មុនពេលប្រគល់រថយន្តនោះទៅឱ្យ Y ។ ដោយមិនគិតពីការតវ៉ាឱ្យអនុវត្ត ព្រមគ្នារបស់ខ្លួន Y ក៏បានយល់ព្រមដោយគ្មានការតវ៉ាទេ។<br>៣- នៅពេលដែលសិទ្ធិលើបំណុល ត្រូវបានធ្វើអនុប្បទាន កាតព្វកិច្ចក៏ត្រូវបានអនុវត្តរួចហើយដែរ។ ដោយមិនគិតពី ការអនុវត្តកាព្វកិច្ចនោះ Y បានយល់ព្រមចំពោះការធ្វើអនុប្បទានសិទ្ធិលើបំណុលចំនួន ១ 000 ដុល្លារនោះ។ នៅក្នុងករណីនេះ Y ត្រូវអនុវត្តកាតព្វកិច្ចម្តងទៀត ចំពោះ Z ។ លើសពីនេះ Y អាចទាមទារសេចក្តីចំរើនដោយឥតហេតុចំពោះ X តាម កថាខណ្ឌទី ១ វាក្យខ័ណ្ឌទី ២ នៃមាត្រា ៥០៥។ |

# ជំពូកទី ៧

# អានុភាពនៃសិទ្ធិលើបំណុលចំពោះតតិយជន

## ផ្នែកទី ១

## សិទ្ធិលុបចោលនូវអំពើដែលនាំឱ្យខូចខាតប្រយោជន៍

### ១- សេចក្តីផ្តើម

និយាយទៅ សិទ្ធិលុបចោលនូវអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍ អាចរារាំងកូនបំណុលមិនឱ្យធ្វើការចាត់ចែងនូវការចាត់ចែងទ្រព្យសម្បត្តិដែលអាចរឹបអូសបានដោយមិនត្រឹមត្រូវរបស់ខ្លួន ហើយ ឧបាទេសកម្មអាចធ្វើឱ្យម្ចាស់បំណុល អនុវត្តសិទ្ធិរបស់កូនបំណុលដើម្បីការពារសិទ្ធិរបស់ម្ចាស់បំណុល។

តាមរយៈ ឧបាទេសកម្ម ឬ សិទ្ធិលុបចោលនូវអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍ ម្ចាស់បំណុលអាចធានានូវទ្រព្យសម្បត្តិដែលអាចរឹបអូសបាន ដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំដើម្បីឱ្យម្ចាស់បំណុលអាចទទួលបាននូវការសងចំពោះសិទ្ធិលើបំណុល។

ហេតុដូច្នេះហើយ ឧបាទេសកម្ម និង សិទ្ធិលុបចោលនូវអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍ គឺ ពិតជាមានផលប្រយោជន៍ចំពោះម្ចាស់បំណុល។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយមធ្យោបាយទាំងពីរនេះ ក៏បំពានសេរីភាពរបស់កូនបំណុលដែរនៅក្នុងករណីមួយចំនួន។ នៅក្នុងន័យនោះ មធ្យោបាយទាំងពីរនេះ គឺជាករណីលើកលែងយ៉ាងធំចំពោះគោលការណ៍ស្វ័យភាពនៃបុគ្គលឯកជន។

### ២- ខ្លឹមសារ និង និយមន័យ

មាត្រា ៤២៨ នៃក្រមរដ្ឋប្បវេណី បានចែងអំពីសិទ្ធិលុបចោលនូវអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍។ មាត្រានេះ បានអនុញ្ញាតឱ្យម្ចាស់បំណុលធ្វើការលុបចោលនូវសកម្មភាពរបស់កូនបំណុលដែលធ្វើឱ្យខូចខាតផលប្រយោជន៍របស់ខ្លួន។ សិទ្ធិលុបចោលនូវអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍ គឺជាសិទ្ធិរបស់ម្ចាស់បំណុលក្នុងការទាមទារតាមផ្លូវតុលាការ ដើម្បីលុបចោលនូវសកម្មភាពទាំងឡាយរបស់កូនបំណុលដែលបានធ្វើឱ្យខូចខាតផលប្រយោជន៍របស់ខ្លួន ពោលគឺ ប្រសិនបើ អំពើរបស់កូនបំណុល ធ្វើឱ្យប៉ះពាល់ដល់សិទ្ធិលើបំណុលរបស់ម្ចាស់បំណុលដែលមិនអាចទទួលការសង បានទាល់តែសោះ ឬ ក៏ទទួលបាន ការសងមិនគ្រប់ចំនួនដោយសារតែសកម្មភាពណាមួយរបស់កូនបំណុល។

ក្នុងន័យនេះ ម្ចាស់បំណុលដែលបានលុបចោលនូវអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍ អាចទាមទារឱ្យសង មកវិញនូវវត្ថុ ឬ ទឹកប្រាក់ដែលជាតម្លៃនៃវត្ថុនោះដើម្បីជាផលប្រយោជន៍ដល់ម្ចាស់បំណុលទាំងអស់របស់កូនបំណុល។

ក្នុងករណីដែល Y ខ្ចីប្រាក់ពី X ចំនួន ១ ០០០ ដុល្លារ ហើយ ក្រោយមក Y បានប្រគល់ដី តែមួយគត់របស់គាត់ដែលមានតម្លៃ ២ ០០០ ដុល្លារទៅម្ចាស់បំណុល Z ដែលជាការសងដោយវត្ថុជំនួស គឺមានន័យថា អំពើរបស់ Y បានធ្វើឱ្យម្ចាស់បំណុល X ទទួលរងនូវការខូចខាត ពោលគឺម្ចាស់បំណុល X មិនអាចទទួលការសងចំពោះសិទ្ធិលើបំណុល របស់ខ្លួនឡើយដោយហេតុថា កូនបំណុល Y មិនមានទ្រព្យសម្បត្តិណាផ្សេងដើម្បីសងចំពោះសិទ្ធិលើបំណុលរបស់ម្ចាស់បំណុល X ឡើយ។ នៅក្នុងសម្មតិកម្មខាងលើនេះ ការលុបចោលនូវអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍ គឺជា វិធីសាស្ត្រមួយក្នុងការជួយឱ្យម្ចាស់បំណុល X ទទួលបាន សំណងចំពោះសិទ្ធិលើបំណុលរបស់គាត់ តាមរយៈការលុបចោលនូវការសងដោយវត្ថុជំនួសពី Y ទៅម្ចាស់បំណុល Z ដែលជា ហេតុនាំឱ្យទ្រព្យសម្បត្តិដែលបានផ្ទេរឱ្យ Z នឹងត្រូវវិលត្រឡប់ ទៅក្នុងបេតិកភណ្ឌរបស់កូនបំណុល Y វិញ ហើយ ទ្រព្យសម្បត្តិនេះ នឹងក្លាយទៅជាកម្មវត្ថុនៃការរឹបអូសដោយម្ចាស់បំណុល X ដើម្បីលក់ដោយបង្ខំយកប្រាក់មកសង សិទ្ធិលើបំណុលរបស់ខ្លួន។

## ៣- លក្ខខណ្ឌ

យោងតាមមាត្រា ៤២៨ និង មាត្រា ៤២៩ ដើម្បីឱ្យមានសិទ្ធិលុបចោលនូវអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍ ត្រូវគោរពតាមលក្ខខណ្ឌ ៤ យ៉ាងគឺ :

-អត្ថិភាពនៃសិទ្ធិដែលត្រូវបានរក្សាការពារ

- អំពើដែលនាំឱ្យខូចខាតផលប្រយោជន៍

-ការបានដឹងរបស់កូនបំណុលអំពីការខូចខាតផលប្រយោជន៍នោះ

-ការបានដឹងរបស់អ្នកដែលបានទទួលផលប្រយោជន៍ពីអំពើរបស់កូនបំណុល ឬ អ្នកដែល បានទទួលបន្តវត្ថុពីអ្នកនោះ។ ក៏ប៉ុន្តែ ប្រសិនបើ អំពើដែលនាំឱ្យមានការខូចខាតនោះ ឱ្យដោយមិនយកថ្លៃទេនោះ ការបានដឹង ឬ មិនបានដឹងពីអំពើរបស់កូនបំណុល មិនមែនជាលក្ខខណ្ឌនៃការលុបចោលនូវអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍ ឡើយ។

### ៣-១ អត្ថិភាពនៃសិទ្ធិដែលត្រូវបានរក្សាការពារ

ជាដំបូង សិទ្ធិលើបំណុលដែលត្រូវបានរក្សាការពារ ត្រូវតែជាសិទ្ធិលើបំណុលដែលទទួលបានមុនពេលដែលអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍បានកើតឡើង។ ហេតុដូច្នេះ ប្រសិនបើ សិទ្ធិលើបំណុលរបស់ម្ចាស់បំណុល បានកើតឡើងមុន បន្ទាប់មកទើបមានការផ្ទេរទ្រព្យសម្បត្តិរបស់កូនបំណុលទៅឱ្យតតិយជន ក្នុងករណីនេះ សិទ្ធិលើបំណុលបាន កើតឡើងមុនអំពើដែលនាំឱ្យមានការខូចខាតផលប្រយោជន៍។ ផ្ទុយទៅវិញ ប្រសិនបើ សិទ្ធិលើបំណុល កើតឡើងក្រោយអំពើនៃការផ្ទេរទ្រព្យសម្បត្តិ គឺពុំមានភាពចាំបាច់ដើម្បីការពារ

សិទ្ធិលើបំណុលទេ ដោយហេតុថា នៅពេលដែលម្ចាស់បំណុល បានបង្កើតសិទ្ធិលើបំណុលជាប្រយោជន៍ដល់កូនបំណុល ម្ចាស់បំណុលបានដឹងរួចជាស្រេចហើយ អំពីទំហំនៃទ្រព្យសម្បត្តិរបស់កូនបំណុលនោះ។

ត្រង់ចំណុចនេះ គួរធ្វើការកត់សំគាល់ផងដែរថា ការពិចារណាទៅលើអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍ដែលជាការផ្ទេរទ្រព្យសម្បត្តិដោយកូនបំណុល គឺត្រូវគិតគូរអំពី ពេលវេលានៃការផ្ទេរកម្មសិទ្ធិ។

ហេតុដូច្នេះ ប្រសិនបើ ការផ្ទេរទ្រព្យសម្បត្តិដោយ បានធ្វើឡើងដោយពុំបានធ្វើការចុះបញ្ជីផ្ទេរកម្មសិទ្ធិ យោងតាមបទបញ្ញត្តិនៃមាត្រា ១៣៥ នៃ ក្រមរដ្ឋប្បវេណីទេ គឺពុំមានការផ្ទេរកម្មសិទ្ធិដែលមានអានុភាពឡើយ។

ឧទាហរណ៍ Y បានខ្ចីប្រាក់ពី X ចំនួន ១ ០០០ ដុល្លារ ។ ទ្រព្យសម្បត្តិតែមួយគត់របស់គាត់ គឺ ដី L ដែលមានតម្លៃ ២ ០០០ ដុល្លារ។ ក្រោយមកកូនបំណុល Y បានឱ្យដី L នោះទៅម្ចាស់បំណុល Z ម្នាក់ផ្សេងទៀតដើម្បីសងបំណុល ដោយវត្ថុជំនួស។ នៅក្នុងករណីនេះ សិទ្ធិលើបំណុលរបស់ X ចំពោះ Y កើតមានមុនពេលដែល Y បានដី L ទៅ Z ហេតុដូច្នេះ គឺបានសេចក្ដីថា ទ្រព្យសម្បត្តិរបស់កូនបំណុល Y បានថយចុះក្រោយពីសិទ្ធិលើបំណុលរបស់ X បានកើតឡើង រួចទៅហើយ។

ផ្ទុយមកវិញ ប្រសិនបើ Y បានយកដី L ទៅសងម្ចាស់បំណុលឈ្មោះ Z ហើយបន្ទាប់មកទើប Y ខ្ចីប្រាក់ពី X នោះមានន័យថា ទ្រព្យសម្បត្តិរបស់កូនបំណុលបានថយចុះ មុនពេលដែលសិទ្ធិលើបំណុលរបស់ X បាកើតឡើងទៅទៀត។ ហេតុដូច្នេះ សិទ្ធិលើបំណុលរបស់ X បានកើតឡើង ក្រោយអំពើដែលនាំឱ្យទ្រព្យសម្បត្តិរបស់កូនបំណុលថយចុះ ពោលគឺ ម្ចាស់បំណុល X មិនមានមូលហេតុនឹងសុំលុបចោលអំពើនេះទេ។

ម្យ៉ាងទៀត សិទ្ធិដែលត្រូវបានរក្សាការពារក្នុងន័យនេះ មិនមែនគ្រាន់តែជាសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់តែប៉ុណ្ណោះទេ គឺថែមទាំងអាចសិទ្ធិលើបំណុលផ្សេងពីនេះក៏បានដែរ។ ក៏ប៉ុន្តែ យោងតាមខ្លឹមសារនៃមាត្រា ៤២៩ វាក្យខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណី នៅពេលទាញហេតុផលដោយផ្ទាល់មាត់ដែលទាក់ទងនឹងសាលក្រម ឬ សាលដីកា ដែលលុបចោលអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍។ ហេតុដូច្នេះ ក្នុងករណីដែលម្ចាស់បំណុលមានសិទ្ធិលើបំណុលដែល ពុំមានគោលបំណងឱ្យសងជាប្រាក់ទេ មាត្រា ៤២៩ នៃក្រមរដ្ឋប្បវេណី កំណត់នូវលក្ខខណ្ឌមួយទៀតនៃការលុបចោលអំពើ ដែលនាំឱ្យខូចខាតផលប្រយោជន៍ គឺការប្ដូរទៅជាសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់វិញ នៅពេលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់។

ឧទាហរណ៍ Y បានលក់គ្រឿងអលង្ការមួយទៅឱ្យ X ក្នុងតម្លៃ ៥០០ ដុល្លារ។ កាលបរិច្ឆេទនៃការប្រគល់គ្រឿង អលង្ការដែលបាន ព្រមព្រៀងគ្នា គឺរយៈពេលមួយឆ្នាំក្រោយបន្ទាប់ពីមានការព្រមព្រៀងគ្នា។

ឧបមាថា ទ្រព្យសម្បត្តិតែមួយគត់របស់ Y គឺ ដី L ដែលមានតម្លៃ ២ ០០០ ដុល្លារ។ ក្រោយមក Y បានឱ្យដី L នោះទៅម្ចាស់បំណុល Z ម្នាក់ផ្សេងទៀតដើម្បីជាការសងដោយវត្ថុជំនួស។

ក្នុងករណីបែបនេះ សិទ្ធិរបស់ម្ចាស់បំណុល X គឺជាការទាមទារឱ្យប្រគល់គ្រឿងអលង្ការ ដែលមិនមែនជាសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់នោះទេ។ ក៏ប៉ុន្តែ ប្រសិនបើ កូនបំណុល Y មិនបំពេញ

កាតព្វកិច្ចរបស់គាត់ ក្នុងការប្រគល់គ្រឿងអលង្ការទេ ម្ចាស់បំណុលអាចដាក់ពាក្យបណ្តឹងចំនួនពីរគឺ : ពាក្យបណ្តឹងទាមទារឱ្យប្រគល់ គ្រឿង អលង្ការ និង ពាក្យបណ្តឹងទាមទារឱ្យលុបចោលអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍ចំពោះការសងដោយវត្ថុជំនួស ។

ទន្ទឹមនឹងនេះ ម្ចាស់បំណុល X អាចត្រឹមតែដាក់ពាក្យបណ្តឹងទាមទារឱ្យលុបចោលនូវអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍ចំពោះការសងដោយវត្ថុជំនួសក៏បានដែរ ។ ក្នុងករណីទាំងពីរនេះ ដើម្បីកុំឱ្យតុលាការសំរេចច្រានចោលពាក្យបណ្តឹងទាមទារឱ្យលុបចោលនូវអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍ ម្ចាស់បំណុល X ត្រូវប្តូរសិទ្ធិរបស់គាត់ ទៅជា សិទ្ធិជាសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់ ពោលគឺ ម្ចាស់បំណុល X ត្រូវបង្ហាញឆន្ទៈរំលាយកិច្ចសន្យារវាងគាត់ និង កូនបំណុល Y ហើយទាមទារសំណងនៃការខូចខាតជាជំនួសឱ្យការទាមទារឱ្យប្រគល់គ្រឿងអលង្ការវិញ ។

ការបង្ហាញឆន្ទៈរំលាយកិច្ចសន្យានេះ ត្រូវធ្វើយ៉ាងយូរបំផុតនៅមុនពេលបញ្ចប់ការទាញហេតុផលដោយផ្ទាល់ សំរាប់ពាក្យបណ្តឹងទាមទារឱ្យលុបចោលនូវអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍តែម្តង ។

### ៧-២ អំពើដែលនាំឱ្យខូចខាតផលប្រយោជន៍ និង ការដឹងអំពីការខូចខាតផលប្រយោជន៍

អំពើដែលនាំឱ្យខូចខាតផលប្រយោជន៍ គឺអំពើដែលបន្ថយនូវទ្រព្យសម្បត្តិរបស់កូនបំណុលត្រឹមកំរិតដែលនាំឱ្យ កូនបំណុល ក្លាយជាអាសាធនីយ៍ ហើយប្រសិនបើ កូនបំណុលស្ថិតក្នុងភាពអាសាធនីយ៍ស្រាប់ អំពើនោះបាន ធ្វើឱ្យកូនបំណុលកាន់តែអាសាធនីយ៍ខ្លាំងជាបន្ថែមទៀត ។

ឧទាហរណ៍ Y ជំពាក់ប្រាក់ X ចំនួន ១ ០០០ ដុល្លារ ។ Y មានប្រាក់ចំនួន ១០ ០០០ ដុល្លារ ហើយបានធ្វើប្រទាន កម្មនូវប្រាក់ទាំងអស់នេះឱ្យទៅ Z ។ ក្នុងករណីបែបនេះ ប្រទានកម្មទៅឱ្យ Z បានធ្វើឱ្យបំពានរបស់ម្ចាស់បំណុល X ។ ប្រទានកម្មនេះ ជាអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍ ។ ម្យ៉ាងវិញទៀត ប្រសិនបើ Y មានប្រាក់ត្រឹមតែ ៣០០ ដុល្លារ តែប៉ុណ្ណោះ ពោលគឺមិនគ្រប់គ្រាន់សំរាប់សងបំណុលរបស់ X ផង ហើយ Y បានធ្វើប្រទានកម្មប្រាក់ ៣០០ ដុល្លារទៅឱ្យ Z ។ ដូចគ្នាទៅនឹងករណីខាងលើដែរ ប្រទានកម្មប្រាក់ ៣០០ ដុល្លារនេះ បានធ្វើឱ្យកូនបំណុល Z កាន់តែអសាធនីយ៍ខ្លាំងថែមទៀត ។ ករណីនេះ ក៏ជាអំពើធ្វើឱ្យខូចខាតផលប្រយោជន៍ដែរ ។

ដើម្បីមានមូលដ្ឋាននៅក្នុងការពិចារណាអំពីសញ្ញាណនៃអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍ សូមធ្វើការពិនិត្យមើលទៅលើការអនុវត្តរបស់ប្រទេសជប៉ុន ។ លក្ខខណៈវិនិច្ឆ័យពីរយ៉ាង ត្រូវបានយកមកពិចារណាដើម្បីកំណត់ថាជាអំពើ ដែលនាំឱ្យខូចខាតផលប្រយោជន៍ ឬ អត់ :

*១- ការធ្វើឱ្យកូនបំណុលក្លាយជាអសាធនីយ៍ (មិនអាចមានប្រាក់គ្រប់គ្រាន់ដើម្បីបំពេញកាតព្វកិច្ចចំពោះម្ចាស់ បំណុល)*

*២- គោលបំណង*

ឧទាហរណ៍ Y បានខ្ចីប្រាក់ពី X ចំនួន ១០០០ ដុល្លារ នៅខណៈនោះ Y មានដី L ដែលមានតម្លៃ ១ ០០០ ដុល្លារ។ ក្រោយមក Y បានយកដី L នោះដាក់ហ៊ីប៉ូតែកជាប្រយោជន៍ដល់ Z ដើម្បីធានាសិទ្ធិលើបំណុលចំនួន ៤០០ ដុល្លារ ។ ក្នុងស្ថានភាពបែបនេះ ទ្រព្យសម្បត្តិរបស់ Y ដែលអាចឱ្យម្ចាស់បំណុល X អនុវត្តនៅសល់ត្រឹមតែ ៦០០ ដុល្លារ តែប៉ុណ្ណោះ។ ក៏ប៉ុន្តែ ទន្ទឹមនឹងនេះ គេក៏ត្រូវពិនិត្យមើលទៅលើគោលបំណងនៃការខ្ចីប្រាក់ និង ការដាក់ហ៊ីប៉ូតែកផងដែរ។ ប្រសិនបើ ការខ្ចីប្រាក់ ៤០០ ដុល្លារ ធ្វើឡើងដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសារ ការខ្ចីប្រាក់ និង ការដាក់ហ៊ីប៉ូតែក បានធ្វើឡើង ដោយមានមូលហេតុត្រឹមត្រូវដែលមិនគួរគប្បីឱ្យគេចាត់ទុកថា អំពើនេះគឺជា អំពើធ្វើឱ្យខូចខាតផលប្រយោជន៍ឡើយ។

ក្រៅពីនេះ ការផ្ទេរវត្ថុណាមួយចេញពីបេតិកភ័ណ្ឌរបស់កូនបំណុល ក៏ជាបញ្ហាដែលងាយកើតឡើងផងដែរ។ ក្នុងករណីដែលការផ្ទេរកម្មសិទ្ធិបានធ្វើឡើងដោយមិនមានតម្លៃថ្នូរ ឬ ដោយតម្លៃថោកជាងធម្មតា នោះត្រូវបានគេ ចាត់ទុកជាទូទៅថា ជាអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍។ ក៏ប៉ុន្តែ ប្រសិនបើ ការផ្ទេរកម្មសិទ្ធិ ធ្វើឡើងដោយតម្លៃ សមរម្យវិញ ជាទូទៅ គឺមិនមានអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍ឡើយ។ ទន្ទឹមនឹងនេះ ពេលខ្លះតុលាការនៃប្រទេសជប៉ុន បានចាត់ទុកជាទូទៅថា ជាអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍ដែរ ដោយសំអាងហេតុថា ការលក់អចលនវត្ថុដោយកូនបំណុល គឺធ្វើឡើងដើម្បីទទួលបានប្រាក់ដែលមានភាពងាយស្រួលក្នុងការលាក់បំបាំងជាង ហេតុដូច្នេះ ប្រសិនបើ មានភស្តុតាងបញ្ជាក់ថា ការផ្ទេរកម្មសិទ្ធិនៃ អចលនវត្ថុ គឺមានគោលបំណងលាក់បំបាំងទ្រព្យសម្បត្តិ នោះត្រូវចាត់ទុកថាជា អំពើដែលនាំឱ្យខូចខាតផលប្រយោជន៍ដែរ។

ជាចុងក្រោយនេះ សូមធ្វើការកត់សំគាល់ថា មាត្រា ៤២៨ កថាខណ្ឌទី ៣ នៃក្រមរដ្ឋប្បវេណី មិនឱ្យយកមាត្រា ៤២៨ កថាខណ្ឌទី ១ និង ទី ២ មកអនុវត្តឡើយចំពោះអំពើដែលមានកម្មវត្ថុមិនមែនជា សិទ្ធិលើទ្រព្យសម្បត្តិ។

អំពើដែលមានកម្មវត្ថុមិនមែនជា សិទ្ធិលើទ្រព្យសម្បត្តិ ភាគច្រើនទាក់ទងនឹងបញ្ហាគ្រួសារ។

ជាក់ស្តែង ការរៀបអាពាហ៍ពិពាហ៍ ការលែងលះ ការយល់ព្រមទទួលសន្តតិកម្មជាដើម ។ល។ មិនមែនជា អំពើដែលមានកម្មវត្ថុជាសិទ្ធិលេទ្រព្យសម្បត្តិឡើយ ទោះបីជាពេលខ្លះ សកម្មភាពនេះ ធ្វើឱ្យកូនបំណុល ក្លាយទៅជាអសាធនីយ៍ក៏ដោយ។ ហេតុដូច្នេះ ទោះបីជាក្រោយពីយល់ព្រមទទួលសន្តតិកម្មហើយ កូនបំណុល ក្លាយទៅជាអសាធនីយ៍ ដោយសារតែ សន្តតិកម្ម មានបំណុលច្រើនជាងទ្រព្យសម្បត្តិក៏ដោយ ក៏ម្ចាស់បំណុល

មិនអាចលុបចោលការយល់ព្រមទទួល សន្តតិកម្មនេះ បានដែរ។ តាមការពិតទៅ គេអាចចាត់ទុកថា ការរៀបអាពាហ៍ពិពាហ៍ ការលែងលះ ការយល់ព្រម ទទួលសន្តតិកម្ម គឺជាអំពើដែលអាស្រ័យយ៉ាងខ្លាំងទៅនឹង ឆន្ទៈរបស់កូនបំណុល ដែលម្ចាស់បំណុលមិនអាចទាមទារឱ្យ លុបចោលបានឡើយ។

ក្រៅពីនេះ ដើម្បីអាចលុបចោលនូវអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍ ត្រូវបង្ហាញភស្តុតាងថា កូនបំណុល ឬ អ្នកដែលបានទទួលបន្តវត្ថុពីកូនបំណុល បានដឹងអំពីការខូចខាតផលប្រយោជន៍នោះ។ ក៏ប៉ុន្តែ ប្រសិនបើ អ្នកដែលបានទទួលផលប្រយោជន៍ ឬ អ្នកទទួលបន្តដោយមិនបង់ថ្លៃ ឬ មិនបានដឹងពីអំពើរបស់ កូនបំណុល មិនមែនជាលក្ខខណ្ឌនៃការលុបចោលនូវអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍ឡើយ។

### ៣-៣ ការបានដឹងរបស់អ្នកដែលបានទទួលផលប្រយោជន៍ពីអំពើរបស់កូនបំណុល ឬ ការបានដឹងរបស់អ្នកដែលបានទទួលបន្តវត្ថុពីអ្នកនោះ ឬ អំពើដែលនាំឱ្យខូចខាតផលប្រយោជន៍នោះ មិនត្រូវបានបង់ថ្លៃ

អ្នកដែលបានទទួលផលប្រយោជន៍ពីអំពើរបស់កូនបំណុល ឬ អ្នកដែលបានទទួលបន្តវត្ថុពីអ្នកនោះ ត្រូវដឹង អំពីការខូត ខាតផលប្រយោជន៍ពីអំពើនោះ បើអ្នកទទួលមិនបានដឹងពីការខូចខាត អ្នកទទួលមិនទទួលខុសត្រូវ ពីការផ្ទេរវត្ថុទេ។

១-អង្គហេតុជាមូលដ្ឋាន :

Y បានខ្ចីប្រាក់ពី X ចំនួន ១០០០ ដូល្លារ ។ ទ្រព្យសម្បត្តិតែមួយគត់របស់គាត់ គឺ ដី L ដែលមានតម្លៃ ២ ០០០ ដូល្លារ។

ក្រោយមក Y បានលក់ដី L នោះទៅឱ្យ Z1 ក្នុងតម្លៃ ១០០ ដូល្លារ។ X មានបំណងចង់លុបចោលនូវអំពើរវាង Y និង Z1 ។ Y បានដឹងថា កិច្ចសន្យានេះនាំឱ្យខូចខាតផលប្រយោជន៍ចំពោះ X ។

តើ X អាចលុបចោលនូវអំពើរវាង Y និង Z1 បានដែរឬទេ នៅក្នុងករណីខាងក្រោមនេះ?

១-១ Z1 មិនដឹងថា អំពើនេះ នាំឱ្យខូចខាតផលប្រយោជន៍នោះទេ

១-២ Z1 បានដឹងថា អំពើនេះ នាំឱ្យខូចខាតផលប្រយោជន៍

២- ក្រៅពីអង្គហេតុជាមូលដ្ឋាន Z1 បានផ្ទេរដី L ទៅឱ្យ Z2 ក្នុងតម្លៃ ២ ០០០ ដូល្លារ។ X មានបំណងចង់លុបចោលនូវអំពើ រវាង Y និង Z1 និង អំពើរវាង Z1 និង Z2 ។

តើ X អាចធ្វើដូច្នោះបានដែរឬទេនៅក្នុងករណីខាងក្រោមនេះ?

២-១ ទាំង Z1 និង Z2 បានដឹងថា អំពើនេះនាំឱ្យខូចខាតផលប្រយោជន៍

២-២ Z1 បានដឹងថា អំពើនេះនាំឱ្យខូចខាតផលប្រយោជន៍ ប៉ុន្តែ Z2 មិនបានដឹងទេ

២-៣ Z1 មិនបានដឹងទេ ប៉ុន្តែ Z2បានដឹងអំពីអំពើនោះ

| ២-៤ Z1 និង Z2 មិនបានដឹង |
| --- |

សន្និដ្ឋាន

១-១ អត់ទេ

១-២ បាន

២-១ បាន

២-២ ទេ X មិនអាចលុបចោលកិច្ចសន្យារវាង Z1 និង Z2 បានទេ ពីព្រោះ Z2 គឺជាជនសុចរិត ។ ប៉ុន្តែ ការអនុវត្តនៅប្រទេសជប៉ុន X នៅតែអាចលុបចោលកិច្ចសន្យារវាង Y និង Z1 ហើយទាមទារឱ្យប្រគល់ តម្លៃដី L (២ 000 ដុល្លារ) ។

២-៣ , ២-៤ វាអាស្រ័យទៅលើការបកស្រាយ ។ ការអនុវត្តនៅប្រទេសជប៉ុន គេអាចធ្វើបាន ហើយ បន្ទាប់ពីនោះ Z2 អាចទាមទារសេចក្តីចំរើនឥតហេតុចំពោះ Y ប៉ុន្តែ មិនអាច ទាមទារអ្វីពី Z1 បានទេ ពីព្រោះអានុភាពនៃការលុបចោល ត្រូវបានចាត់ទុកថា កើតឡើងមិនដាច់ខាត ។

នៅពេលដែលផលប្រយោជន៍ត្រូវបានផ្តល់ឱ្យដោយមិនបង់ថ្លៃ លក្ខខណ្ឌនៃការ **បានដឹង** គឺមិនមាន ភាពចាំបាច់នោះទេ ពីព្រោះអ្នកដែលទទួលបានផលប្រយោជន៍ដែលមិនបានបង់ថ្លៃបែបនេះ ឬ ក៏អ្នកដែលបាន ទទួលបន្ត នូវវត្ថុរបស់គាត់ មិនចាំបាច់ត្រូវការការពារខ្លាំងនោះទេ ។

## ៤- ការអនុវត្តសិទ្ធិលុបចោលនូវអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍

### ៤-១ នីតិវិធីតុលាការដែលចាំបាច់

យោងតាមមាត្រា ៤២៨ កថាខណ្ឌទី ១ ការលុបចោលនូវអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍ ត្រូវធ្វើឡើងតាមផ្លូវតុលាការ ពីព្រោះសិទ្ធិលុបចោលនូវអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍ អាចប៉ះពាល់ដល់ ភាគីជាច្រើន ហេតុដូច្នេះ ចាំបាច់ត្រូវបញ្ជាក់ អំពីអត្ថិភាព និង ខ្លឹមសារនៃអានុភាពនៃការលុបចោលនោះ ។

### ៤-២ ការទទួល

គោលបំណងនៃសិទ្ធិលុបចោលនូវអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍ គឺដើម្បីទទួលបានមកវិញនូវ ទ្រព្យសម្បត្តិដែលអាចរឹបអូសបានរបស់កូនបំណុល ។ ហេតុដូច្នេះ កម្មវត្ថុនៃសិទ្ធិលុបចោលនូវអំពើដែលនាំឱ្យ ខូចខាតផលប្រយោជន៍ ត្រូវប្រគល់ឱ្យទៅទ្រព្យសម្បត្តិរបស់កូនបំណុលវិញ ប៉ុន្តែ មិនមែនម្ចាស់បំណុលនោះទេ ។

តាមមាត្រា ៤៣០ បើគ្មានវិធីសមរម្យដើម្បីឱ្យអ្នកដែលបានទទួលប្រយោជន៍ ឬ អ្នកដែលបានទទួលបន្តវត្ថុធ្វើបដិទាន ម្ចាស់បំណុលដែលអនុវត្តសិទ្ធិលុបចោលអាចទាមទារអោយអ្នកដែលបានទទួលផលប្រយោជន៍ ឬ អ្នកដែលបានទទួលបន្តវត្ថុនោះ តម្កល់នូវវត្ថុដែលទទួលបាន ។

ឧទាហរណ៍នៃករណីដែលការធ្វើបដិទានមិនសមរម្យ គឺមានដូចខាងក្រោមនេះ :

**ក- ការបដិសេធមិនព្រមទទួលរបស់កូនបំណុល :** មានន័យថា បន្ទាប់ពីធ្វើការទាមទារបានពីតតិយជនរួចហើយ តែកូនបំណុល មិនព្រមទទួលវត្ថុត្រឡប់ ដូច្នេះម្ចាស់បំណុលអាចទាមទារឱ្យធ្វើការតម្កល់ ។ កម្មវត្ថុដែលត្រូវលុបចោល គឺត្រូវតែជាចលនវត្ថុ ។ ប្រសិនបើវា ជាអចលនវត្ថុ មិនចាំបាច់អនុវត្តវិធីតម្កល់ទេ ពីព្រោះការលុបចោលនូវការចុះបញ្ជី អាចធ្វើឡើងបានដោយមិនចាំបាច់មានការយល់ព្រមពីកូនបំណុល ប្រសិនបើតុលាការបង្គាប់ឱ្យធ្វើយ៉ាងដូច្នោះ ។

**ខ- អចលនវត្ថុមានជាប់បន្ទុកសិទ្ធិប្រាតិភោគ**

| |
|---|
| អង្គហេតុជាមូលដ្ឋាន<br>X គឺជាម្ចាស់បំណុលដែលមានសិទ្ធិលើបំណុលចំពោះ Z ចំនួន ១ 000 ដុល្លារ ហើយ Y គឺជាម្ចាស់បំណុលដែលមានសិទ្ធិលើបំណុលចំនួន ២ 000 ដុល្លារចំពោះ Z ។ ទ្រព្យសម្បត្តិតែមួយគត់របស់ Z គឺ L ដែលមានតម្លៃ ៤ 000 ដុល្លារ ហើយត្រូវបាន យកមកដាក់ជាប្រាតិភោគទៅឱ្យ Y រួចហើយ ។<br>១- Z បានឱ្យដី L នោះទៅ A ដែលជាម្ចាស់បំណុលម្នាក់ផ្សេងទៀតដែលមានសិទ្ធិលើបំណុលចំនួន ១ 000 ដុល្លារ ដែលជាការសងដោយវត្ថុជំនួស ។ អ្នកទាំងពីរនាក់បានដឹងថា នេះគឺជាអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍ ។ X បានដាក់ពាក្យបណ្ដឹង ទៅតុលាការដើម្បីទាមទារឱ្យលុបចោលនូវអំពើនេះ ដោយផ្អែកតាមសិទ្ធិលុបចោលនូវអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍ និង ទាមទារឱ្យប្រគល់ដីត្រឡប់មកវិញ ។ Z បានបង្ហាញឆន្ទៈបដិសេធមិនទទួលយកដី L នោះទេ ។ តើ X អាចទាមទារឱ្យ A លុបចោលការចុះបញ្ជីផ្ទេរកម្មកម្មសិទ្ធិនៃដី L បានដែរឬទេ?<br>២- Z បានឱ្យដី L ទៅ Y ដែលជាការសងដោយវត្ថុជំនួស ។ អ្នកទាំងពីរនាក់បានដឹងថា នេះគឺជាអំពើដែលនាំឱ្យខូចខាត ផលប្រយោជន៍ ។ ដោយសារតែមូលហេតុនោះហើយ សិទ្ធិលើបំណុលរបស់ Y ត្រូវរលត់ ហើយហ៊ីប៉ូតែកក៏រលត់ផងដែរ ។<br>X បានដាក់ពាក្យបណ្ដឹងទៅតុលាការដើម្បីទាមទារឱ្យលុបចោល ដោយផ្អែកលើសិទ្ធិលុបចោលនូវអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍ និង ទាមទារឱ្យប្រគល់ដីត្រឡប់មកវិញ ។ Z បានបង្ហាញឆន្ទៈបដិសេធការប្រគល់ដី L ត្រឡប់មកវិញ ។ តើ X អាចទាមទារឱ្យ A លុបចោលការចុះបញ្ជីផ្ទេរកម្មសិទ្ធិនៃដី L បានដែរឬទេ? |

**សន្និដ្ឋាន**

១-តាមឧទាហរណ៍ខាងលើ X អាចសុំលុបចោលអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍បាន និង អាចទាមទារឱ្យ A ប្រគល់ដីត្រឡប់មកវិញ ទោះបីជា Z បានផ្ទេរដីទៅអោយ A ហើយក៏ដោយ។ ម្យ៉ាងទៀត ការផ្ទេរនេះ មិននាំឱ្យហ៊ីប៉ូតែករបស់ Y រលាយទេ (ភាពទៅជាមួយនៃហ៊ីប៉ូតែក) ដូច្នេះ Y ក៏អាចមានសិទ្ធិក្នុងការ លុបចោលអំពើដែលនាំឱ្យខូចផលប្រយោជន៍បានដែរ និង លុបចោល នូវការចុះបញ្ជីផ្ទេរកម្មសិទ្ធិនៃដីដ L រវាង Z និង A ផងដែរ ទោះបីជា Z បដិសេធមិនព្រមទទួលដីនោះក៏ដោយ។

២-ករណីដែល Z ប្រគល់ដីអោយទៅម្ចាស់បំណុលហ៊ីប៉ូតែកតែម្នាក់

ចំពោះករណីនេះ នាំឱ្យសិទ្ធិលើបំណុលរបស់ Y លើ Z ត្រូវរលត់ ដូច្នេះហ៊ីប៉ូតែកក៏ត្រូវរលត់ដែរ។

បើ X ទាមទារ ការចុះបញ្ជីផ្ទេរកម្មសិទ្ធិរវាង Z និង Y ត្រូវលុបចោល វាអាចមានអានុភាពពីរ:

- X អាចទាមទារបាន : ដីនោះត្រូវប្រគល់ឱ្យ Z ទាំងគ្មានជាប់បន្ទុកហ៊ីប៉ូតែក ដូច្នេះម្ចាស់បំណុល អាចទាមទារបែងចែកចំនែកដោយ គ្មានម្ចាស់បំណុលណាមួយមានអាទិភាពទៀតទេ ប៉ុន្តែការអនុញ្ញាតិឱ្យធ្វើ បែបនេះវាដូចជាអយុត្តិធម៌ ចំពោះ Y ដែលជាម្ចាស់បំណុលអាទិភាពតាំងពីដំបូង។

- X មិនអាចទាមទារបាន : បើ X មិនអាចទាមទារបាន មានន័យថា Y នឹងក្លាយជាម្ចាស់អចលនវត្ថុនោះ តែម្នាក់ឯង តែផ្ទុយទៅវិញសិទ្ធិលើបំណុលរបស់ Y មានចំនួនតែ២ ០០០ដុល្លារប៉ុណ្ណោះ ឯដីមានតម្លៃ៤ ០០០ដុល្លារ ដូច្នេះតម្លៃដីដែលនៅសល់ គឺចំនួន២ ០០០ដុល្លារ ហើយបើសិនមិនអនុញ្ញាតិឱ្យមានសិទ្ធិទាមទារដីត្រឡប់មកវិញ នោះវានាំឱ្យខូចផលប្រយោជន៍របស់ ម្ចាស់បំណុលដទៃទៀត ដោយមិនសមហេតុផល។

ដូច្នេះទោះបីជា X មិនអាចទាមទារដីដែលបានធ្វើអនុប្បទានហើយ មកវិញបានក៏ដោយ តែ X អាចទាមទារចំនួនទឹកប្រាក់ ២ ០០០ ដុល្លារ ដែលឆ្លើយតបទៅនឹងតម្លៃដែលសល់ពីការទូរទាត់បំណុលរបស់ Y បាន។

### ៤-៣ អានុភាពនៃសិទ្ធិលុបចោលនូវអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍

ដោយផ្អែកតាមមាត្រា ៤៣១ សិទ្ធិលុបចោលនូវអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍ ត្រូវបានធ្វើឡើង ដោយម្ចាស់បំណុលណាមួយ ត្រូវបង្កើតអានុភាពសំរាប់ផលប្រយោជន៍របស់ម្ចាស់បំណុលទាំងអស់។

ហេតុដូច្នេះ ក្នុងករណីដែលទ្រព្យសម្បត្តិដែលត្រូវបានធ្វើអនុប្បទាន ត្រូវបានប្រគល់ត្រឡប់មកវិញ ឬ ត្រូវ បានដាក់តម្កល់ ទ្រព្យសម្បត្តិនោះអាចត្រូវបានរឹបអូសតាមនីតិវិធីនៃការអនុវត្តដោយបង្ខំធម្មតាហើយម្ចាស់បំណុល

ដទៃទៀតអាចចូលរួមក្នុងការបែងចែកចំណែករបស់ខ្លួនបាន។

### ៩-៤ អំឡុងពេលដែលអាចអនុវត្តសិទ្ធិលុបចោលនូវអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍

យោងតាមមាត្រា ៤៣២ អំឡុងពេលដែលអាចអនុវត្តសិទ្ធិលុបចោលនូវអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍ ត្រូវបាន កំរិតត្រឹមតែរយៈពេល ១ ឆ្នាំបន្ទាប់ពីពេលដែលម្ចាស់បំណុលបានដឹងអំពីអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍នោះ ឬរយៈពេល ៣ ឆ្នាំ បន្ទាប់ពីពេលដែលអំពើនោះបានកើតឡើង។

អំឡុងពេលនេះគឺមានរយៈពេលខ្លីមិនដាច់ខាត ហើយអំឡុងពេលនេះ មិនអាចយកបញ្ញត្តិស្ដីពីការផ្អាកអាជ្ញាយុកាល មកអនុវត្តចំពោះអាជ្ញាយុកាលរបស់សិទ្ធិលុបចោលនូវអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍បានទេ ដើម្បីជាប្រយោជន៍សំរាប់ស្ថិរភាពគតិយុត្ត។

## ផ្នែកទី ២

## ឧបាទេសកម្មដោយអ្នកមានសិទ្ធិលើបំណុល

### ១- សេចក្តីផ្តើម

ឧបាទេសកម្មនៃសិទ្ធិលើបំណុល គឺជាប្រព័ន្ធមួយដែលអនុញ្ញាតឱ្យម្ចាស់បំណុលអនុវត្តនូវសិទ្ធិរបស់កូនបំណុលជំនួសឱ្យ កូនបំណុលក្នុងគោលដៅដើម្បីរក្សាការពារសិទ្ធិលើបំណុលរបស់ខ្លួន ។ ខុសប្លែកពីសិទ្ធិលុបចោលនូវអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍ដែលផ្តល់សិទ្ធិឱ្យម្ចាស់បំណុល លុបចោលនូវសកម្មភាពផ្សេងៗរបស់កូនបំណុលដែលធ្វើឱ្យប៉ះពាល់ដល់សិទ្ធិរបស់ម្ចាស់បំណុល ឧបាទេសកម្មដោយអ្នកមានសិទ្ធិលើបំណុលត្រូវយកមកប្រើប្រាស់នៅក្នុងករណីដែលកូនបំណុលមិនអើពើនឹងអនុវត្តសិទ្ធិរបស់ខ្លួន ហើយការមិនអើពើនេះ បានធ្វើឱ្យប៉ះពាល់ដល់សិទ្ធិរបស់ម្ចាស់បំណុល ។

ឧបមាថា កូនបំណុលម្នាក់មិនមានប្រាក់គ្រប់គ្រាន់ដើម្បីបំពេញកាតព្វកិច្ចចំពោះម្ចាស់បំណុលរបស់ខ្លួនឡើយ ក៏ប៉ុន្តែគាត់មាន ផ្ទះជួលដោយទទួលបានថ្លៃឈ្នួលចំនួន ៥០ ដុល្លារអាមេរិកក្នុងមួយខែ ។ ទោះជាយ៉ាងនេះក្តី កូនបំណុលជួនកាលអាចមិនរវីរវល់ក្នុងការទាមទារប្រាក់ថ្លៃឈ្នួលពីភតិកៈឡើយ ដោយសារតែ គាត់គិតថា ប្រាក់ដែលគាត់ត្រូវប្រមូលយកមកនោះ ចុងក្រោយ ច្បាស់ជានឹងត្រូវបានទៅម្ចាស់បំណុលរបស់គាត់ជាក់ជាមិនខាន ពោលគឺគាត់មិនអាច រក្សាទុកនូវប្រាក់ទាំងនេះបានទេ ។

ហេតុដូច្នេះ ម្ចាស់បំណុលអាចប្រើប្រាស់យន្តការនៃឧបាទេសកម្មដោយអ្នកមានសិទ្ធិលើបំណុលដើម្បីអាចប្រមូលយកថ្លៃឈ្នួលពីភតិកៈរបស់កូនបំណុលបាន ទោះបីជាម្ចាស់បំណុលមិនទាន់មានលិខិតអនុវត្តសម្រាប់អនុវត្តសិទ្ធិលើបំណុលរបស់គាត់ក៏ដោយ ។

ក្នុងន័យនេះ មាត្រា ៤២២ និងមាត្រាបន្តបន្ទាប់នៃក្រមរដ្ឋប្បវេណីបានចែងពីលក្ខខណ្ឌផ្សេងៗដើម្បីឱ្យ ម្ចាស់បំណុលអាចប្រើប្រាស់សិទ្ធិនេះបាន ។

### ២- លក្ខខណ្ឌ

មាត្រា ៤២២ នៃក្រមរដ្ឋប្បវេណីបានចែងថា :

១-ក្នុងករណីដែលចាំបាច់ដើម្បីរក្សាការពារសិទ្ធិលើបំណុលរបស់ខ្លួន ម្ចាស់បំណុលអាចអនុវត្តសិទ្ធិដែលកូនបំណុលមានជំនួសកូនបំណុលបាន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយចំពោះសិទ្ធិផ្តាច់មុខរបស់កូនបំណុលផ្ទាល់ សិទ្ធិដែលកូនបំណុលអាចសម្រេចដោយឆន្ទៈសេរីរបស់ខ្លួនក្នុងការអនុវត្ត និង សិទ្ធិដែលហាមមិនឱ្យរឹបអូស ។

២-ក្នុងករណីដែលចាំបាច់ ដើម្បីទទួលការបំពេញចំពោះសិទ្ធិលើបំណុលរបស់ខ្លួនម្ចាស់បំណុលអាចអនុវត្ត សិទ្ធិលើបំណុល របស់កូនបំណុលដែលមានការទាក់ទងយ៉ាងខ្លាំងនឹងសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនោះ ដោយឧបាទេសកម្មបាន។

យោងតាមបទប្បញ្ញត្តិខាងលើនេះ ឧបាទេសកម្មដែលអាចអនុវត្តដោយម្ចាស់បំណុលបានមានចំនួន ពីរប្រភេទគឺ :

### ២-១ ឧបាទេសកម្មដោយផ្អែកតាមមាត្រា ៤២២ កថាខណ្ឌទី ១

បើពិនិត្យទៅលើខ្លឹមសារនៃមាត្រា ៤២២ កថាខណ្ឌទី ១ និង មាត្រា ៤២៣ នៃក្រមរដ្ឋប្បវេណីលក្ខខណ្ឌ នៃឧបាទេសកម្ម ដោយអ្នកមានសិទ្ធិលើបំណុលមានចំនួន ៤ ពោលគឺ :

#### ២-១-១ អត្ថិភាពនៃសិទ្ធិលើបំណុល និង ភាពចាំបាច់ដែលត្រូវរក្សាការពារ

ជាដំបូងដើម្បីអាចអនុវត្តសិទ្ធិដែលកូនបំណុលមានជំនួសកូនបំណុលបាន លុះត្រាតែម្ចាស់បំណុល ពិតជា មានសិទ្ធិលើបំណុលចំពោះកូនបំណុលពិតប្រាកដមែន។ ជាងនេះទៅទៀត មិនមែនមានន័យថា ម្ចាស់បំណុល ដែលមានសិទ្ធិលើបំណុលបែបនេះ សុទ្ធតែអាចអនុវត្តសិទ្ធិដែលកូនបំណុលមានជំនួសកូនបំណុលឡើយ ពោលគឺ ត្រូវតែមាន ភស្តុតាងបញ្ជាក់អំពីភាពចាំបាច់ដែលត្រូវរក្សាការពារសិទ្ធិលើបំណុលរបស់ម្ចាស់បំណុល បានសេចក្តីថា ការមិនអើពើរបស់កូនបំណុលក្នុងការអនុវត្តសិទ្ធិរបស់ខ្លួន បានធ្វើឱ្យប៉ះពាល់ដល់សិទ្ធិរបស់ម្ចាស់បំណុល។ ក្នុងន័យនេះ ប្រសិនបើកូនបំណុលមិនធ្វើការទាមទារប្រាក់ថ្លៃឈ្នួលពីភតិកៈរបស់គាត់ក៏ពិតមែន ក៏ប៉ុន្តែ គាត់មានទ្រព្យសម្បត្តិ ផ្សេងទៀតយ៉ាងគ្រប់គ្រាន់ដែលអាចសងទៅម្ចាស់បំណុលបាន នោះគឺមិនមាន ភាពចាំបាច់ដែលត្រូវរក្សាការពារ ឡើយ ឬ និយាយមួយបែបទៀតថា ម្ចាស់បំណុលមិនមានភាពចាំបាច់ដើម្បី រក្សាការពារសិទ្ធិលើបំណុលរបស់ខ្លួន តាមរយៈការប្រើយន្តការ ឧបាទេសកម្មដោយអ្នកមានសិទ្ធិលើបំណុល នេះទេ។

ហេតុដូច្នេះលុះត្រាតែកូនបំណុលមិនមានទ្រព្យសម្បត្តិគ្រប់គ្រាន់ ដើម្បីសងទៅម្ចាស់បំណុល ឬ ហៅម្យ៉ាង វិញទៀតថាអសាធនីយ៍ ទើបម្ចាស់បំណុលមានភាពចាំបាច់ត្រូវរក្សាការពារសិទ្ធិរបស់គាត់ តាមរយៈការប្រើប្រាស់ យន្តការនៃឧបាទេសកម្មដោយអ្នកមានសិទ្ធិលើបំណុល។

#### ២-១-២ ការខកខានមិនបានអនុវត្តសិទ្ធិរបស់កូនបំណុល

ជាការពិតណាស់ ប្រសិនបើកូនបំណុល បានអនុវត្តសិទ្ធិរបស់គាត់ហើយ ម្ចាស់បំណុលមិនអាច ធ្វើឧបាទេសកម្មលើសិទ្ធិនេះបានឡើយ។នៅក្នុងករណីដែលកូនបំណុលបានអនុវត្តសិទ្ធិរបស់គាត់ហើយ ឧបាទេសកម្ម ដោយម្ចាស់បំណុល នឹងប៉ះពាល់ឆន្ទៈផ្ទាល់របស់កូនបំណុល ហើយក៏បង្កើតឱ្យមានការភាន់ច្រឡំផងដែរ ដោយសារតែ មានភាគីច្រើនអនុវត្តសិទ្ធិតែមួយទៅវិញ។

ហេតុដូចនេះ ប្រសិនបើកូនបំណុលបានទាមទារប្រាក់ថ្លៃឈ្នួលពីភតិកៈរបស់គាត់ហើយនោះ ម្ចាស់បំណុល មិនអាចទាមទារ ប្រាក់ថ្លៃឈ្នួលនេះជំនួសកូនបំណុលបានឡើយ។

### ២-១-៣ ខ្លឹមសារនៃសិទ្ធិរបស់កូនបំណុល

ជាធម្មតា សិទ្ធិរបស់កូនបំណុលដែលម្ចាស់បំណុលអាចធ្វើឧបាទេសកម្មបាន សំដៅទៅលើ សិទ្ធិលើបំណុលជាប្រាក់ធម្មតា ដូចជាសិទ្ធិទាមទារឱ្យបង់ប្រាក់ដែលកើតឡើងពីកិច្ចសន្យាលក់ទិញ ឬ ភតិសន្យាជាដើម។ ក៏ប៉ុន្តែតាមការពិត មិនមែនមានតែសិទ្ធិដែលមានគោលបំណងឱ្យសងជាប្រាក់តែប៉ុណ្ណោះទេ ដែលម្ចាស់បំណុលអាចអនុវត្តជំនួសកូនបំណុលបាន គឺនៅមានសិទ្ធិផ្សេងទៀតដូចជា សិទ្ធិលុបចោល សិទ្ធិរំលាយកិច្ចសន្យា ។ល។ និង ។ល។

ហេតុដូច្នេះ ក្នុងករណីដែលកូនបំណុល មិនបានប្រមូលថ្លៃឈ្នួលផ្ទះដែលគាត់បានជួលទៅឱ្យភតិកៈទេ សិទ្ធិរបស់គាត់គឺជាសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់។ ផ្ទុយទៅវិញប្រសិន បើកូនបំណុលឈ្មោះ ក បានធ្វើកិច្ចសន្យាដែលមានខ្លឹមសារថាត្រូវប្រគល់ ផ្ទះមួយខ្នងឱ្យទៅ ឥ ដោយផ្អែកលើកិច្ចសន្យាលក់ទិញអចលនវត្ថុ ក៏ប៉ុន្តែ កិច្ចសន្យានេះ បានកើតឡើងដោយសារតែការគម្រាមកំហែងពីសំណាក់ឈ្មោះ ឥ តែប៉ុណ្ណោះ ក្នុងករណីនេះ ឈ្មោះ ក មានសិទ្ធិតាមច្បាប់ក្នុងការលុបចោលកិច្ចសន្យាដោយសារតែ មានវិការៈនៃការបង្ហាញឆន្ទៈ។ ក៏ប៉ុន្តែទោះបីជាយ៉ាងដូចនេះក្តីឈ្មោះ ក ដែលជាកូនបំណុលនៅតែមិនបង្ហាញឆន្ទៈក្នុងការលុបចោលកិច្ចសន្យាឡើយ។ ក្នុងន័យបែបនេះ ម្ចាស់បំណុលរបស់ ក អាចធ្វើឧបាទេសកម្មសិទ្ធិដើម្បីលុបចោលកិច្ចសន្យាលក់ទិញអចលនវត្ថុខាងលើជំនួសឈ្មោះ ក បាន។ ទន្ទឹមនឹងនេះផងដែរ ម្ចាស់បំណុល ក៏អាចធ្វើឧបាទេសកម្មសិទ្ធិក្នុងការលើកឡើងពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលរបស់កូនបំណុលបានដែរ ក្នុងគោលដៅដើម្បីទប់ស្កាត់មិនឱ្យមានការថយចុះនូវទ្រព្យសម្បត្តិរបស់កូនបំណុលបាន ឱ្យតែលក្ខខណ្ឌនៃការធ្វើឧបាទេសកម្មត្រូវបានបំពេញ។

និយាយជារួម រាល់សិទ្ធិគ្រប់ប្រភេទទាំងអស់របស់កូនបំណុល សុទ្ធតែអាចជាកម្មវត្ថុនៃឧបាទេសកម្មដោយអ្នកមានសិទ្ធិលើបំណុលបាន ក៏ប៉ុន្តែក៏ត្រូវមានលក្ខខណ្ឌផងដែរ ពោលគឺសិទ្ធិដែលអាចធ្វើឧបាទេសកម្មបានមិនមែនជាសិទ្ធិផ្តាច់មុខរបស់កូនបំណុល មិនមែនជាសិទ្ធិដែលហាមមិនឱ្យរឹបអូស ហើយក៏មិនមែនជាសិទ្ធិដែលកូនបំណុលអាចសម្រេចអនុវត្តដោយឆន្ទៈសេរីរបស់ខ្លួនឡើយ។

សិទ្ធិផ្តាច់មុខរបស់កូនបំណុលរួមមានដូចជា សិទ្ធិទាមទារលែងលះ សិទ្ធិទាមទារឱ្យបែងចែកទ្រព្យសម្បត្តិក្នុងករណីលែងលះ សិទ្ធិទាមទារឱ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងជាដើម។ ម្យ៉ាងវិញទៀត សិទ្ធិខ្លះរបស់កូនបំណុល គឺជាសិទ្ធិដែលច្បាប់កំណត់ឱ្យកូនបំណុល អាចសម្រេចដោយឆន្ទៈសេរីទាំងស្រុង ថាតើខ្លួននឹងអនុវត្តសិទ្ធិនោះ ឬ អត់។ ឧទាហរណ៍ ដូចជាសិទ្ធិទាមទារសំណងពីបុគ្គលណាម្នាក់ដោយផ្អែកលើការបំពានសិទ្ធិបុគ្គលដូចជា ការបរិហាកេរ្តិ៍ គឺជាសិទ្ធិបុគ្គល។ ហេតុនេះ កូនបំណុលអនុវត្តសិទ្ធិនេះក៏បាន មិនអនុវត្តក៏បានដែរគឺអាស្រ័យទៅលើឆន្ទៈយ៉ាងសេរីរបស់គាត់។ ក្នុងករណីបែបនេះម្ចាស់បំណុល មិនអាចធ្វើឧបាទេសកម្មបានឡើយ។ បញ្ហាលំបាកអាចចោទឡើងនៅក្នុងការកំណត់ ថាតើសិទ្ធិណាដែលមិនអាចសម្រេច ដោយឆន្ទៈសេរីរបស់កូនបំណុលបាន។

នៅពេលនោះ យុត្តិសាស្ត្ររបស់តុលាការកម្ពុជា នឹងកំណត់ទៅតាមករណីជាក់ស្តែងនីមួយៗដែលបានកើតឡើង។ ជាងនេះទៅទៀត មានតែសិទ្ធិដែលអាចរឹបអូសបានប៉ុណ្ណោះដែលអាចធ្វើឧបាទេសកម្មបាន។ ក្នុងន័យនេះ ប្រសិនបើកូនបំណុលមានសិទ្ធិដែលច្បាប់ហាមឃាត់ការរឹបអូស ម្ចាស់បំណុល ក៏មិនអាចរឹបអូសសិទ្ធិនេះបានដែរដូចនេះការធ្វើឧបាទេសកម្មក៏ពុំមានន័យខ្លឹមសារអ្វីដែរ ដូចជា ករណីនៃសិទ្ធិទាមទារឱ្យផ្គត់ផ្គង់អាហារកាតព្វកិច្ច គឺជាសិទ្ធិដែលមិនអាចរឹបអូសបានទេ ហេតុដូច្នេះ បើទោះបីជាកូនបំណុល មិនព្រមអនុវត្តសិទ្ធិរបស់គាត់ ក៏ម្ចាស់បំណុលនឹងមិនអាចធ្វើឧបាទេសកម្មបានឡើយ។

### ២-១-៤ ពេលវេលាអនុវត្តសិទ្ធិឧបាទេសកម្ម

ជាគោលការណ៍ សិទ្ធិលើបំណុលដែលម្ចាស់បំណុលមានចំពោះកូនបំណុលត្រូវតែបានដល់កំណត់សងដើម្បីឱ្យម្ចាស់បំណុលអាចធ្វើឧបាទេសកម្មបានយោងតាមខ្លឹមសារនៃមាត្រា ៤២៣ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណី។ និយាយមួយបែបទៀតថា ម្ចាស់បំណុល មិនអាចធ្វើឧបាទេសកម្មបានទេ ដរាបណាសិទ្ធិលើបំណុលរបស់គាត់មិនទាន់ដល់កំណត់សង ពីព្រោះថា នៅពេលនោះកូនបំណុលមិនទាន់មានកាតព្វកិច្ចត្រូវសងទៅម្ចាស់បំណុលនៅឡើយ។ ក៏ប៉ុន្តែមានអញ្ញត្រកម្មពីរយ៉ាងទៅនឹងគោលការណ៍ខាងលើរួមមាន :

#### ក-សកម្មភាពរក្សាទុក

មាត្រា ៤២៣ កថាខណ្ឌទី ២ វាក្យខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណី បានកំណត់នូវបដិបញ្ញត្តិទៅនឹងគោលការណ៍ខាងលើសម្រាប់សកម្មភាពរក្សាទុក។ ការធ្វើសកម្មភាពដើម្បីផ្អាកអំឡុងពេលអាជ្ញាយុកាល គឺជាសកម្មភាពមួយដែលមានគោលដៅរក្សាទុកនូវសិទ្ធិលើបំណុលរបស់កូនបំណុលកុំឱ្យរលត់ ដោយសារតែការផុតអំឡុងពេលអាជ្ញាយុកាល។

ឧបមាថា កូនបំណុលឈ្មោះ **ក** មានសិទ្ធិលើបំណុលចំពោះឈ្មោះ **គ** ហើយនឹងត្រូវផុតអំឡុងពេលអាជ្ញាយុកាលនៅថ្ងៃទី ០៥ ខែ មករាឆ្នាំ ២០១២ ក៏ប៉ុន្តែ នៅខណៈនេះ សិទ្ធិលើបំណុលរបស់ម្ចាស់បំណុលឈ្មោះ **ខ.** ចំពោះកូនបំណុល **ក.** មិនទាន់ដល់កំណត់ត្រូវសងនៅឡើយ។ ក្នុងស្ថានភាពបែបនេះ ប្រសិនបើយកគោលការណ៍ខាងលើមកអនុវត្តម្ចាស់បំណុលឈ្មោះ **ខ** មិនអាចធ្វើឧបាទេសកម្មបានទេហើយនៅពេលផុតថ្ងៃទី ០៥ ខែ មករាឆ្នាំ ២០១២ សិទ្ធិលើបំណុលរបស់ឈ្មោះ **ក** ចំពោះ **គ** នឹងត្រូវរលត់ដោយសារអាជ្ញាយុកាល ហើយម្ចាស់បំណុលក៏នឹងបាត់បង់ឱកាសនឹងបង្កើនទ្រព្យសម្បត្តិរបស់កូនបំណុលរបស់គាត់ ដើម្បីជាប្រយោជន៍ដល់រូបគាត់ដែរ។

សូមធ្វើការកត់សម្គាល់ថា ការទទួលការសងពីតតិយជន មិនមែនជាសកម្មភាពរក្សាទុកទេ បានសេចក្តីថា ដរាបណាមិនទាន់ ដល់កាលកំណត់ត្រូវសងទេ ម្ចាស់បំណុលមិនអាចទទួលការសងពីតតិយជនបានឡើយ ពីព្រោះថាការទទួលការសងពីតតិយជនមុនកាលកំណត់ មិនមែនជាសកម្មភាពរក្សាទុកឡើយ។

ក៏ប៉ុន្តែផ្ទុយទៅវិញ ប្រសិនបើដល់កំណត់សងហើយ ហើយកូនបំណុលនៅតែមិនប្រមូលសិទ្ធិលើបំណុលរបស់ខ្លួនដែលមានចំពោះតតិយជនទេ ម្ចាស់បំណុលត្រូវដាស់តឿនឱ្យតតិយជននោះសងទៅកូនបំណុល ឬ ក៏ដាក់

ពាក្យបណ្តឹងទៅតុលាការដើម្បីទាមទារឱ្យតតិយជនសងទៅកូនបំណុលបាន ដើម្បីរក្សាការពារសិទ្ធិលើបំណុលរបស់គាត់ ដែលមានចំពោះកូនបំណុល ។

**ខ-ការអនុញ្ញាតពីតុលាការ**

មាត្រា ៤២៣ កថាខណ្ឌទី ២ វាក្យខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី អនុញ្ញាតឱ្យម្ចាស់បំណុលអនុវត្តសិទ្ធិរបស់កូនបំណុលបាន ទោះបីជាពេលកំណត់ នៃសិទ្ធិលើបំណុលរបស់គាត់មិនទាន់ដល់ក៏ដោយ នៅក្នុងករណីដែលបានទទួលការអនុញ្ញាតពីតុលាការឱ្យធ្វើយ៉ាងដូច្នេះ ។ ដើម្បីអាចឱ្យតុលាការអនុញ្ញាតឱ្យម្ចាស់បំណុលធ្វើឧបាទេសកម្មនូវសិទ្ធិរបស់ កូនបំណុលបានថ្វីត្បិតតែសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលមិនទាន់ ដល់កាលកំណត់សងក៏ដោយនោះ តុលាការត្រូវ ធ្វើការពិនិត្យផ្ទៀងផ្ទាត់នូវលក្ខខណ្ឌផ្សេងៗនៃសិទ្ធិឧបាទេសកម្ម ព្រមទាំងភាពចាំបាច់នៃការធ្វើឧបាទេសកម្ម មុនកាលកំណត់មកដល់ ។ តុលាការសម្រេចអនុញ្ញាតឱ្យអនុវត្តសិទ្ធិឧបាទេសកម្មដោយចេញជាដីកាសម្រេចយោងតាមច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ។ ក្នុងករណីបែបនេះ ការដាក់ពាក្យសុំឱ្យតុលាការ អនុញ្ញាតឱ្យអនុវត្តសិទ្ធិឧបាទេសកម្ម ត្រូវធ្វើឡើងដោយម្ចាស់បំណុលចំពោះតតិយជនដែលជាកូនបំណុលរបស់ កូនបំណុលដោយមិនចាំបាច់ដាក់ពាក្យសុំចំពោះកូនបំណុលឡើយ ។

**២-២ ឧបាទេសកម្មហួសវិស័យនៃមាត្រា ៤២២ កថាខណ្ឌទី ២**

យោងតាមមាត្រា ៤២២ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណី បានចែងថា : *ក្នុងករណីដែលចាំបាច់ដើម្បីទទួលការបំពេញចំពោះសិទ្ធិលើបំណុលរបស់ខ្លួន ម្ចាស់បំណុលអាចអនុវត្តសិទ្ធិលើបំណុលរបស់កូនបំណុលដែលមានការទាក់ទងយ៉ាងខ្លាំងនឹងសិទ្ធិលើ បំណុលរបស់ម្ចាស់បំណុលនោះដោយឧបាទេសកម្មបាន* ។

ខុសប្លែកពីមាត្រា ៤២២ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណីដែលត្រូវបានបកស្រាយរួចហើយមាននៅដូចខាងលើស្រាប់បទប្បញ្ញត្តិនៃមាត្រា ៤២២ កថាខណ្ឌទី ២ មិនបានទាមទារឱ្យមានភាពចាំបាច់ដើម្បីរក្សាការពារសិទ្ធិលើបំណុលរបស់ម្ចាស់បំណុល ដើម្បីអាចអនុវត្តសិទ្ធិឧបាទេសកម្មបានឡើយពោល គឺសិទ្ធិឧបាទេសកម្មនេះអាចអនុវត្តបាន បើទោះបីជាមិនមានភាពចាំបាច់ដើម្បីរក្សាការពារសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលក៏ដោយ ។ ក្នុងន័យនេះ ទោះបីជាកូនបំណុលមិនស្ថិតក្នុងស្ថានភាពអសាធនីយ៍ក៏ដោយ ក៏ម្ចាស់បំណុលនៅតែអាចអនុវត្តសិទ្ធិឧបាទេសកម្មបានដដែល ។អ្វីដែលជាលក្ខខណ្ឌចាំបាច់ គឺការទាក់ទងយ៉ាងខ្លាំងរវាងសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនិងសិទ្ធិលើបំណុលរបស់កូនបំណុល ។

**ឧទាហរណ៍** : ឈ្មោះ **ក** មានសិទ្ធិទាមទារឱ្យឈ្មោះ **ខ** សងសំណងនៃការខូចខាត ដោយផ្អែកលើអំពើអនីត្យានុកូល ។ ដោយហេតុថា ឈ្មោះ **ខ** មានការធានារ៉ាប់រងគឺនាំឱ្យឈ្មោះ **ខ** មានសិទ្ធិទាមទារសំណងពីក្រុមហ៊ុនធានារ៉ាប់រងបាន ។ ក្នុងករណីបែបនេះ ទោះបីជាឈ្មោះ **ខ**. មានទ្រព្យសម្បត្តិគ្រប់គ្រាន់ ដើម្បីបង់សំណងនៃការខូចខាតឱ្យទៅឈ្មោះ **ក** ក៏ដោយ ក៏ឈ្មោះ **ក** នៅតែអាចអនុវត្តសិទ្ធិឧបាទេសកម្មចំពោះក្រុមហ៊ុនធានា

រ៉ាប់រងជំនួសឱ្យ ខ បានដែរ ពីព្រោះថា សិទ្ធិលើបំណុលរបស់ឈ្មោះ ក និង សិទ្ធិលើបំណុលរបស់ឈ្មោះ ខ ក្នុងស្ថានភាពនេះ គឺមានការទាក់ទងគ្នាយ៉ាងខ្លាំង ។

ការកំណត់ថា សិទ្ធិលើបំណុលបែបណាដែលជាសិទ្ធិលើបំណុលដែលមានការទាក់ទងគ្នាយ៉ាងខ្លាំងនោះ គឺអាស្រ័យទៅតាម ការវិនិច្ឆ័យនៃយុត្តិសាស្ត្ររបស់តុលាការកម្ពុជានាពេលអនាគតតែប៉ុណ្ណោះ ដោយមូលហេតុថា ក្រមរដ្ឋប្បវេណីមិនបានផ្តល់និយមន័យ ច្បាស់លាស់អំពីលក្ខណៈនៃភាពទាក់ទងគ្នាយ៉ាងខ្លាំងនោះទេ ។

**៣ -វិធីអនុវត្ត**

កូនបំណុល អាចអនុវត្តសិទ្ធិលើបំណុលរបស់ខ្លួនចំពោះកូនបំណុលទី៣ រួចយកមកអនុវត្តកាតព្វកិច្ចសង ចំពោះម្ចាស់បំណុលបាន ។ រីបើកូនបំណុលអលទ្ធភាព នោះម្ចាស់បំណុលអាចធ្វើឧបាទេសកម្ម ចំពោះកូនបំណុល ទី៣បាន ។

មិនដូចសិទ្ធិលុបចោលនូវអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍នោះទេ ម្ចាស់បំណុលអាចធ្វើឧបាទេសកម្ម សិទ្ធិក្រៅតុលាការបាន ។ តាមការអនុវត្ត ម្ចាស់បំណុល អាចទាមទារឱ្យសងក្រៅតុលាការជាមុនសិនបាន បន្ទាប់មកទៀត បើកូនបំណុលទី៣ បដិសេធមិនព្រមអនុវត្តចំពោះម្ចាស់បំណុល នោះម្ចាស់បំណុល អាចដាក់ពាក្យ បណ្តឹងទាមទារតាមផ្លូវតុលាការបាន ។

**៤ -អានុភាពនៃសិទ្ធិឧបាទេសកម្មរបស់ម្ចាស់បំណុល**

**៤- ១ ការតវ៉ារបស់កូនបំណុលទី ៣**

កូនបំណុលទី ៣ អាចតតាំងចំពោះម្ចាស់បំណុលដែលធ្វើឧបាទេសកម្ម ដោយយកការតវ៉ាដែល កូនបំណុលទី ៣ នោះមាន ចំពោះម្ចាស់បំណុលរបស់ខ្លួន យោងតាមមាត្រា ៤២៤ ។

| |
|---|
| X មានសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់ចំពោះ Y ហើយ Y បានលក់គ្រឿងអលង្កាទៅឱ្យ Z ។ Y មិនបានផ្តល់ គ្រឿងអលង្កា ហើយក៏មិនបានទាមទារឱ្យបង់ថ្លៃលក់ដែរ ។ ដោយសារតែ Y ក្លាយជាអសាធនីយ៍ X ធ្វើឧបាទេសកម្មសិទ្ធិទាមទារឱ្យបង់ថ្លៃ លក់ចំពោះ Z ប៉ុន្តែ Z បដិសេធមិនព្រមបង់ថ្លៃលក់ទេ ដោយសារ ការតវ៉ាឱ្យអនុវត្តព្រមគ្នា ។ |

**ក្នុងករណីនេះ បើ X ធ្វើឧបាទេសកម្មទាមទារពី Z ដោយសារតែ Z មានលក្ខខណ្ឌតវ៉ាឱ្យអនុវត្តព្រមគ្នា ដែលមានចំពោះ Y ដូច្នេះនាំឱ្យ Z ក៏អាចតវ៉ាជាមួយ X ដែរ ។** នេះជារឿងសាមញ្ញ ពីព្រោះអ្វីដែល X ធ្វើឧបាទេសកម្ម (អនុវត្ត) ចំពោះ Z គឺសិទ្ធិរបស់ Y ប៉ុន្តែ មិនមែនជាសិទ្ធិរបស់ X ផ្ទាល់នោះទេ ។ ហេតុដូច្នេះ Z អាចអះអាងអំពីការតវ៉ាតែមួយចំពោះការអនុវត្តបែបនេះ ។

### ៤- ២ ទំនាក់ទំនងរវាងម្ចាស់បំណុលដែលធ្វើឧបាទេសកម្ម និង កូនបំណុល

ដោយផ្អែកតាមមាត្រា ៤២៥ ក្រោយពេលដែលទទួលបានការជូនដំណឹង កូនបំណុលមិនអាចអនុវត្តសិទ្ធិរបស់ខ្លួនបានទេ លើកលែងតែករណី កូនបំណុល ***ទទួលការសងពីកូនបំណុលទីៗ*** ។

| |
|---|
| X មានសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់ចំពោះ Y ចំនួន ៤០០ ដុល្លារ ហើយ Y មានសិទ្ធិលើបំណុល ចំពោះ Z ចំនួន ១ ០០០ ដុល្លារដែរ។ ដោយសារតែ Y ក្លាយជាអសាធនីយ៍ X ក៏បានធ្វើឧបាទេសកម្មសិទ្ធិក្នុងទំហំទឹកប្រាក់ចំនួន ៤០០ ដុល្លារចំពោះ Z ហើយ ក៏បានជូនដំណឹងអំពីការធ្វើឧបាទេសកម្មនេះទៅ Y។ ក្រោយពីការជូនដំណឹងនេះ ចំពោះប្រាក់ចំនួន ៤០០ ដុល្លារ Y មិនអាចទាមទារ ឬ ធ្វើអ្វីផ្សេងទៀត បាននោះទេ ក្រៅពីការទទួលការសងពី Z ។ |

ក្នុងករណីនេះ បើ X ធ្វើឧបាទេសកម្មចំនួន ៤០០ដុល្លារពី Z ហើយធ្វើការជូនដំណឹងទៅ Y ពីការសងនោះ Y មិនអាច អនុវត្តសិទ្ធិលើបំណុលរបស់ខ្លួនលើ Z បានទេ។ ប៉ុន្តែចំណែកណាដែលមិនធ្វើឧបាទេសកម្ម គឺ Y អាចអនុវត្តបាន។ មាត្រានេះ គឺមានបំណងបញ្ជាក់ឱ្យបានច្បាស់ថាតើ នរណាមានសិទ្ធិអនុវត្តដើម្បីជាប្រយោជន៍ដល់កូនបំណុលទី ៣។

### ៤- ៣ អានុភាពនៃឧបាទេសកម្មចំពោះកូនបំណុល

អានុភាពនៃឧបាទេសកម្ម របស់ម្ចាស់បំណុលដែលធ្វើឧបាទេសកម្មត្រូវមានលើកូនបំណុល ដោយផ្អែកតាមមាត្រា ៤២៦ កថាខណ្ឌទី ១ ។

| |
|---|
| X មានសិទ្ធិលើបំណុលចំនួន ៥០០ ដុល្លារចំពោះ Y ហើយ Y មានសិទ្ធិលើបំណុលចំពោះ Z ចំនួន ១ ០០០ដុល្លារ។ ដោយសារតែ Y អសាធនីយ៍ X ក៏បានធ្វើឧបាទេសកម្មសិទ្ធិក្នុងទំហំទឹកប្រាក់ចំនួន ៥០០ ដុល្លារចំពោះ Z ហើយក៏បានជូនដំណឹង អំពីការធ្វើ ឧបាទេសកម្មនេះទៅ Y ។<br>១- ដោយសារ Y បដិសេធមិនទទួលការសង X ក៏បានទាមទារឱ្យ Z សងមកខ្លួន ហើយ Z ក៏បានសងដល់ X ។ នៅក្នុងករណីនេះ ដោយសារមាត្រា ៤២៦ កថាខណ្ឌទី ១ ការសងរបស់ Z ក៏មានអានុភាពចំពោះ Y ផងដែរ ហេតុដូច្នេះចំនួន ទឹកប្រាក់នៃកាតព្វកិច្ច គឺត្រូវបន្ថយមកត្រឹមចំនួន ៥០០ ដុល្លារ។<br>២- X បានដាក់ពាក្យបណ្តឹងទាមទារឱ្យសង ហើយ Z បានលើកឡើងនូវអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល ហើយការលើក ឡើងនេះត្រូវបានទទួលស្គាល់ (Z ឈ្នះក្តី) ។ នៅក្នុងករណីនេះ អានុភាពដែលចង មានមិនត្រឹមតែទៅលើ X និង Z តែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងទៅលើ Y ទៀតផង។ ហេតុដូច្នេះ Y លែងអាចទាមទារឱ្យ Z សងទៀតទេ។ |

ជាគោលការណ៍ អ្នកដែលអាចលើកឡើងពីអាជ្ញាយុកាលរំលត់សិទ្ធិលើបំណុល តាមមាត្រា**៤៨៦** គឺមានតែភាគី ,អ្នកធានា , កូនបំណុលដោយសាមគ្គីភាព, អ្នកធានាដោយវត្ថុ, តតិយជនដែលបានធ្វើលទ្ធកម្ម និងអ្នកដែលមានផលប្រយោជន៍ត្រឹមត្រូវតាម ច្បាប់។ ដូច្នេះនៅក្នុងបណ្តឹងរវាង X និង Z គឺ Z ជាកូនបំណុល ដូច្នេះនាំអោយ Z មានសិទ្ធិលើកឡើងពីអាជ្ញាយុកាល។

**អានុភាពនៃការលើកឡើងពីអាជ្ញាយុកាលរបស់ Z ចំពោះសិទ្ធិលើបំណុលរវាង Y និង Z**

**តាមមាត្រា ៤៨៦ កថាខណ្ឌទី ៣** ការលើកពីអាជ្ញាយុកាលវាមានតែចំពោះម្ចាស់បំណុល នឹង កូនបំណុល ប៉ុណ្ណោះ ផ្ទុយទៅវិញ បើការលើកឡើងដោយ **ជនដែលមានផលប្រយោជន៍** នោះអានុភាពនេះ មិនមានចំពោះ កូនបំណុលទេ។ ដូច្នេះបើលើកពីអាជ្ញាយុកាល វាមានអានុភាពតែចំពោះ X និង Z ប៉ុន្តែវាគ្មានអានុភាពចំពោះ Y ទេ ជាទូទៅ។ ប៉ុន្តែ មាត្រា ៤២៦ មានអានុភាពទៅ Y ដោយករណីលើកលែង។ ដោយសារតែមាត្រានេះ Z អាចបញ្ចៀសនូវការពារខ្លួនគាត់ច្រើនជាងម្តង (នៅពេលដែល Z ឈ្នះក្នុងការតវ៉ាចំពោះម្ចាស់បំណុលដែល ធ្វើឧបាទេសកម្ម Z មិនមានទៀតទេ ពិព្រោះអានុភាពបែបនេះ មានទៅលើកូនបំណុល ( Y នៅក្នុងករណីនេះ)) ។

## ៩- ៩ ការទទួលការសង

**តាមមាត្រា ៤២៦ កថាខណ្ឌទី ២** បើម្ចាស់បំណុលទាមទារឱ្យកូនបំណុលទី៣សងប្រាក់ ហើយកូនបំណុលទី ៣ បានសងទៅកូន បំណុលដូច្នេះកូនបំណុលត្រូវទទួលការសង បើកូនបំណុលមិនព្រមទទួលការសង ម្ចាស់បំណុល អាចទាមទារអោយកូនបំណុលទី៣ សងមកខ្លួនបាន ដោយករណីលើកលែងដោយផ្ទាល់។

**តាមមាត្រា ៤២៧** ម្ចាស់បំណុល អាចរក្សារតាវកាលិកដែលខ្លួនទទួលបានពីកូនបំណុលទី៣ ដើម្បីម្ចាស់បំណុល ផ្សេងទៀត រហូតដល់ពេលត្រូវប្រគល់តាវកាលិកនោះទៅកូនបំណុល។

X មានសិទ្ធិលើបំណុលចំនួន ៥០០ ដុល្លារចំពោះ Y ហើយ Y មានសិទ្ធិលើបំណុលចំពោះ Z ចំនួន ១ ០០០ ដុល្លារ។ ដោយសារតែ Y អសាធនីយ៍ X ក៏បានធ្វើឧបាទេសកម្មសិទ្ធិក្នុងទំហំទឹកប្រាក់ចំនួន ៥០០ ដុល្លារចំពោះ Z ហើយ ក៏បានជូនដំណឹង អំពីការធ្វើឧបាទេសកម្មនេះទៅ Y ។ មានម្ចាស់បំណុលដទៃផ្សេងទៀត គឺ A1, A2 និង A3 ចំពោះ Y ដែលម្ចាស់បំណុលម្នាក់ៗនោះ មានសិទ្ធិបំណុលចំនួន ៥០០ ដុល្លារ។ ដោយសារ Y បដិសេធមិនព្រម ទទួលការសង, X ក៏បានទាមទារឱ្យ Z សងមកខ្លួនហើយ Z ក៏បានសង។

នៅក្នុងករណីនេះ យោងតាមមាត្រា ៤២៧ X មិនអាចយកទឹកប្រាក់ចំនួន ៥០០ ដុល្លារនេះ មកកាត់ សិទ្ធិលើបំណុលរបស់ខ្លួនបានទេ។ X ត្រូវរក្សា និង ប្រគល់ទឹកប្រាក់ចំនួន ៥០០ ដុល្លារនេះទៅឱ្យកូនបំណុល (Y) ហើយបន្ទាប់មក X អាចអនុវត្តសិទ្ធិរបស់ខ្លួនតាមធម្មតាតាមរយៈការអនុវត្តដោយបង្ខំជាដើម។ ជាការពិតណាស់ ម្ចាស់បំណុលផ្សេងដទៃទៀត អាចអនុវត្តសិទ្ធិរបស់ខ្លួនតាមធម្មតា (X មិនមានអាទិភាពនោះទេ ទោះបីជា គាត់ ប្រមូលប្រាក់ពី Z ក៏ដោយ) ។

**X** បានធ្វើឧបាទេសកម្មទាមទារឱ្យ **Z** សងប្រាក់ចំនួន ៥០០ ដុល្លារ ពេលទទួលបានហើយ **X** ត្រូវរក្សាប្រាក់ទុក ប៉ុន្តែ មិនអាចយកប្រាក់នោះមកកាត់ ឬទូទាត់បានឡើយ ។